# កើតមក មានសេរីភាព និង សមភាព

ទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ
នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ



អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

# កើតមក មានសេរីភាព និង សមភាព

## ទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

ទីក្រុងញូវយ៉ក និង ហ្សឺណែវ ឆ្នាំ ២០១២

## កំណត់ចំណាំ

វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ និងការបង្ហាញឯកសារនៅក្នុងអត្ថបទបោះពុម្ពផ្សាយនេះ មិនបានបញ្ជាក់អំពីការសម្តែងទស្សនៈណាមួយរបស់លេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់របស់ ប្រទេស ដែនដី ទីក្រុង ឬ តំបន់ណាមួយ ឬ របស់អាជ្ញាធររនៃប្រទេស ដែនដី ទីក្រុង ឬ តំបន់នោះ ឬ ពាក់ព័ន្ធនឹង ការកំណត់ ព្រំដែនរបស់ប្រទេស ដែនដី ទីក្រុង ឬ តំបន់នោះឡើយ ។

និមិត្តសញ្ញានៃឯកសាររបស់អង្គការសហប្រជាជាតិមានអក្សរធំដែលត្រូវបានភ្ជាប់ជាមួយនឹងតួលេខ។ ការលើកឡើងនូវតួលេខបែបនេះ បង្ហាញអំពីសេចក្តីយោងទៅនឹងឯកសាររបស់អង្គការសហប្រជាជាតិ ។

HR/PUB/12/06

@ ២០១២ អង្គការសហប្រជាជាតិ
រក្សាសិទ្ធិគ្រប់យ៉ាង នៅទូទាំងពិភពលោក

# មាតិកា

បុព្វកថា............................................................ ០៧

សេចក្តីផ្តើម............................................................ ០៩

អនុសាសន៍សង្ខេប............................................................ ១៤

កាតព្វកិច្ចផ្លូវច្បាប់សំខាន់ប្រាំរបស់រដ្ឋចំពោះកិច្ចការពារសិទ្ធិមនុស្សរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT)............. ១៥

១. ការពារបុគ្គលពីអំពើហិង្សាដែលបង្កឡើងដោយសារការស្អប់ការស្រលាញ់ភេទដូចគ្នា និង ការប្តូរភេទ............................................................ ១៥

២. ទប់ស្កាត់ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មដ៏ឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប ចំពោះ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT)..................................... ២៥

៣. មិនត្រូវចាត់ទុកការស្រលាញ់ភេទដូចគ្នាជាបទល្មើសព្រហ្មទណ្ឌ............................... ៣២

៤. ហាមឃាត់ការរើសអើង ដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ.............. ៤៥

៥. គោរពសេរីភាពក្នុងការសម្តែងមតិ ធ្វើសមាគម និងជួបជុំដោយសន្តិវិធី.................... ៦៥

សេចក្តីសន្និដ្ឋាន............................................................ ៧៤

# បុព្វកថា

ករណីពង្រីកសិទ្ធិដល់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) ឲ្យមានដូចមនុស្សដទៃទៀត គឺមិនហួសហេតុ និងមិនស្មុគស្មាញទេ។ វាមានមូលដ្ឋាននៅលើគោលការណ៍គ្រឹះពីរ ដែលទ្រទ្រង់ច្បាប់សិទ្ធិមនុស្សអន្តរជាតិ គឺ សមភាព និងភាពមិនរើសអើង។ពាក្យផ្តើមដំបូងនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សបានបញ្ជាក់ច្បាស់លាស់ថា: "មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ" ។

ទោះជាយ៉ាងណាក៏ដោយ ឥរិយាបថស្អប់មនុស្សស្រលាញ់មនុស្សភេទដូចគ្នា ដែលកប់យ៉ាងជ្រៅដែលជារឿយៗ រួមផ្សំជាមួយនឹងកង្វះការគាំពារផ្នែកច្បាប់ពេញលេញចំពោះការរើសអើងដោយផ្អែកលើមូលហេតុទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ ធ្វើឲ្យមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ (LGBT) ជាច្រើននាក់នៅគ្រប់វ័យទាំងអស់ និងនៅគ្រប់តំបន់ទាំងអស់ក្នុងពិភពលោក ប្រឈមទៅនឹងអំពើរំលោភបំពានដ៏ធ្ងន់ធ្ងរលើ សិទ្ធិមនុស្សរបស់ពួកគេ។ ពួកគេត្រូវបានរើសអើង នៅក្នុងទីផ្សារពលកម្ម នៅតាមសាលារៀន និង មន្ទីរពេទ្យ និងត្រូវបានធ្វើទុក្ខទោស និងត្រូវបានលែងទទួលស្គាល់ពីសំណាក់គ្រួសាររបស់ពួកគេផ្ទាល់។ នៅតាមដងវិថីនានានៅក្នុងទីក្រុងតូចនិងទីក្រុងធំនៅជុំវិញពិភពលោកពួកគេ ត្រូវបានកំណត់ជាគោលដៅ ដើម្បីវាយប្រហារលើរាយកាយពោលគឺត្រូវបានវាយដំ ចាប់រំលោភផ្លូវភេទ ធ្វើទារុណកម្ម និងធ្វើឃាត។ ហើយនៅក្នុងប្រទេសប្រហែល ៧៦ ប្រទេស ច្បាប់ដែលមានភាពរើសអើង ចាត់ទុកទំនាក់ទំនងផ្លូវភេទដូចគ្នា ដែលមានការព្រមព្រៀងជាឯកជនគឺជាបទល្មើសព្រហ្មទណ្ឌមានន័យថាធ្វើឲ្យបុគ្គលទាំងនោះប្រឈមទៅនឹងហានិភ័យនៃការចាប់ខ្លួន ការចោទប្រកាន់ និងការដាក់ពន្ធនាគារ។

កង្វល់អំពីករណីទាំងនេះ និង ការរំលោភបំពានពាក់ព័ន្ធ ត្រូវបានសម្តែងចេញដដែលៗ ដោយយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០មកម្ល៉េះ។ យន្តការទាំងនេះ រួមបញ្ចូលអង្គការសន្ធិសញ្ញាដែលត្រូវបានបង្កើតឡើងដើម្បីពិនិត្យតាមដានរដ្ឋទាំងឡាយក្នុងការអនុវត្តតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និង ព្រមទាំងអ្នករាយការណ៍ពិសេស និង អ្នកជំនាញការឯករាជ្យផ្សេងទៀតដែលត្រូវបានតែងតាំងដោយអតីតគណៈកម្មការសិទ្ធិមនុស្ស និង ស្ថាប័នស្នងបន្តរបស់អង្គការនេះ ហៅថា ក្រុមប្រឹក្សាសិទ្ធិមនុស្សដើម្បីស៊ើបអង្កេត និង រាយការណ៍អំពីបញ្ហាប្រឈមចំពោះមុខផ្នែកសិទ្ធិមនុស្ស។ នៅក្នុងឆ្នាំ ២០១១ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានអនុម័តសេចក្តីសម្រេចចិត្តដោយសម្តែងចេញនូវ "កង្វល់ដ៏ខ្លាំងក្លាបំផុត" អំពីអំពើហិង្សា និង ការរើសអើងចំពោះបុគ្គលដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័ររបស់គេ។តម្រូវការឲ្យមានវិធានការបញ្ឈប់ការរំលោភបំពានទាំងនេះត្រូវបានទទួលស្គាល់យ៉ាងច្រើន និងទូលំទូលាយ ទោះបីជាមិនត្រូវបានទទួលយកជាសកលក្តី ។

ការបញ្ចប់អំពើហិង្សា និង ការរើសអើងចំពោះបុគ្គល ដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័ររបស់បុគ្គលទាំងនោះ គឺជាបញ្ហាប្រឈមជាចម្បងផ្នែកសិទ្ធិមនុស្ស។ ខ្ញុំសង្ឃឹមថា សៀវភៅនេះ ដែលពន្យល់អំពីកាតព្វកិច្ចតាមផ្លូវច្បាប់ដែលរដ្ឋមានចំពោះមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) អាចរួមចំណែកដល់កិច្ចពិភាក្សាវែកញែក ទាំងនៅថ្នាក់ជាតិ និងពិភពលោកដែលជាករណីដែលចាំបាច់ត្រូវមានការអនុត្ត។

ចំពោះការលំបាកទាំងអស់នេះ គឺជាពេលវេលានៃសេចក្តីសង្ឃឹម មានន័យថា រដ្ឋដែលមានចំនួនកើនឡើង បច្ចុប្បន្ននេះ ទទួលស្គាល់ពីភាពធ្ងន់ធ្ងរនៃបញ្ហានេះ និងតម្រូវការចាំបាច់ឲ្យមានវិធានការ។ ដោយមានការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងរួមគ្នារបស់រដ្ឋទាំងឡាយ និងសង្គមស៊ីវិល ខ្ញុំទុកចិត្តបានថា យើងនឹងមើលឃើញគោលការណ៍សមភាព និង ការមិនរើសអើង ដែលត្រូវបានប្រែក្លាយទៅជាតថភាពសម្រាប់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) នៅជុំវិញពិភពលោក ។



**ណាវី ភីឡាយ**

ឧត្តមស្នងការនៃអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្ស

# សេចក្ដីផ្ដើម

បន្ទាប់ពីរយៈពេលជាច្រើនទសវត្សរ៍ដែលពាក្យ "ទំនោរផ្លូវភេទ" និង "អត្តសញ្ញាណយេនឌ័រ" កម្រនឹងត្រូវបានលើកមកនិយាយនៅក្នុងកិច្ចប្រជុំផ្លូវការអន្តររដ្ឋាភិបាលនៅអង្គការសហប្រជាជាតិកិច្ចពិភាក្សាវែកញែកកំពុងលាតត្រដាងនៅក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងទីក្រុងហ្សឺណែវអំពីសិទ្ធិរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្ដូរភេទ។ កិច្ចពិភាក្សានៅក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ បានយកចិត្តទុកដាក់ផ្នែកនយោបាយទៅលើច្បាប់ និង ការអនុវត្តដែលមានភាពរើសអើងនៅថ្នាក់ជាតិ និង ទៅលើកាតព្វកិច្ចរបស់រដ្ឋក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាទាំងនេះ តាមរយៈវិធានការច្បាប់ និងវិធានការផ្សេងទៀត ។

នៅខែ មិថុនា ឆ្នាំ ២០១១ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានអនុម័តសេចក្ដីសម្រេចលេខ១៧/១៩ ដែលជាសេចក្ដីសម្រេចលើកទីមួយស្ដីពីសិទ្ធិមនុស្សទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័ររបស់អង្គការសហប្រជាជាតិ។ សេចក្ដីសម្រេចនេះ ត្រូវបានអនុម័តដោយសម្លេងភាគតិច ប៉ុន្តែជាសំខាន់នោះត្រូវទទួលបានការគាំទ្រពីសមាជិកក្រុមប្រឹក្សាដែលមកពីគ្រប់តំបន់ទាំងអស់។ ការអនុម័តលើសេចក្ដីសម្រេចនេះបានត្រួសត្រាយផ្លូវសម្រាប់របាយការណ៍ជាផ្លូវការលើកទីមួយរបស់អង្គការសហប្រជាជាតិស្ដីពីកម្មវត្ថុដូចគ្នា ដែលត្រូវបានរៀបចំឡើងដោយការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ។[1]

របាយការណ៍របស់ឧត្ដមស្នងការ បង្ហាញនូវភស្ដុតាងដែលបញ្ជាក់អំពីគំរូនៃអំពើហិង្សាជាប្រព័ន្ធ និងការរើសអើងចំពោះមនុស្សនៅគ្រប់តំបន់ទាំងអស់ ដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័ររបស់ពួកគេពោលគឺចាប់ពីការរើសអើងលើការងារ ការថែទាំសុខភាព និង ការអប់រំ រហូតដល់ការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ និងការវាយប្រហារលើរូបរាងកាយដែលត្រូវបានកំណត់ជាគោលដៅ សូម្បីតែការធ្វើឃាតក៏ដោយ។ របាយការណ៍បានរួមបញ្ចូលអនុសាសន៍មួយចំនួន ដែលត្រូវបានលើកឡើងសម្រាប់រដ្ឋទាំងឡាយ និងត្រូវបានរៀបចំឡើង ដើម្បីពង្រឹងកិច្ចគាំពារសិទ្ធិមនុស្សរបស់ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្ដូរភេទ (LGBT)[2] ។ លទ្ធផលស្រាវជ្រាវ

[1]របាយការណ៍របស់ឧត្ដមស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ស្ដីពី "ច្បាប់ និង ការអនុវត្តដែលមានភាពរើសអើង និងអំពីហិង្សាចំពោះបុគ្គល ដោយមានមូលដ្ឋាននៅលើទំនោរផ្លូវភេទ និងអត្តសញ្ញាយេនឌ័ររបស់បុគ្គលទាំងនោះ" (A/HRC/19/41) ។

[2] វាក្យស័ព្ទ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្ដូរភេទនៅក្នុងរបាយការណ៍ទាំងមូល ពោលគឺជារឿយៗ ត្រូវបានបំព្រួញទៅជា LGBT។ វាក្យស័ព្ទទាំងនេះ មានឮសូរលើពិភពលោក ប៉ុន្តែ នៅក្នុងវប្បធម៌នានា វាក្យស័ព្ទផ្សេងទៀត (ក្នុងនោះរួមមាន hijra, meti, lala, skesana,motsoalle, mithli, kuchu, kawein, travesti, muxé, fa'afafine, fakaleiti, hamjensgara និងមនុស្សប្រុសមានឫកពារជាមនុស្សស្រី) នៅតែត្រូវបានប្រើប្រាស់ ដើម្បីពិពណ៌នាអំពីអាកប្បកិរិយា អត្តសញ្ញាណ ឬ ទំនាក់ទំនងភេទដូចគ្នា និងអត្តសញ្ញាណភេទពីរ។ នៅក្នុងចំណុចមួយចំនួនក្នុងអត្ថបទ ការរើសអើងចំពោះមនុស្សភេទពីរ (មនុស្សដែលកើតមកមានលក្ខណៈភេទខុសពីធម្មតា) ក៏ត្រូវបានលើកយកមកដោះស្រាយផងដែរ ។

ដែលមាននៅក្នុងរបាយការណ៍នេះ បានបង្កើតជាមូលដ្ឋានសម្រាប់កិច្ចពិភាក្សាជាក្រុមដែលបានធ្វើឡើងនៅក្រុមប្រឹក្សាសិទ្ធិមនុស្សនៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១២ ជាកិច្ចពិភាក្សាលើកទីមួយហើយដែលស្ថាប័នអន្តររដ្ឋាភិបាលមួយនៃអង្គការសហប្រជាជាតិបានរៀបចំកិច្ចពិភាក្សាវែកញែកជាផ្លូវការលើបញ្ហានេះ។

ដោយបង្ហាញរបាយការណ៍ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនៅពេលចាប់ផ្តើមកិច្ចពិភាក្សាវែកញែកនោះ ឧត្តមស្នងការ ណាវី ភីឡាយ បានជំរុញឲ្យរដ្ឋទាំងឡាយខិតខំអស់ពីសមត្ថភាព ដើម្បីជួយសរសេរ "ជំពូកថ្មី" មួយនៅក្នុងប្រវត្តិសាស្ត្រនៃអង្គការសហប្រជាជាតិ ក្នុងគោលបំណងបញ្ចប់អំពើហិង្សា និង ការរើសអើងចំពោះមនុស្សទាំងអស់ ដោយមិនគិតអំពីទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័ររបស់ពួកគេ ។ ថ្លែងតាមរយៈខ្សែវីដេអូ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន (Ban Ki-moon) បានពិពណ៌នាអំពើហិង្សា និង ការរើសអើងចំពោះមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) ថាជា "សោកនាដកម្មដ៏ធ្ងន់ធ្ងរចំពោះអ្នកពាក់ព័ន្ធ និងភាពសៅហ្មងចំពោះមនសិការរួមរបស់យើង"។ លោកបានកត់សំគាល់ថា វាក៏ជាការរំលោភបំពានលើច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលនៅជាធរមានផងដែរ ។

កាតព្វកិច្ចតាមផ្លូវច្បាប់របស់រដ្ឋក្នុងកិច្ចការពារសិទ្ធិមនុស្សរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) និងមនុស្សភេទពីរត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិដោយឈរលើមូលដ្ឋាននៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងបន្ទាប់មក សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលត្រូវបានព្រមព្រៀង។ មនុស្សទាំងអស់ ដោយមិនគិតអំពីភេទ ទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ ត្រូវបានផ្តល់នូវសិទ្ធិទទួលបានការគាំពារដែលត្រូវបានផ្តល់ជូនដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិក្នុងនោះរួមមានពាក់ព័ន្ធនឹងសិទ្ធិរស់រានមានជីវិត សន្តិសុខផ្ទាល់ខ្លួន និងសិទ្ធិឯកជន សិទ្ធិរួចផុតពីការធ្វើទារុណកម្ម ការចាប់ខ្លួនដោយរំលោភបំពាន និង ការឃុំខ្លួន សិទ្ធិរួចផុតពីការរើសអើង និង សិទ្ធិមានសេរីភាពក្នុងការសម្តែងមតិ ធ្វើសមាគម និង ជួបជុំដោយសន្តិវិធី ។

គោលបំណងនៃសៀវភៅនេះ គឺដើម្បីបង្ហាញអំពីកាតព្វកិច្ចដ៏សំខាន់ដែលរដ្ឋទាំងឡាយមានចំពោះមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) និងពិពណ៌នាអំពីរបៀបដែលយន្តការនៃអង្គការសហប្រជាជាតិបានអនុវត្តច្បាប់អន្តរជាតិនៅក្នុងបរិបទនេះ។ ក្នុងរយៈពេលដប់ប្រាំបី (១៨) ឆ្នាំ កន្លងមកនេះអង្គការសន្ធិសញ្ញាសិទ្ធិមនុស្ស និងយន្តការពិសេសនៃអង្គការសហប្រជាជាតិ បានចងក្រងជាឯកសារនូវការរំលោភបំពានលើសិទ្ធិមនុស្ស របស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) និងបានវិភាគលើការអនុវត្តតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិរបស់រដ្ឋ។ អង្គការសន្ធិសញ្ញាសិទ្ធិមនុស្ស និងយន្តការពិសេសនៃអង្គការសហប្រជាជាតិ ទទួលបានមកជាបន្តបន្ទាប់គ្នានូវភស្តុតាង

ដ៏ច្រើនដែលបង្ហាញអំពីរបៀបដែលបុគ្គលម្នាក់ៗ ត្រូវបានកំណត់ជាគោលដៅ ដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ និង បានចេញសេចក្តីណែនាំជូនរដ្ឋទាំងឡាយ។ ផ្នែកដែលស្ថិតនៅជាបន្តបន្ទាប់នេះ សង្ខេបអំពីលទ្ធផលរកឃើញ និងការណែនាំរបស់អង្គការសន្ធិសញ្ញាសិទ្ធិមនុស្ស និងយន្តការនីតិវិធីពិសេសនៃអង្គការសហប្រជាជាតិ ដើម្បីជួយដល់រដ្ឋឲ្យអនុវត្តវិធានការចាំបាច់ ដើម្បីឆ្លើយតបទៅនឹងកាតព្វកិច្ចផ្នែកសិទ្ធិមនុស្សជាមូលដ្ឋានគ្រឹះរបស់ខ្លួន។ សៀវភៅនេះ ក៏បានរៀបចំឡើង ដើម្បីជួយអ្នកការពារសិទ្ធិមនុស្ស និងអ្នកមានសិទ្ធិជាទូទៅ ដើម្បីអំពាវនាវឲ្យរដ្ឋទាំងឡាយទទួលខុសត្រូវចំពោះការប្រព្រឹត្តល្មើសលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

សៀវភៅនេះ មានប្រាំ (៥) ផ្នែក។ ផ្នែកនីមួយៗបង្ហាញអំពីកាតព្វកិច្ចរបស់រដ្ឋ ច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ និងទស្សនៈរបស់អង្គការសន្ធិសញ្ញាសិទ្ធិមនុស្ស និងយន្តការនីតិវិធីពិសេស។ សម្រង់សេចក្តីពីរបាយការណ៍របស់អង្គការសន្ធិសញ្ញាសិទ្ធិមនុស្ស និង យន្តការនីតិវិធីពិសេស ផ្តល់នូវឧទាហរណ៍ស្តីពីប្រភេទនៃការរំលោភបំពានដែលធ្លាប់ជួបប្រទះ និង ពិពណ៌នាអំពីរូបភាពដ៏ទូលំទូលាយនៃស្ថានភាពរីករាលដាលនៃអំពើហិង្សា និងការរើសអើង។ ផ្នែកនីមួយៗ ធ្វើសេចក្តីសន្និដ្ឋាន ដោយផ្តល់នូវអនុសាសន៍ដល់រដ្ឋទាំងឡាយ ។

កិច្ចគាំពារមនុស្ស ដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ មិនតម្រូវឲ្យមានការបង្កើតសិទ្ធិថ្មី ឬ សិទ្ធិពិសេសសម្រាប់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT)។ ផ្ទុយទៅវិញ វាតម្រូវឲ្យមានការអនុវត្តការធានាដែលអាចអនុវត្តបានជាសកល ចំពោះការមិនរើសអើងលើការទទួលបានសិទ្ធិទាំងអស់។ ការហាមឃាត់ការរើសអើង ដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ មិនកម្រិតត្រឹមច្បាប់សិទ្ធិមនុស្សអន្តរជាតិនោះទេ។ តុលាការនៅក្នុងប្រទេសជាច្រើន បានអះអាងថាការរើសអើងបែបនេះរំលោភបំពានលើបទដ្ឋានធម្មនុញ្ញក្នុងស្រុកក៏ដូចជាច្បាប់អន្តរជាតិ។ បញ្ហានេះក៏ត្រូវបានលើកយកមកពិភាក្សាដោយប្រព័ន្ធសិទ្ធិមនុស្សប្រចាំតំបន់ ជាពិសេសបំផុតនោះ គឺដោយគណៈកម្មាធិការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្ស និងក្រុមប្រឹក្សាអឺរ៉ុប។

សៀវភៅនេះ មានប្រធានបទដែលត្រូវបានរៀបចំតាមបញ្ហា ជាជាងតាមសិទ្ធិជាក់លាក់។ អំពើសកម្ម ឬ អំពើអកម្ម អាចធ្វើឲ្យអន្តរាយដល់សិទ្ធិខុសៗគ្នាជាច្រើន។ វាក៏មិនមានលក្ខណៈទូលំទូលាយដែរ។ ដោយគ្រាន់តែត្រួតពិនិត្យលើការងាររបស់អង្គការសន្ធិសញ្ញា និងយន្តការនីតិវិធីពិសេសនៃអង្គការសហប្រជាជាតិប៉ុណ្ណោះ វាផ្តល់ជាចាំបាច់នូវទិដ្ឋភាពដ៏មានកម្រិតអំពីការរំលោភបំពាន ដែលមនុស្សទទួលរង និងសិទ្ធិជាក់លាក់ដែលពាក់ព័ន្ធ។ ប្រធានបទទាំងប្រាំដែលត្រូវបានបង្ហាញនៅក្នុងសៀវភៅនេះ ជាប្រធានបទដែលធ្លាប់ឃើញញឹកញាប់បំផុតនៅក្នុងការងាររបស់ក្រុមអ្នកជំនាញការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។

បញ្ហាសំខាន់ខ្លាំងមួយចំនួន មិនទាន់ត្រូវបានដោះស្រាយដោយក្រុមអ្នកជំនាញការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅឡើយទេ ។

ទោះបីយ៉ាងណាក៏ដោយគោលការណ៍មិនរើសអើងមានភាពប្រទាក់ក្រឡាគ្នា ហើយកាតព្វកិច្ចរបស់រដ្ឋទាំងឡាយតម្រូវឲ្យមានជាបន្ទាន់។ និយាយជាសាមញ្ញ មនុស្សមិនអាចត្រូវបានរើសអើងចំពោះការទទួលបានសិទ្ធិ ដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រឡើយ។ ដូចដែលឧត្តមស្នងការបានលើកឡើង "គោលការណ៍សកលភាពពុំអនុញ្ញាតឲ្យមានការលើកលែងឡើយ។ សិទ្ធិមនុស្សពិតជាសិទ្ធិដែលមានពីកំណើតរបស់មនុស្សគ្រប់រូប"[3] ។




*លោកអគ្គលេខាអង្គការសហប្រជាជាតិ បាន គីមូន ចូលរួមក្នុងកិច្ចពិភាក្សាលើសមភាពនៃមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) នៅក្នុង ការិយាល័យអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក នាថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១០ ។*

[3] ថ្លែងដោយប្រធានឧត្តមស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ណាវី ភីឡាយ នៅក្នុងសម័យប្រជុំពេញអង្គលើកទី៦៣ នៃមហាសន្និបាតអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ។



## អនុសាសន៍សង្ខេប

# – ជំហានទាំងប្រាំ –

១. **ការពារ** មនុស្សពីអំពើហិង្សាដែលបង្កឡើងដោយការស្អប់ការស្រលាញ់ភេទដូចគ្នា និង ការប្តូរភេទ។ រួមបញ្ចូលទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ ជាចរិតលក្ខណៈដែលត្រូវបានការពារនៅក្នុងច្បាប់ស្តីពីឧក្រិដ្ឋកម្មរើសអើង បង្កើតប្រព័ន្ធប្រកបដោយប្រសិទ្ធភាពដើម្បីកត់ត្រា និង រាយការណ៍អំពីអំពើហិង្សាដែលត្រូវបានជំរុញដោយការស្អប់ខ្ពើម។ ធានាឲ្យមានការស៊ើបអង្កេត និង ការចោទប្រកាន់ចារី ប្រកបដោយប្រសិទ្ធភាព និងសងសំណងដល់ជនរងគ្រោះ ដោយអំពើហិង្សាបែបនេះ។ ច្បាប់ និង គោលនយោបាយស្តីពីសិទ្ធិជ្រកកោនគួរតែទទួលស្គាល់ថា ការធ្វើទុក្ខបុកម្នេញដោយសារតែទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័ររបស់អ្នកណាម្នាក់ អាចជាមូលដ្ឋានដែលមានសុពលភាពសម្រាប់ការសុំទាមទារសិទ្ធិជ្រកកោន។

២. **ទប់ស្កាត់** ការធ្វើទារុណកម្ម និង ប្រព្រឹត្តកម្មដ៏ឃោរឃៅ អមនុស្សធម៌ និងថោកទាបចំពោះមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) ដែលកំពុងជាប់ឃុំដោយហាមឃាត់ និង ផ្តន្ទាទោសអំពើបែបនេះ ព្រមទាំងធានាថា ជនរងគ្រោះត្រូវបានផ្តល់នូវសំណង។ ស៊ើបអង្កេតរាល់អំពើធ្វើទុក្ខទោសរបស់ភ្នាក់ងាររដ្ឋ និង ចាប់បញ្ជូនជនដែលទទួលខុសត្រូវទៅជំនុំជម្រះទោសនៅតុលាការ។ ផ្តល់ការបណ្តុះបណ្តាលសមស្របដល់មន្ត្រី អនុវត្តច្បាប់ និងធានាឲ្យមានការពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាពលើកន្លែងឃុំខ្លួន។

៣. **លុបចោល** ច្បាប់ដែលចាត់ទុកការស្រលាញ់មនុស្សភេទដូចគ្នាជាបទល្មើសព្រហ្មទណ្ឌ រួមទាំងច្បាប់ទាំងអស់ដែលហាមឃាត់អំពើរួមភេទជាលក្ខណៈឯកជនតាមការព្រមព្រៀងរវាងមនុស្សពេញវ័យ ដែលមានភេទដូចគ្នា។ ធានាថាបុគ្គលទាំងឡាយមិនត្រូវបានចាប់ខ្លួន ឬ ឃុំខ្លួន ដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ និង មិនត្រូវឲ្យមានការពិនិត្យរាងកាយដោយគ្មានមូលដ្ឋាននិងមានលក្ខណៈបង្អាប់បង្អោនដែលត្រូវបានរៀបចំឡើងដើម្បីកំណត់អំពីទំនោរផ្លូវភេទ។

៤. **ហាមឃាត់** ការរើសអើងដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ។ អនុម័តច្បាប់ដែលមាន លក្ខណៈទូលំទូលាយដែលរួមបញ្ចូលទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រជាមូលដ្ឋានហាមឃាត់ការរើសអើង។ ជាពិសេសធានាឲ្យមានសិទ្ធិទទួលបានសេវាជាមូលដ្ឋានដែលមិនមានលក្ខណៈរើសអើង ក្នុងនោះរួមមាននៅក្នុងបរិបទការងារ និងការថែទាំសុខភាព។ ផ្តល់ការអប់រំ និងការបណ្តុះបណ្តាល ដើម្បីទប់ស្កាត់ការរើសអើង និងការធ្វើឲ្យមានស្លាកស្នាម ទុយ៌សចំពោះមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) និង មនុស្សមានភេទពីរ ។

៥. **ការពារ** សេរីភាពក្នុងការសម្តែងមតិ ធ្វើសមាគម និងជួបជុំដោយសន្តិវិធីរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ(LGBT) និង មនុស្សភេទពីរ។ ការកម្រិតណាមួយលើសិទ្ធិទាំងនេះត្រូវតែស្របទៅនឹងច្បាប់អន្តរជាតិ និងមិនត្រូវមានលក្ខណៈរើសអើងឡើយ។ ការពារបុគ្គលដែលប្រើប្រាស់សិទ្ធិមានសេរីភាពក្នុង ការសម្តែងមតិ ធ្វើសមាគម និង សេរីភាពក្នុងការជួបជុំរបស់ខ្លួន ពីអំពើហិង្សា និងការបំភិតបំភ័យរបស់បុគ្គលឯកជន។

## *កាតព្វកិច្ចផ្លូវច្បាប់សំខាន់ប្រាំរបស់រដ្ឋចំពោះកិច្ចការពារសិទ្ធិមនុស្សរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT)*

## ១. ការពារបុគ្គលពីអំពើហិង្សាដោយសារការស្អប់ការស្រលាញ់ភេទដូចគ្នា និង ការប្តូរភេទ

*អំពើហិង្សាដែលត្រូវបានជំរុញដោយសារការស្អប់ខ្ពើមចំពោះមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) ដែលជាទូទៅ ត្រូវបានប្រព្រឹត្តដោយតួអង្គមិនមែនរដ្ឋ ដូចជា បុគ្គលឯកជន ក្រុមដែលមានការចាត់តាំង ឬ អង្គការជ្រុលនិយម។ ទោះជាយ៉ាងណាក៏ដោយ ការខកខានរបស់អាជ្ញាធររបស់រដ្ឋក្នុងការស៊ើបអង្កេត និង ផ្តន្ទាទោសអំពើហិង្សាប្រភេទនេះ គឺជាការប្រព្រឹត្តល្មើសនឹងកាតព្វកិច្ចរបស់រដ្ឋដែលត្រូវការពារសិទ្ធិរស់រានមានជីវិត មានសេរីភាពជាមូលដ្ឋាន និងសន្តិសុខផ្ទាល់ខ្លួនរបស់មនុស្សគ្រប់រូប ដូចដែលត្រូវបានធានាដោយមាត្រា ៣ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ៦ និងមាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។*

**សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស**

មាត្រា ៣៖ បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ**

មាត្រា ៦៖ ជនគ្រប់រូបមានសិទ្ធិមានជីវិតជាប់ពីកំណើត។ សិទ្ធិនេះត្រូវបានការពារដោយច្បាប់ ។ គ្មានជនណាម្នាក់ ត្រូវគេប្រហារជីវិតតាមអំពើចិត្តឡើយ។

មាត្រា ៩៖ ជនគ្រប់រូប មានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

**អនុសញ្ញាពាក់ព័ន្ធនឹងឋានៈនៃជនភៀសខ្លួន**

មាត្រា ៣៣ (១) ៖ គ្មានរដ្ឋភាគីនៃអនុសញ្ញាណាមួយ ត្រូវបណ្តេញចេញ ឬ បញ្ជូនត្រឡប់វិញ (បង្ខំឲ្យវិលត្រឡប់វិញ) នូវជនភៀសខ្លួន ទោះតាមលក្ខណៈបែបណាក៏ដោយ ឲ្យទៅកាន់ព្រំដែននៃទឹកដីដែលជីវិត ឬ សេរីភាពរបស់គេ រងការគំរាមកំហែង ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ សមាជិកភាពនៃក្រុមសង្គមពិសេសណាមួយ ឬ ទស្សនៈនយោបាយ ។

## គោលជំហររបស់យន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ(LGBT) ប្រឈមមុខនឹងគ្រោះថ្នាក់ពិសេសណាមួយនៃអំពើហិង្សាដែលត្រូវបានកំណត់ជាគោលដៅ បង្កឡើងដោយសារស្មាដៃរបស់តួអង្គឯកជន។ អំពើហិង្សាដែលបង្កឡើងដោយការស្អប់មនុស្សស្រលាញ់ភេទដូចគ្នា និងការស្អប់មនុស្សប្តូរភេទ ត្រូវបានកត់ត្រាទុកនៅគ្រប់តំបន់ទាំងអស់។ អំពើហិង្សាបែបនេះអាចបង្កឡើងទៅលើរាងកាយ (ក្នុងនោះរួមមាន ការសម្លាប់ ការវាយដំ ការចាប់ពង្រត់ ការរំលោភសេពសន្ថវៈ និងការបំពានផ្លូវភេទ) ឬ ទៅលើចិត្តសាស្រ្ត (ក្នុងនោះរួមមានការគំរាមកំហែង ការបង្ខិតបង្ខំ និងការដកហូតសេរីភាពដោយបំពាន)។[4] ការវាយប្រហារទាំងនេះ ជាទម្រង់នៃអំពើហិង្សាយេនឌ័រ ដែលត្រូវបានជំរុញដោយបំណងប្រាថ្នាចង់ផ្តន្ទាទោសអ្នកដែលត្រូវបានយល់ឃើញថាបំពានលើបទដ្ឋានយេនឌ័រ ។

### ការធ្វើឃាតដែលត្រូវបានកំណត់ជាគោលដៅ

*ការផ្តន្ទាទោសរបស់រដ្ឋទាំងឡាយពង្រឹងបុរេនិច្ឆ័យដែលមានស្រាប់ និងចាត់ទុកជាត្រឹមត្រូវតាមច្បាប់នូវអំពើហិង្សារបស់សហគមន៍ និងអំពើឃោរឃៅរបស់នគរបាលចំពោះបុគ្គលរងគ្រោះ ។*

កាតព្វកិច្ចរបស់រដ្ឋក្នុងកិច្ចការពារអាយុជីវិត តម្រូវឲ្យរដ្ឋយកចិត្តទុកដាក់ក្នុងការទប់ស្កាត់ការផ្តន្ទាទោស និង ការផ្តល់សំណងចំពោះការដកហូតសិទ្ធិរស់រានមានជីវិតដោយបុគ្គលឯកជន ក្នុងនោះរួមមានករណីដែលជនរងគ្រោះ ត្រូវបានកំណត់ជាគោលដៅដោយសារទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ របស់គេ។[5] រដ្ឋទាំងឡាយមានកាតព្វកិច្ចដូចមាន ចែងក្នុងច្បាប់អន្តរជាតិ ក្នុងការទប់ស្កាត់ការប្រហារជីវិតក្រៅប្រព័ន្ធតុលាការ ស៊ើបអង្កេតលើការសម្លាប់នេះដូចដែលបានកើតមានឡើងនិងចាប់បញ្ជូនអ្នកដែលទទួលខុសត្រូវទៅជំនុំជម្រះទោសនៅតុលាការ។ មហាសន្និបាតអង្គការសហប្រជាជាតិ តាមរយៈសេចក្តីសម្រេចមួយចំនួនរបស់ខ្លួនបានអំពាវនាវដល់រដ្ឋទាំងឡាយ"ធានាឲ្យមានកិច្ចការពារសិទ្ធិរស់រានមានជីវិតរបស់ជនគ្រប់រូបដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន" និង ស៊ើបអង្កេតដោយរហ័សទាន់ពេលវេលា និង ហ្មត់ចត់លើគ្រប់ការសម្លាប់ទាំងអស់ក្នុងនោះរួមមានការសម្លាប់ដោយសារទំនោរផ្លូវភេទរបស់ជនរងគ្រោះផងដែរ។[6]ការខកខានណាមួយរបស់រដ្ឋក្នុងការ មិនយកចិត្តទុកដាក់នៅក្នុងរឿងនេះ គឺជាការបំពានកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងនៅក្នុងច្បាប់អន្តរជាតិ ។ ឃាតកម្មលើបុគ្គលដែលត្រូវបានកំណត់ជាគោលដៅ ដោយសារតែទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័ររបស់ពួកគេត្រូវបានបញ្ចូលយ៉ាងល្អត្រឹមត្រូវទៅក្នុងរបាយការណ៍របស់អង្គការសន្ធិសញ្ញាសិទ្ធិមនុស្ស និង

---

[4] មាត្រា ២ នៃសេចក្តីប្រកាសស្តីពីការលុបបំបាត់ចោលអំពើហិង្សាចំពោះស្រ្តី កត់សំគាល់ថា អំពើហិង្សាចំពោះស្រ្តី រួមមាន អំពើហិង្សានៅក្នុងគ្រួសារ និងសហគមន៍ និងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬ ផ្លូវចិត្ត ដែលត្រូវបានប្រព្រឹត្ត និងលើកលែងទោសឲ្យដោយរដ្ឋ ទោះបីជាវាកើតនៅទីកន្លែងណាក៏ដោយ ។

5 សេចក្តីពន្យល់ទូទៅលេខ ៦ (ស្តីពីសិទ្ធិរស់រានមានជីវិត) និង លេខ ៣១ (ស្តីពីប្រភេទនៃកាតព្វកិច្ចតាមផ្លូវច្បាប់ទូទៅដែលត្រូវបានកម្រិតទៅលើរដ្ឋភាគីទាំងឡាយនៃកតិកាសញ្ញានេះ) របស់គណៈកម្មាធិការសិទ្ធិមនុស្ស ត្រង់កថាខណ្ឌទី ៨ ។

6 កថាខណ្ឌទី ៦ នៃសេចក្តីសម្រេចលេខ 57/214 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០២ កថាខណ្ឌទី ៥ (ខ) នៃសេចក្តីសម្រេចលេខ 61/173 ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៦ និងកថាខណ្ឌទី ៦ (ខ) នៃសេចក្តីសម្រេចលេខ 65/208 ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១០ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ។

យន្តការនីតិវិធីពិសេស។[7] ឧទាហរណ៍ ក្នុងករណីរបស់ប្រទេសអែលសាវ៉ាឌ័រ គណៈកម្មាធិការសិទ្ធិមនុស្ស បានបង្ហាញពី:

*កង្វល់អំពីឧប្បត្តិហេតុដែលមនុស្សត្រូវបានវាយប្រហារ ឬ សម្លាប់ ដោយសារតែទំនោរផ្លូវភេទរបស់ពួកគេ (មាត្រា ៩) និង អំពីការស៊ើបអង្កេតមួយចំនួនតូចលើអំពើខុសច្បាប់បែបនេះ ...។ រដ្ឋភាគីគួរផ្តល់កិច្ចការពារប្រកបដោយប្រសិទ្ធភាពចំពោះអំពើហិង្សានិងការរើសអើងដោយទំនោរផ្លូវភេទ ។*[8]

ចាប់តាំងពីឆ្នាំ ១៩៩៩ មក អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅប្រព័ន្ធតុលាការដោយមិនគោរពតាមនីតិវិធីត្រឹមត្រូវ ឬ ដោយបំពាន បានសុំឲ្យមានការយកចិត្តទុកដាក់ដោយទៀងទាត់ចំពោះជនដែលទទួលការគំរាមកំហែងដល់អាយុជីវិត ឬ ត្រូវបានធ្វើឃាត ដោយសារតែទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ។[9] មានករណីជាច្រើនពាក់ព័ន្ធនឹងអ្នកប្តូរភេទ។[10] តាមរយៈការបង្ហាញរបាយការណ៍ឆ្នាំ ២០០៦ របស់គាត់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស អ្នករាយការណ៍ពិសេសបានថ្លែងថា:

*បញ្ហាមួយដែលកន្លងមកបានធ្វើឲ្យមានភាពចម្រូងចម្រាស់មួយទាក់ទងនឹងអាណត្តិនេះ មានជាប់ពាក់ព័ន្ធនឹងស្ថានភាពរបស់បុគ្គលដែលជាមនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ ឬ មនុស្សប្តូរភេទបន្ទាប់ពីបានវះកាត់។ ប៉ុន្តែដោយផ្អែក*

---

[7]**កម្រងឯកសារស្តីពីការប្រហារជីវិតក្រៅតុលាការលើស្រីស្រលាញ់ភេទដូចគ្នា ប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ (LGBT)៖** សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសប៉ូឡូញ (CCPR/CO/82/POL) ត្រង់កថាខណ្ឌទី ១៨ និងសម្រាប់ប្រទេសអែលសាវ៉ាឌ័រ (CCPR/CO/78/SLV) ត្រង់កថាណ្ឌទី ១៦ ។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ឬ ដោយបំពាន ក្នុងដំណើរបេសកកម្មរបស់គាត់ទៅកាន់ប្រទេសម៉ិកស៊ិកូ (E/CN.4/2000/3/Add.3) ត្រង់កថាខណ្ឌទី ៩១-៩២ ។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រី ក្នុងដំណើរបេសកកម្មរបស់គាត់ទៅកាន់ប្រទេសអែលសាវ៉ាឌ័រ (A/HRC/17/26/Add.2) ត្រង់កថាខណ្ឌទី ២៨ ។របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្សក្នុងដំណើរបេសកកម្មរបស់គាត់ទៅកាន់ប្រទេសកូឡុំប៊ី (A/HRC/13/22/Add.3) ត្រង់កថាខណ្ឌទី ៥០ ។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ឬ ដោយបំពាន (A/HRC/14/24/Add.2)ត្រង់កថាខណ្ឌទី ៧៤ ។ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីនៅអាព្រិចខាងត្បូង (CEDAW/C/ZAF/CO/4) ត្រង់កថាខណ្ឌទី ៣៩ ។

[8]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសអែលសាវ៉ាឌ័រ (CCPR/CO/78/SLV) ត្រង់កថាខណ្ឌទី ១៦ ។

[9]សូមមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ឬ ដោយបំពាន៖ E/CN.4/1999/39 ត្រង់កថាខណ្ឌទី៧៦ E/CN.4/1999/39 ត្រង់កថាខណ្ឌទី ៧៦ E/CN.4/2000/3 ត្រង់កថាខណ្ឌទី៥៤ E/CN.4/2001/9 ត្រង់កថាខណ្ឌទី ៤៨ E/CN.4/2002/74 ត្រង់កថាខណ្ឌទី ៦២ A/57/138 ត្រង់កថាខណ្ឌទី៣៨ E/CN.4/2003/3 ត្រង់កថាខណ្ឌទី៦៦ A/59/319 ត្រង់កថាខណ្ឌទី៦០ A/HRC/4/20 និង Add.1,A/HRC/4/29/Add.2, A/HRC/11/2/Add.7, A/HRC/14/24/Add.2 និងA/HRC/17/28/Add.1។

[10]**ការសម្លាប់អ្នកប្តូរភេទ៖** របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ឬ ដោយបំពាន: E/CN.4/2002/3 ត្រង់កថាខណ្ឌទី ៥៤ ("អ្នករកស៊ីផ្លូវភេទជាប្រុសចរិតស្រី" នៅប្រទេសប្រេស៊ីល) E/CN.4/2001/9 ត្រង់កថាខណ្ឌទី ៤៩ មនុស្សប្រុសចរិតស្រីដែលត្រូវបានបាញ់ និងសម្លាប់នៅក្នុងប្រទេសអែលសាវ៉ាឌ័រ) E/CN.4/2003/3/Add.2 ត្រង់កថាខណ្ឌទី ៦៨ (អ្នករកស៊ីផ្លូវភេទជាអ្នកប្តូរភេទ ដែលត្រូវបានសម្លាប់នៅខាងក្រោយមហាវិហារគ្រឹះសាសនា San Pedro Sula) E/CN.4/2003/3 ត្រង់កថាខណ្ឌទី ៦៦ (ការប្រហារជីវិតអ្នកប្តូរភេទចំនួនបី (៣) នាក់ នៅរដ្ឋប៊ូលីវ៉ារៀនវេណេស៊ូអ៊ីឡា ដោយគ្មានការផ្តួចផ្តើមស៊ើបអង្កេតពីសំណាក់រដ្ឋាភិបាល) ។

*ទៅលើព័ត៌មានដែលខ្ញុំបានទទួលវានៅតែលំបាកនឹកស្មានអំពីបញ្ហាដែលគួរតែពុំសូវមានភាពចម្រូងចម្រាសចំពោះអាណត្តិនេះ។*

*សំខាន់បំផុត សមាជិកក្រុមនេះបានជម្រាបដល់ខ្ញុំអំពីបរិបទពីរ។ ទីមួយ ជាប់ពាក់ព័ន្ធនឹងអ្នកដែលត្រូវបានសម្លាប់ដោយសារហេតុពិតនៃអត្តសញ្ញាណភេទរបស់ពួកគេ ដែលជារឿយៗ ធ្វើឡើងដោយភ្នាក់ងាររបស់រដ្ឋ ហើយការសម្លាប់របស់ពួកគេមិនបានផ្តន្ទាទោសទេ។ តាមពិត ការចោទប្រកាន់មិនធ្លាប់ត្រូវបានធ្វើឡើងទេ។ ប៉ុន្តែពួកគេគ្រាន់តែជាមនុស្សប្រុសស្រលាញ់ភេទដូចគ្នាប៉ុណ្ណោះ។ ផ្ទុយទៅវិញ បរិបទទីពីរជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់យ៉ាងតឹងរ៉ឹង ដោយមិនធ្វើឡើងចំពោះឃាតករនោះទេ ប៉ុន្តែបែរជាធ្វើឡើងចំពោះអ្នកមានទំនាក់ទំនងផ្លូវភេទដោយមានការព្រមព្រៀងជាលក្ខណៈឯកជនទៅវិញ។ ខ្ញុំបន្តទទួលរបាយការណ៍ស្តីពីបុគ្គលទាំងនេះដែលត្រូវបានកាត់ទោសប្រហារជីវិតដោយវាយនឹងដុំថ្ម។ បាតុភូតទាំងពីរនេះ ជាប់ពាក់ព័ន្ធនឹងការបដិសេធជាមូលដ្ឋានគ្រឹះ នូវសិទ្ធិទាំងអស់ដែលតំណាងដោយបទដ្ឋានសិទ្ធិមនុស្ស។ ការអនុវត្តបែបនេះ គួរតែជាបញ្ហាកង្វល់ដ៏ជ្រាលជ្រៅជាជាងប្រភពចម្រូងចម្រាស ។[11]*

តាមរយៈរបាយការណ៍ឆ្នាំ ២០០៧ របស់ខ្លួន ក្នុងដំណើរបេសកកម្មទៅកាន់ប្រទេសហ្គាតេម៉ាឡា អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅប្រព័ន្ធតុលាការដោយមិនគោរពតាមនីតិវិធី ឬ ដោយបំពានបានថ្លែងថា:

*ដោយមិនគិតអំពីទំហំដែលអាចពាក់ព័ន្ធដោយភ្នាក់ងាររបស់រដ្ឋ មានភស្តុតាងបង្ហាញថា រដ្ឋមានការទទួលខុសត្រូវដូចមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិចំពោះការសម្លាប់ដែល មានការរីករាលដាលលើ.........មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្តូរភេទ និង មនុស្សប្តូរភេទបន្ទាប់ពីបានវះកាត់.........។ មាននិទ្ទណ្ឌភាពចំពោះឃាតកម្ម ដែលត្រូវបានប្រព្រឹត្ត ដោយសារការស្អប់ចំពោះជនដែលកំណត់ថាជា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្តូរភេទ និង មនុស្សប្តូរភេទបន្ទាប់ ពីបានវះកាត់។ ព័ត៌មានដែលគួរឲ្យជឿបានបង្ហាញថា មានឃាតកម្មបែបនេះយ៉ាងតិច ៣៥ ករណី នៅចន្លោះឆ្នាំ ១៩៩៥ និង ឆ្នាំ ២០០៦។ ដោយពិចារណាទៅលើកង្វះទិន្នន័យស្ថិតិផ្លូវការ និងភាពលំបាកក្នុងការបង្ហាញការពិតហើយ ប្រសិនបើមិនមានភាពយល់ដឹងរបស់សមាជិកគ្រួសារជនរងគ្រោះនោះទេ មានមូលហេតុដែលនាំឲ្យជឿថា ចំនួនជាក់ស្តែងពិតជាខ្ពស់ជាងច្រើន ។[12]*

---

[11]ការបង្ហាញដោយផ្ទាល់មាត់នូវរបាយការណ៍ E/CN.4/2006/53 ដោយអ្នករាយការណ៍ពិសេស ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៦ ដែលអាចរកបាននៅក្នុងវិបសាយ: www.un.org/webcast/unhrc/archive.asp?go=060919 (បើកនៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១២) ។

[12]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ឬ ដោយបំពាន ក្នុងដំណើរបេសកកម្មរបស់គាត់ទៅកាន់ប្រទេសហ្គាតេម៉ាឡា (A/HRC/4/20/Add.2) ត្រង់កថាខណ្ឌទី ១២ និងទី ៣២ ។

អ្នករាយការណ៍ពិសេស បានលើកទឹកចិត្តដល់:

*រដ្ឋាភិបាលឲ្យបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីការពារសន្តិសុខ និង សិទ្ធិរស់រានមានជីវិតរបស់បុគ្គលស្ថិតនៅក្នុងក្រុមជនភាគតិចផ្នែកផ្លូវភេទ។ អំពើឃាតកម្ម និង ការគំរាមកំហែងដល់អាយុជីវិតគួរតែត្រូវបានស៊ើបអង្កេត ដោយរហ័សទាន់ពេលវេលា និងហ្មត់ចត់ ដោយមិនគិតអំពីទំនោរផ្លូវភេទរបស់ជនរងគ្រោះ។ វិធានការគួរតែរួមបញ្ចូលគោលនយោបាយ និង កម្មវិធីដែលរៀបចំឡើង ក្នុងគោលដៅលុបបំបាត់ចោលការស្អប់ និងបុរេនិច្ឆ័យ ចំពោះការស្រលាញ់មនុស្សភេទដូចគ្នា និងធ្វើឲ្យមន្ត្រីសាធារណៈ និងសាធារណជនទូទៅ មានការយល់ដឹងកាន់តែច្រើនឡើងអំពីបទល្មើស និងអំពើហិង្សាដែលត្រូវបានប្រព្រឹត្តលើសមាជិកក្រុមជនភាគតិចផ្នែកផ្លូវភេទ។ អ្នករាយការណ៍ពិសេសជឿជាក់ថា ការមិនចាត់ទុកទំនោរផ្លូវភេទជាបទល្មើសព្រហ្មទណ្ឌនឹងរួមចំណែកយ៉ាងច្រើនក្នុងការលុបបំបាត់ចោលការចាត់ទុកជាទុយ៌សចំពោះ សមាជិកក្រុមជនភាគតិចផ្នែកផ្លូវភេទ និង ទប់ស្កាត់និទ្ទណ្ឌភាពចំពោះការរំលោភសិទ្ធិមនុស្សចំពោះជនទាំងនេះ ។[13]*

មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) ក៏ស្ថិតនៅក្នុងចំណោមជនរងគ្រោះដោយសារអ្វីដែលហៅថា "ការធ្វើឃាតដើម្បីកិត្តិយស" ដែលត្រូវបានធ្វើឡើងចំពោះអ្នកដែលសមាជិកគ្រួសារ ឬ សហគមន៍ មើលឃើញថា បាននាំភាពអាម៉ាស់ ឬ ភាពអាប់អោន កិត្តិយស មកដល់គ្រួសារ ដែលជារឿយៗ ដោយសារការបំពានបទដ្ឋានយេនឌ័រ ឬ អាកប្បកិរិយាផ្លូវភេទ ក្នុងនោះរួមមានសកម្មភាពផ្លូវភេទរវាងមនុស្សដែលមានភេទដូចគ្នាជាក់ស្តែង ឬ តាមការសន្មត។ ទោះបីជាស្ត្រីជាទូទៅ គឺជាគោលដៅនៃការផ្តន្ទាទោសប្រភេទនេះក៏ដោយក៏ការវាយប្រហារទាំងនេះអាចធ្វើឡើងលើគ្រប់បុគ្គលទាំងអស់ ទោះបីជាបុគ្គលនោះមានភេទអ្វីក៏ដោយ។[14]

[13] របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ឬ ដោយបំពាន(E/CN.4/2000/3) ត្រង់កថាខណ្ឌទី ១១៦ ។

[14] សូមមើលរបាយការណ៍របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីអំពើហិង្សាចំពោះស្ត្រី (A/61/122/Add.1) ត្រង់កថាខណ្ឌទី ១២៤។ របាយ-ការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រីៈ E/CN.4/2002/83 ត្រង់កថាខណ្ឌទី ២៧-២៨ A/HRC/4/34/Add.2 ត្រង់កថាខណ្ឌទី ១៩ និងA/HRC/4/34/Add.3 ត្រង់កថាខណ្ឌទី ៣៩ ។

## ការវាយប្រហារដែលមិនគ្រោះថ្នាក់ដល់អាយុជីវិត

ក្រៅពីការធ្វើជាគោលដៅនៃអំពើឃាតកម្ម មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) ជារឿយៗ គឺជាជនរងគ្រោះដោយទម្រង់ផ្សេងទៀតនៃអំពើហិង្សា ដោយតួអង្គមិនមែនរដ្ឋ។[15] ការចោទប្រកាន់មនុស្សស្រីស្រលាញ់ភេទដូចគ្នាដែលត្រូវបានបានវាយប្រហារ រំលោភសេពសន្ថវៈ ធ្វើឲ្យមានផ្ទៃពោះដោយបង្ខំ ហើយបើមិនដូច្នោះទេ ត្រូវបានផ្តន្ទាទោស ដោយសារតែទំនោរផ្លូវភេទទទួលបានពីតំបន់ជាច្រើន។[16] គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រី បានសម្តែងចេញនូវកង្វល់ដ៏ខ្លាំងក្លាអំពីបទល្មើសផ្លូវភេទដូចដែលបានរាយការណ៍ ដែលត្រូវបានប្រព្រឹត្តចំពោះស្ត្រីដោយសារតែទំនោរផ្លូវភេទរបស់ពួកគេ។[17]អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រី បានរាយការណ៍អំពីឧប្បត្តិហេតុដែលត្រូវបានចោទប្រកាន់នៃការរំលោភសេពសន្ថវៈជាក្រុម អំពើហិង្សាក្នុងគ្រួសារ និងអំពើឃាតកម្ម ដែលត្រូវបានទទួលរងដោយសារមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សស្រីស្រលាញ់ភេទទាំងពីរ និង មនុស្សស្រីប្តូរភេទ នៅប្រទេសអែលសាវ៉ាឌ័រ ប្រទេសគីជីស្ថាន និងប្រទេសអាហ្វ្រិកខាងត្បូង[18]ដែលអ្នករាយការណ៍ពិសេសបានកត់សំគាល់ថា"មនុស្សស្រីស្រលាញ់ភេទដូចគ្នាប្រឈមមុខនឹងហានិភ័យខ្ពស់ដែលត្រូវក្លាយជាជនរងគ្រោះដោយអំពើហិង្សា ជាពិសេស អំពើរំលោភសេពសន្ថវៈ ដោយសារតែបុរេនិច្ឆ័យ និង ទេវកថាដែលត្រូវបានប្រកាន់យកដ៏ទូលំទូលាយ" ក្នុងនោះរួមមាន "ឧទាហរណ៍ៈ ដែលអះអាងថា មនុស្សស្រីស្រលាញ់ភេទដូចគ្នា នឹងផ្លាស់ប្តូរទំនោរផ្លូវភេទរបស់ពួកគេ ប្រសិនបើពួកគេត្រូវបានរំលោភសេពសន្ថវៈដោយបុរស"។[19] នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួនស្តីពីប្រទេសអាហ្វ្រិកខាងត្បូង គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រី បានថ្លែងថាៈ

---

[15]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រីក្នុងដំណើរបេសកកម្មរបស់ខ្លួនទៅកាន់ប្រទេសគើជីស្ថាន A/HRC/14/22/Add.2 ត្រង់កថាខណ្ឌទី ៣៧-៣៨ (ការរៀបរាប់អំពីកម្រិតខ្ពស់នៃអំពើហិង្សាចំពោះស្រីស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ ក្នុងនោះរួមមាន ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ) ។

[16]សូមមើល A/HRC/17/26 ត្រង់កថាខណ្ឌទី ៤០។ ចូរមើលផងដែរនូវ A/HRC/14/22/Add.2 ត្រងកថាខណ្ឌទី ២៣ A/HRC/17/26/Add.1 ត្រង់កថាខណ្ឌទី២០៤-២១៣ E/CN.4/2002/83 ត្រង់កថាខណ្ឌទី ១០២ A/HRC/4/34/Add.3 ត្រង់កថាខណ្ឌទី៣៤ និងសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីសម្រាប់សហព័ន្ធរុស្ស៊ី (C/USR/CO/7) ត្រង់កថាខណ្ឌទី ៤០-៤១ ។

[17]សេចក្តីសង្កេតសន្និដ្ឋានស្តីពីប្រទេសអាហ្វ្រិកខាងត្បូង (CEDAW/C/ZAF/CO/4) ត្រង់កថាខណ្ឌ ៣៩-៤០ ។

[18]សូមមើល A/HRC/14/22/Add.2 ត្រង់កថាខណ្ឌទី ៣៧-៣៨ និងA/HRC/17/26/Add.2 ត្រង់កថាខណ្ឌ២៨-២៩ ។

[19]A/HRC/4/34/Add.1 ត្រង់កថាខណ្ឌទី ៦៣២-៦៣៣ ។ ទាំងគណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រី និងអ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រី បានដោះស្រាយអ្វីដែលហៅថា បញ្ហាអំពើរំលោភសេពសន្ថវៈ ក្នុងបំណង"ព្យាបាល" ឬ "កែប្រែ" ដែលត្រូវបានប្រព្រឹត្តដោយបុរសដែលអះអាងថា ចេតនារបស់ពួកគេ គឺដើម្បី "ព្យាបាល" ស្ត្រី ស្រលាញ់ភេទដូចគ្នារបស់ពួកគេ ។ សូមមើល ឧទាហរណ៍ៈ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការ សម្រាប់ប្រទេសអាហ្វ្រិកខាងត្បូង (CEDAW/C/ZAF/CO/4) ត្រង់កថាខណ្ឌទី ៣៩ និងរបាយការណ៍របស់អ្នករាយការណ៍ពិសេសក្នុងដំណើរបេសកកម្មរបស់គាត់ទៅកាន់ប្រទេសគើជីស្ថាន (A/HRC/14/22/Add.2) ត្រង់កថាខណ្ឌទី ៣៨ ។



*គណៈកម្មាធិការសម្តែងចេញនូវកង្វល់ដ៏ខ្លាំងក្លាអំពីបទល្មើសផ្លូវភេទនិងអំពើឃាតកម្មដូចដែលបានរាយការណ៍ ដែលត្រូវបានប្រព្រឹត្តចំពោះស្ត្រី ដោយសារតែទំនោរផ្លូវភេទរបស់ពួកគេ។ គណៈកម្មាធិការក៏សម្តែងចេញនូវកង្វល់ដ៏ខ្លាំងក្លាអំពីការអនុវត្តនូវអ្វីដែលហៅថា "ការរំលោភសេពសន្ថវៈដើម្បីកែប្រែ" លើមនុស្សស្រីស្រលាញ់ភេទដូចគ្នា។*[20]

ដូចការធ្វើឃាតក្រៅតុលាការដែរ ការរើសអើងដែលមានលក្ខណៈជាផ្លូវការ អាចចាត់ទុកជាត្រឹមត្រូវតាមច្បាប់នូវអំពើហិង្សាបែបនេះ និង បង្កើតឲ្យមានបរិយាកាសដែលចារីពុំត្រូវបានដាក់ទោសទៅវិញ។ ដូចអ្នករាយការណ៍ពិសេសទទួលបន្ទុកផ្នែកសុខភាព បានកត់សំគាល់ "ទោសទណ្ឌដែលត្រូវបានដាក់ដោយរដ្ឋទាំងឡាយ ពង្រឹងបុរេនិច្ឆ័យដែលមានស្រាប់ និងចាត់ទុកជាត្រឹមត្រូវតាមច្បាប់នូវអំពើហិង្សារបស់សហគមន៍ និង អំពើឃោរឃៅរបស់នគរបាលដែលមានចំពោះបុគ្គលរងគ្រោះ។[21] ដូចនេះ នៅក្នុងសេចក្តីសន្និដ្ឋានរបស់

[20]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីសម្រាប់ប្រទេសអាហ្វ្រិកខាងត្បូង (CEDAW/C/ZAF/CO/4) ត្រង់កថាខណ្ឌទី ៣៩-៤០ ។

[21]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិរបស់មនុស្សរាល់រូបក្នុងការទទួលបានសុខភាពផ្លូវកាយ និង ផ្លូវចិត្ត តាមស្តង់ដាដែលអាចសម្រេចបានខ្ពស់បំផុត (A/HRC/14/20) ត្រង់កថាខណ្ឌទី ២០។

ខ្លួនសម្រាប់តូហ្គោ គណៈកម្មាធិការសិទ្ធិមនុស្សបានផ្តល់អនុសាសន៍លើការមិនចាត់ទុកទំនាក់ទំនងផ្លូវភេទតាមការព្រមព្រៀងរបស់មនុស្សពេញវ័យដែលមានភេទដូចគ្នា។ គណៈកម្មាធិការនេះថ្លែងបន្ថែមទៀតថារដ្ឋគួរតែៈ

> *ចាត់វិធានការចាំបាច់ដើម្បីបញ្ចប់បុរេនិច្ឆ័យ និង ការធ្វើឲ្យទុយ៌សសង្គម នៃអំពើមនុស្សស្រលាញ់មនុស្សភេទដូចគ្នា និងបញ្ជូនសារច្បាស់លាស់ដែលមិនបណ្តោយឲ្យមានទម្រង់ណាមួយនៃការយាយីរំខាន ការរើសអើង ឬ អំពើហិង្សាចំពោះមនុស្ស ដោយផ្អែកលើទំនោរផ្លូវភេទរបស់ពួកគេ ។*[22]

រដ្ឋទាំងឡាយមានកាតព្វកិច្ចអនុម័តច្បាប់ដើម្បីហាមឃាត់ការរើសអើងរបស់ភាគីឯកជនក្នុងនោះរួមមានតាមរយៈច្បាប់ស្តីពីឧក្រិដ្ឋកម្មរើសអើង។ ការស្អប់មនុស្សស្រលាញ់មនុស្សភេទដូចគ្នានិងការស្អប់មនុស្សប្តូរភេទ។[23] ក្នុងករណីនៃរដ្ឋចាម៉ៃកាដែលគណៈកម្មាធិការបានទទួលរបាយការណ៍ស្តីពីទំនុកច្រៀងដែលញុះញង់ ឲ្យមានអំពើហិង្សាប្រឆាំងនឹងមនុស្សប្រុសស្រលាញ់ភេទដូចគ្នា គណៈកម្មាធិការបានថ្លែងថា រដ្ឋជាភាគី "គួរតែធានាថាបុគ្គលទាំងឡាយ ដែលញុះញង់ឲ្យមាន អំពើហិង្សាចំពោះ មនុស្សស្រលាញ់មនុស្សភេទដូចគ្នាត្រូវបានស៊ើបអង្កេតនាំយកមកកាត់ទោស និង ដាក់ទណ្ឌកម្មដោយសមស្រប"។[24] ក្នុងករណីនៃប្រទេសប៉ូឡូញ គណៈកម្មាធិការសិទ្ធិមនុស្សបានកត់សំគាល់ ដោយមានកង្វល់លើការកើនឡើងដ៏ខ្លាំង នៃការសម្តែងចេញឲ្យឃើញនូវការនិយាយវាយប្រហារ និង ភាពមិនចេះអត់ឱនដោយសារស្អប់ចំពោះមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ" ។

*តម្រូវឲ្យរដ្ឋទាំងឡាយ ការពារ "មនុស្សគ្រប់រូបដោយមិនគិតអំពី...ទំនោរផ្លូវភេទ (ឬ) អត្តសញ្ញាណយេនឌ័រ ពីការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មដ៏ឃោរឃៅ អមនុស្សធម៌ និងថោកទាប ឬ ការដាក់ទណ្ឌកម្ម" ។ គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម នៃអង្គការសហប្រជាជាតិ*

*រដ្ឋជាភាគីគួរតែធានាថា គ្រប់ការចោទប្រកាន់ទាំងអស់លើការវាយប្រហារ និង ការគំរាមកំហែងចំពោះបុគ្គលទាំងឡាយដែលត្រូវបានកំណត់ជាគោលដៅ ដោយសារតែទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេន*

---

[22]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់តូហ្គោ (CCPR/C/TGO/CO/4) ត្រង់កថាខណ្ឌទី ១៤ ។

[23]**ច្បាប់ស្តីពីឧក្រិដ្ឋកម្មរើសអើង៖** សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់សហរដ្ឋអាមេរិក (CCPR/C/USA/CO/3) ត្រង់កថាខណ្ឌទី ២៥ អ៊ូបេគីស្ថាន (CCPR/C/UZB/CO/3) ត្រង់កថាខណ្ឌទី ២២ ។ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មសម្រាប់ប្រទេសប៉ូឡូញ (CAT/C/POL/CO/4) ត្រង់កថាខណ្ឌទី ១៩ ប្រទេសម៉ុងហ្គោលី (CAT/C/MNG/CO/1) ត្រង់កថាខណ្ឌទី២៥ សាធារណរដ្ឋម៉ូលដូវ៉ា (CAT/C/MDA/CO/2) ត្រង់កថាខណ្ឌទី២៧។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រី ក្នុងដំណើរបេសកកម្មរបស់គាត់ទៅកាន់ប្រទេសគើជីស្ថាន (A/HRC/14/22/Add.2) ត្រង់កថាខណ្ឌទី ៩២។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រី ក្នុងដំណើរបេសកកម្មរបស់គាត់ទៅកាន់ប្រទេសអែលសាវ៉ាឌ័រ (A/HRC/17/26) ត្រង់កថាខណ្ឌ ២៨-២៩ និង ៧៧។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សរបស់ពលករចំណាកស្រុកក្នុងដំណើរបេសកកម្មរបស់គាត់ទៅកាន់ប្រទេសអាហ្វ្រិកខាងត្បូង (A/HRC/17/33/Add.4) ត្រង់កថាខណ្ឌទី ៧៧ (ក) ("ធ្វើឲ្យអំពើហិង្សាចំពោះបុគ្គលទាំងឡាយ ឬ ទ្រព្យសម្បត្តិ ដោយឈរលើមូលដ្ឋាននៃ ជនជាតិ សញ្ជាតិ សាសនា ជាតិពន្ធុ ទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ ('ឧក្រិដ្ឋកម្មរើសអើង') របស់មនុស្ស ធ្លាក់ចូលក្នុងស្ថានភាពធ្ងន់ធ្ងរ ឡើងៗ") ។

[24]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់រដ្ឋចាម៉ៃកា (CCPR/C/JAM/CO/3) ត្រង់កថាខណ្ឌទី ៨ ។

*ឪរត្រូវបានស៊ើបអង្កេតដោយហ្មត់ចត់។ រដ្ឋជាភាគី ក៏គួរតែ...ធ្វើវិសោធនកម្មលើក្រមព្រហ្មទណ្ឌ ដើម្បីកំណត់និយមន័យអំពីការនិយាយវាយប្រហារ និង ឧក្រិដ្ឋកម្មដោយសារការរើសអើង ដោយមានមូលដ្ឋាននៅលើទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ ក្នុងចំណោមប្រភេទបទល្មើសដែលអាចដាក់ទោសទណ្ឌបាន និង ពង្រឹងសកម្មភាពលើកកម្ពស់ការយល់ដឹងដែលមានគោលដៅទៅលើកងកម្លាំងនគរបាល និង សាធារណជនទូទៅ ។*[25]

គណៈកម្មាធិការសិទ្ធិមនុស្ស ក៏បានធ្វើសេចក្តីថ្លែងការណ៍ស្រដៀងគ្នានេះពាក់ព័ន្ធនឹងប្រទេសម៉ុងហ្គោលី ដោយថ្លែងថារដ្ឋគួរតែ "ធានាថាមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្ស ស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ(LGBT) មានលទ្ធភាពទទួលបានយុត្តិធម៌ និង គ្រប់ការចោទប្រកាន់ ទាំងអស់លើការវាយប្រហារ និង ការគំរាមកំហែងចំពោះបុគ្គលទាំងឡាយដែលត្រូវបានកំណត់ជាគោលដៅ ដោយសារតែទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ ត្រូវបានស៊ើបអង្កេតដោយហ្មត់ចត់" ។[26]

## ការទាមទារសិទ្ធិជ្រកកោន

រដ្ឋទាំងឡាយ ក៏មានករណីយកិច្ចផ្តល់ជម្រកប្រកបដោយសុវត្ថិភាពដល់បុគ្គលទាំងឡាយ ដែលរត់ចេញពីការធ្វើទុក្ខបុកម្នេញដោយមានទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ។ មាត្រា៣៣ នៃអនុសញ្ញាស្តីពីឋានៈនៃជនភៀសខ្លួនចែងថា រដ្ឋជាភាគីមានកាតព្វកិច្ចមិនបណ្តេញចេញ ឬ បញ្ជូនត្រឡប់វិញនូវជនភៀសខ្លួនទៅកន្លែងដែលជីវិត ឬ សេរីភាពរបស់គេ នឹងត្រូវបានគំរាមកំហែង ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ សមាជិកភាពរបស់ក្រុមសង្គមពិសេសណាមួយ ឬ ទស្សនៈនយោបាយ។ ឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ណែនាំថា បុគ្គលទាំងឡាយដែលភ័យខ្លាចការធ្វើទុក្ខបុកម្នេញ ដោយសារទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ អាចត្រូវបានចាត់ទុកថាជាសមាជិករបស់ "ក្រុមសង្គមពិសេសណាមួយ"។ រដ្ឋជាភាគីនៃអនុសញ្ញាគួរតែធានាថា បុគ្គលបែបនេះ មិនត្រូវបានបញ្ជូនត្រឡប់ទៅរដ្ឋដែលនៅទីនោះជីវិត ឬ សេរីភាពរបស់ពួកគេនឹងប្រឈមនឹងគ្រោះថ្នាក់ និង ឲ្យតែបុគ្គលពាក់ព័ន្ធបំពេញតាមលក្ខណៈវិនិច្ឆ័យនៃឋានៈជនភៀសខ្លួនទទួលស្គាល់ពួកគេជាជនភៀសខ្លួនដែលត្រូវបានធ្វើប្រព្រឹត្តកម្ម ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ ។[27]

---

[25] សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសប៉ូឡូញ (CCPR/C/POL/CO/6) ត្រង់កថាខណ្ឌទី ៨ ។

[26] សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសម៉ុងហ្គោលី (CCPR/C/MNG/CO/5) ត្រង់កថាខណ្ឌទី ៩ និងសម្រាប់ប្រទេសម៉ិចស៊ីកូ (CCPR/C/MEX/CO/5) ត្រង់កថាខណ្ឌទី ២១ ។

[27] ឯកសារកំណត់សំគាល់ណែនាំស្តីពីការទាមទារសិទ្ធិជនភៀសខ្លួនរបស់ឧត្តមស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនដែលពាក់ព័ន្ធនឹងទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ (សូមមើលលេខយោងទី ១) ត្រង់កថាខណ្ឌទី ៣ ។ សូមមើលផងដែរនូវឧត្តមស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ពាក់ព័ន្ធនឹងរដ្ឋលេខាធិការនៃក្រសួងដែនដី និង Patrick Kwame Otchere ឆ្នាំ ១៩៩៨ ។

ឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនប៉ាន់ប្រមាណថា យ៉ាងតិច ៤២ រដ្ឋបានផ្តល់សិទ្ធិជ្រកកោនដល់បុគ្គលទាំងឡាយដែលមានការភ័យខ្លាចចំពោះការធ្វើទុក្ខបុកម្នេញដែលមានមូលហេតុច្បាស់លាស់ដោយហេតុថា ទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ ទោះបីជាតួលេខច្បាស់លាស់មិនមានក៏ដោយ។រដ្ឋខ្លះផ្តល់សិទ្ធិជ្រកកោនសូម្បីតែគ្មានគោលនយោបាយច្បាស់លាស់នៅក្នុងរឿងនេះ ចំណែកឯរដ្ឋទទៃទៀតមិនបានតាមរកមូលហេតុដើម្បីផ្តល់ឋានៈជនភៀសខ្លួន ឬ សិទ្ធិជ្រកកោនទេ។ សូម្បីតែនៅក្នុងប្រទេសដែលទទួលស្គាល់មូលដ្ឋានគ្រឹះទាំងនេះ ដើម្បីផ្តល់សិទ្ធិជ្រកកោនក៏ដោយក៏ការអនុវត្ត និង នីតិវិធីជារឿយៗ មិនទាន់ឈានដល់បទដ្ឋានអន្តរជាតិទេ។ ការពិនិត្យមើលពាក្យស្នើសុំជួនកាលមានលក្ខណៈបំពាន និងមិនខ្ជាប់ខ្ជួន។ មន្ត្រីអាចមានចំណេះដឹងតិចតួច ឬ ភាពងាយរងផលប៉ះពាល់ឆ្ពោះទៅរកលក្ខខណ្ឌដែលមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ(LGBT)ប្រឈមមុខ។[28] ជនភៀសខ្លួន ជួនកាលត្រូវទទួលរងអំពើហិង្សា និងការរើសអើងពេលនៅក្នុងមន្ទីរឃុំឃាំង និង នៅពេលតាំងទីលំនៅ អាចត្រូវបានផ្តល់ជម្រកស្នាក់នៅក្នុងសហគមន៍ដែលពួកគេប្រឈមនឹងគ្រោះថ្នាក់ដែលទាក់ទងនឹងផ្លូវភេទ និង ពាក់ព័ន្ធនឹងយេនឌ័របន្ថែមទៀត។ ការបង្ខំឲ្យវិលត្រឡប់ទៅវិញចំពោះអ្នកស្វែងរកសិទ្ធិជ្រកកោនដែលរត់ចេញពីការធ្វើទុក្ខបុកម្នេញបែបនេះ ធ្វើឲ្យពួកគេធ្លាក់ចូលក្នុងគ្រោះថ្នាក់នៃអំពើហិង្សា ការរើសអើង និងការចាត់ទុកជាអំពើឧក្រិដ្ឋ។ ក្នុងករណីខ្លះ ពួកគេត្រូវបានបញ្ជូនត្រឡប់ទៅវិញដោយមានការណែនាំ "ឲ្យទៅផ្ទះដោយមិនត្រូវសម្ដែង" ពោលគឺជាយុទ្ធវិធីដែលត្រូវបានរិះគន់ដោយឧត្តមស្នងការ នៃអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ។[29]

## សេចក្តីសន្និដ្ឋាន

ដើម្បីគោរព ការពារ និង បំពេញសិទ្ធិរស់រានមានជីវិត និងសន្តិសុខផ្ទាល់ខ្លួនដែលត្រូវបានធានា ដូចមានចែងក្នុងច្បាប់អន្តរជាតិ រដ្ឋទាំងឡាយត្រូវតែស៊ើបអង្កេត នាំយកមកកាត់ទោស និងផ្តន្ទាទោសចារី ដែលទទួលខុសត្រូវចំពោះការប្រហារជីវិតក្រៅតុលាការឲ្យមានប្រសិទ្ធភាព និងអនុម័តច្បាប់ស្តីពីឧក្រិដ្ឋកម្មរើសអើងដែលការពារបុគ្គលទាំងឡាយពីអំពើហិង្សា ដោយសារទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ។ ប្រព័ន្ធប្រកបដោយប្រសិទ្ធភាព គួរតែត្រូវបានបង្កើតឲ្យមានឡើង សម្រាប់កត់ត្រា និងធ្វើរបាយការណ៍ ស្តីពី អំពើហិង្សាដែលបង្កឡើងដោយសារការស្អប់។ ច្បាប់ និងគោលនយោបាយស្តីពីសិទ្ធិជ្រកកោន គួរតែទទួលស្គាល់ ថា ការធ្វើទុក្ខបុកម្នេញដោយសារតែទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រអាចជាមូលដ្ឋានដែលមានសុពលភាពសម្រាប់ការទាមទារសិទ្ធិជ្រកកោន ។

[28]ឯកសារកំណត់សំគាល់ណែនាំស្តីពីការទាមទារសិទ្ធិជាជនភៀសខ្លួនរបស់ឧត្តមស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ត្រង់កថាខណ្ឌទី ៣៧ និង ៤១ ។

[29]ដូចយោងខាងលើ ត្រង់កថាខណ្ឌទី ២៥ ២៦ និង ៤១ ។ សូមមើលផងដែរនូវសេចក្តីសម្រេចរបស់តុលាការកំពូលនៃចក្រភពអង់គ្លេស *HJ (សាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់) និង HT (កាមេរូន) និងរដ្ឋលេខាធិការនៃក្រសួងដែនដី* [២០១០] UKSC 31 ។

## ២. ទប់ស្កាត់ការធ្វើទារុណកម្ម និង ប្រព្រឹត្តកម្មដ៏ឃោរឃៅ អមនុស្សធម៌ និង បន្ថោកបន្ទាប ចំពោះមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ( LGBT )

*រដ្ឋទាំងឡាយមានកាតព្វកិច្ចដូចមានចែងក្នុងច្បាប់អន្តរជាតិ ដើម្បីការពារបុគ្គលពីការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មដ៏ឃោរឃៅ អមនុស្សធម៌ ឬ ថោកទាបផ្សេងទៀត។ នេះរួមបញ្ចូលទាំងកាតព្វកិច្ចដើម្បីហាមឃាត់ការធ្វើទារុណកម្ម និង ទម្រង់ផ្សេងទៀតនៃការធ្វើទុក្ខទោស និង ដើម្បីផ្តល់នូវសំណងចំពោះអំពើបែបនេះ។ ការខកខានមិនបានស៊ើបអង្កេត និង មិនបានចាប់បញ្ជូនចារីដែលធ្វើទារុណកម្ម ទៅជំនុំជម្រះទោសនៅតុលាការ គឺជាការប្រព្រឹត្តល្មើសលើច្បាប់សិទ្ធិមនុស្សអន្តរជាតិតែម្តង។ ជាងនេះទៀតការប្រើប្រាស់ ការពិនិត្យទ្វារលាមកដោយបង្ខំបំបានការហាមឃាត់ចំពោះការធ្វើទារុណកម្ម និង ប្រព្រឹត្តកម្មដ៏ឃោរឃៅ អមនុស្សធម៌ ឬ ថោកទាបផ្សេងទៀត ។ សិទ្ធិទាំងនេះត្រូវបានធានាដោយមាត្រា៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ និងមាត្រា២ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។*

### សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

**មាត្រា ៥៖** គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬ ប្រព្រឹត្តកម្មមកលើខ្លួន ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាបបានឡើយ ។

### កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

**មាត្រា ៧៖** គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬ ប្រព្រឹត្តកម្មមកលើខ្លួន ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាបបានឡើយ ។ ជាពិសេស ហាមយកជនណាម្នាក់មកធ្វើពិសោធន៍ខាងវេជ្ជសាស្ត្រ ឬ វិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រមដោយសេរីពីសាមីខ្លួនឡើយ ។

### អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម

**មាត្រា ១ (១)៖** ដើម្បីគោលបំណងនៃអនុសញ្ញានេះពាក្យ "ទារុណកម្ម" មានន័យថា អំពើទាំងឡាយណាដែលនាំឲ្យមានការឈឺចាប់ ឬ ការរងទុក្ខយ៉ាងខ្លាំងទោះផ្លូវកាយ ឬ ផ្លូវចិត្តក្តី ត្រូវបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ក្នុងគោលបំណងទាំងឡាយ ដូចជាទាញយកព័ត៌មានពីជននោះ ឬ តតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះចំពោះអំពើណាមួយដែលជននោះ ឬ តតិយជនណាម្នាក់ បានប្រព្រឹត្ត ឬ សង្ស័យថាបានប្រព្រឹត្ត ឬ បំភិតបំភ័យ ឬ បង្ខិតបង្ខំជននោះឬ តតិយជនណាម្នាក់ ឬ ដើម្បីមូលហេតុណា ផ្សេងទៀត ដែលផ្អែកលើការរើសអើងណាមួយ បើការឈឺចាប់ ឬ ការរងទុក្ខបង្កដោយមន្ត្រីសាធារណៈ ឬ ជនផ្សេងទៀត តាមការញុះញង់ ឬ ការព្រមព្រៀង ឬ ផ្តើមគំនិតរបស់ មន្ត្រីសាធារណៈ ឬ ជនផ្សេង ទៀតដែលបំពេញតួនាទីជាផ្លូវការ។ ពាក្យទារុណកម្ម មិនរាប់បញ្ចូលនូវការឈឺចាប់ ឬ ការរងទុក្ខដែល កើតជាប់ ឬ ម្តងម្កាល ពីទណ្ឌកម្មត្រឹមត្រូវតាមច្បាប់ឡើយ។

**មាត្រា ២ (១)៖** រដ្ឋភាគី ត្រូវចាត់វិធានការច្បាប់រដ្ឋបាល និង តុលាការ ឬ វិធានការផ្សេងទៀតដើម្បីបង្ការកុំឲ្យមានទារុណកម្មនៅក្នុងលើដែនដី ក្រោមសមត្ថកិច្ចរបស់ខ្លួន ។

# គោលជំហររបស់យន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម តំណាងពិសេសទទួលបន្ទុកការធ្វើទារុណកម្ម និង អង្គការសិទ្ធិមនុស្ស និងយន្តការផ្សេងទៀត មានចងក្រងជាឯកសារនូវភស្តុតាងដ៏ច្រើនពីការរំលោភបំពាន និងការធ្វើទុក្ខទោសលើមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) ដែលបង្កឡើងដោយនគរបាល ឆ្មាំគុក និងមន្ត្រីអនុវត្តច្បាប់ដទៃទៀត។[30] គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មបានព្រមានថា "ទាំងបុរស និងស្ត្រី ទាំងក្មេងប្រុស និងក្មេងស្រី អាចមានការរំលោភបំពានលើអនុសញ្ញា ដោយសារមិនគោរពតាមជាក់ស្តែងឬតាមការយល់ដឹងនូវតួនាទីយេនឌ័រដែលត្រូវបានកំណត់ដោយសង្គម"។[31] អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រី មានការចោទប្រកាន់ពិស្តារអំពីកូនកាត់[32] នៅក្នុងប្រទេសនេប៉ាល់ ដែលត្រូវបានវាយដំដោយនគរបាលដែលបានទាមទារប្រាក់ និងការរួមភេទ ។[33] នៅក្នុងករណីមួយនៅក្នុងប្រទេសអែលសាវ៉ាឌ័រ ស្ត្រីប្តូរភេទម្នាក់ត្រូវបានឃុំឃាំងនៅក្នុងបន្ទប់មួយជាមួយនឹងសមាជិកក្រុមជនខិលខូចដែលនៅទីនោះ នាងត្រូវបាន "រំលោភសេពសន្ថវៈជាង ១០០ ដង ជួនកាលដោយមានសមគំនិតក្នុងការរំលោភពីសំណាក់មន្ត្រីពន្ធនាគារទៀត ។[34]

អ្នករាយការណ៍ពិសេសទទួលបន្ទុកការធ្វើទារុណកម្ម ក៏បានលើកឡើងពីការចោទប្រកាន់អំពីការធ្វើទុក្ខទោសចំពោះអ្នកជាប់ពន្ធនាគារ និង អ្នកជាប់ឃុំឃាំង ដោយសារទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័ររបស់ពួកគេនៅក្នុងរបាយការណ៍របស់គាត់ ។[35] នៅក្នុងរបាយការណ៍ឆ្នាំ ២០០១ គាត់ បានសរសេរថា:

[30]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់សហរដ្ឋអាមេរិក (CCPR/C/US/CO/3)ត្រង់កថាខណ្ឌទី ២៥។ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មសម្រាប់សហរដ្ឋអាមេរិក (CAT/C/USA/CO/2)ត្រង់កថាខណ្ឌទី ៣២ និង ៣៧ សម្រាប់ប្រទេសអេក្វាឌ័រ (CAT/C/ECU/CO/3) ត្រង់កថាខណ្ឌទី ១៧ សម្រាប់ប្រទេសអាសង់ទីន (CAT/C/C/CR/33/1) ត្រង់កថាខណ្ឌទី៦ (ឆ) សម្រាប់ប្រទេសអេស៊ីប (CAT/C/CR/29/4) ត្រង់កថាខណ្ឌទី ៥ (ង)។ សេចក្តីពន្យល់ទូទៅលេខ ២ ត្រង់កថាខណ្ឌទី ២១ របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម។ សូមមើលផងដែរនូវសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសម្រាប់ប្រទេសអេក្វាឌ័រ (CAT/C/ECU/CO/3) ត្រង់កថាខណ្ឌទី ១៧ សម្រាប់ប្រទេសអាសង់ទីន (CAT/C/CR/33/1)ត្រង់កថាខណ្ឌទី ៦ សម្រាប់ប្រទេសប្រេស៊ីល (A/56/44)ត្រង់កថាខណ្ឌទី ១១៩ ។

[31]កថាខណ្ឌទី ២២ នៃសេចក្តីពន្យល់ទូទៅលេខ ២ របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ។

[32]កូនកាត់ភេទ គឺជាវាក្យស័ព្ទដែលត្រូវបានប្រើប្រាស់នៅក្នុងប្រទេសនេប៉ាល់ ដើម្បីពិពណ៌នាអំពីមនុស្សដែលត្រូវបានបែងចែកជាភេទប្រុសពីកំណើត និងដែលមានអត្តសញ្ញាណភេទស្រី ឬ របៀបបង្ហាញពីយេនឌ័រ។

[33]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រីៈ E/CN.4/2006/61/Add.1 ត្រង់កថាខណ្ឌទី ១ និង ២ និង A/HRC/4/34/Add.1 ត្រង់កថាខណ្ឌទី ៤៤៨-៤៥៤ ។

[34]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រី (A/HRC/17/26/Add.2) ត្រង់កថាខណ្ឌទី ២៨-២៩ ។

[35]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មដ៏ឃោរឃៅ អមនុស្សធម៌ ឬ ថោកទាប ឬ ការដាក់ទណ្ឌកម្មៈ E/CN.4/2001/66/Add.2 ត្រង់កថាខណ្ឌទី១៩៩ E/CN.4/2005/62/Add.1 ត្រង់កថាខណ្ឌទី ១០១៩ ១១៦១ E/CN.4/2004/56/Add.1 ត្រង់កថាខណ្ឌទី ១៣២៧ E/CN.4/2003/68/Add.1 ត្រង់កថាខណ្ឌទី៤៤៦ ៩៦៣-៩៦៥ និង ១៨៦១ E/CN.4/2002/76/Add.1 ត្រង់កថាខណ្ឌទី ១៦ ៥០៧-៥០៨ ៨២៩ ១៧០៩-១៧១៦E/CN.4/2001/66 ត្រង់កថាខណ្ឌទី ១១៧១ E/CN.4/2000/9 ត្រង់កថាខណ្ឌទី ១៤៥ ១៥១ ៧២៦ E/CN.4/1995/34 ត្រង់កថាខណ្ឌទី៦១៤ ។

*វាបង្ហាញឲ្យឃើញថា សមាជិកក្រុមជនភាគតិចផ្នែកផ្លូវភេទ មានលក្ខណៈវិសមាមាត្រក្នុងការទទួលរងការធ្វើទារុណកម្ម និង ទម្រង់ផ្សេងទៀតនៃការធ្វើទុក្ខទោស ដោយសារពួកគេខកខានមិនបានអនុលោមទៅតាមការរំពឹងទុកយេនឌ័រដែលត្រូវបានកំណត់ដោយសង្គម។តាមពិតការរើសអើងដោយសារទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ ជារឿយៗអាចរួមចំណែកក្នុងដំណើរការធ្វើឲ្យបាត់លក្ខណៈជាមនុស្សចំពោះជនរងគ្រោះ ដែលជារឿយៗ ជាលក្ខខណ្ឌចាំបាច់សម្រាប់បង្កឲ្យការធ្វើទារុណកម្ម និងការធ្វើទុក្ខទោសកើតមានឡើង ។*[36]

គាត់បានបញ្ជាក់ថា ជាពិសេស អ្នកជាប់ពន្ធនាគារដែលប្តូរភេទងាយនឹងទទួលរងការរំលោភបំពានលើរូបរាងកាយ និង ផ្លូវភេទ ប្រសិនបើត្រូវបានដាក់ជាមួយនឹងអ្នកជាប់ពន្ធនាគារទូទៅ។[37] ឧទាហរណ៍ៈ អ្នករាយការណ៍ពិសេស បានរាយការណ៍អំពីករណីស្ត្រីប្តូរភេទដែលត្រូវបានវាយដំដោយចេតនាចំលើសុដន់និងឆ្អឹងថ្ពាល់របស់គាត់ដើម្បីបញ្ចេញជាតិពុលករណីរបស់ក្រុមជនភាគតិចផ្នែកផ្លូវភេទដែលត្រូវទទួលរងភាពជាជនរងគ្រោះដោយសារនគរបាល នៅពេលរាយការណ៍អំពីអំពើឧក្រិដ្ឋ និងករណីរបស់ឆ្មាំគុកដែលខកខានមិនបានអនុវត្តវិធានការសមស្រប ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃអំពើហិង្សាផ្នែករាងកាយ ឬ ផ្លូវភេទទៅលើជនជាប់ឃុំឃាំងជាមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT)។[38] នៅក្នុងករណីមួយ គូស្វាមីភរិយាដែលជា មនុស្សស្រីស្រលាញ់ភេទដូចគ្នានៅក្នុងប្រទេសប្រេស៊ីលត្រូវបានចោទប្រកាន់ថាត្រូវបានវាយដំនៅប៉ុស្តិ៍នគរបាលត្រូវបាន រំលោភបំពានដោយពាក្យសំដី និង ត្រូវបានបង្ខំឲ្យរួមភេទតាមមាត់។[39] នៅអ៊ូបេគីស្ថានអ្នកការពារសិទ្ធិមនុស្សម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទស្រលាញ់មនុស្សភេទដូចគ្នា ត្រូវបានវាយដំ និង គំរាមកំហែងដោយមានការរំលោភសេពសន្ថវៈ ពីនគរបាល ។[40]

រដ្ឋទាំងឡាយត្រូវបានតម្រូវឲ្យការពារ"មនុស្សគ្រប់រូបដោយមិនគិតអំពី..ទំនោរផ្លូវភេទ ឬអត្តញ្ញាណយេនឌ័រ" ពីការធ្វើទារុណកម្ម និង ប្រព្រឹត្តកម្ម ឬ ការដាក់ទណ្ឌកម្មដ៏ឃោរឃៅ អមនុស្សធម៌ឬ ថោកទាប (ដែលនៅក្នុងសៀវភៅនេះ ហៅថា "ការធ្វើទុក្ខទោស")។[41]ដូចមានចែងក្នុងច្បាប់អន្តរជាតិ រដ្ឋទាំងឡាយមានកាតព្វកិច្ចហាមឃាត់ ទប់ស្កាត់និងផ្តល់សំណងចំពោះការធ្វើទារុណកម្ម និង ការធ្វើទុក្ខទោសក្នុង គ្រប់បរិបទទាំងអស់នៃការឃុំឃាំង ឬ ត្រួតត្រារបស់រដ្ឋ។[42] ការខកខានមិនបានស៊ើបអង្កេត និង ចាប់បញ្ជូនទៅជំនុំ

---

[36]របាយការណ៍បណ្តោះអាសន្នរបស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មដ៏ឃោរឃៅ អមនុស្សធម៌ ឬ ថោកទាប ឬ ការដាក់ទណ្ឌកម្ម (A/56/156) ត្រង់កថាខណ្ឌទី ១៩ ។

[37]A/56/156ត្រង់កថាខណ្ឌទី ២៣ ។

[38]A/56/156ត្រង់កថាខណ្ឌទី ១៨ E/CN.4/2002/76/Add.1 ត្រង់កថាខណ្ឌទី ១៦ ១៧១១។

[39]E/CN.4/2001/66/Add.2 ត្រង់កថាខណ្ឌទី ១៩៩ ។

[40]E/CN.4/2004/56/Add.1 ត្រង់កថាខណ្ឌទី ១៨៧៨ និង ១៨៩៩ ។

[41]កថាខណ្ឌទី ២១ នៃសេចក្តីពន្យល់ទូទៅលេខ ២ របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ។

[42]កថាខណ្ឌទី ១៥ នៃសេចក្តីពន្យល់ទូទៅលេខ ២ របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ។

ជម្រះទោសនៅតុលាការចំពោះចារីធ្វើទារុណកម្ម ឬ ធ្វើទុក្ខទោសអាចបណ្តាលឲ្យមានការប្រព្រឹត្តល្មើសដាច់ដោយឡែកលើច្បាប់អន្តរជាតិ។[43] នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនសម្រាប់សហរដ្ឋអាមេរិក ឧទាហរណ៍ គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម បានសម្តែងចេញនូវកង្វល់អំពីរបាយការណ៍ ស្តីពីការរំលោភលើរាងកាយ និង ផ្លូវភេទរបស់មនុស្ស"ដែលមានទំនោរផ្លូវភេទផ្សេងគ្នា"។ រដ្ឋជាភាគីគួរតែធានាថា "មន្ត្រីអនុវត្តច្បាប់របស់ខ្លួនត្រូវបានស៊ើបអង្កេតដោយឯករាជ្យដោយរហ័សទាន់ពេលវេលានិងដោយហ្មត់ចត់ហើយចារីត្រូវបានចោទប្រកាន់ និង ដាក់ទោសដោយសមស្រប"។[44] ក្នុងករណីប្រទេសកូស្តារីកា គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម បានផ្តល់អនុសាសន៍អំពីកម្មវិធីបណ្តុះបណ្តាល និង លើកកម្ពស់ការយល់ដឹងដល់មន្ត្រីនគរបាល អ្នកយាមតាមព្រំដែន និង បុគ្គលិកពន្ធនាគារ ដើម្បីបង្ការទប់ស្កាត់ការរំលោភបំពានលើមនុស្ស "ដោយសារទំនោរផ្លូវភេទ និង/ឬ អត្តសញ្ញាណប្តូរភេទបន្ទាប់ពីវះកាត់របស់ពួកគេ" ។[45]

[43]កថាខណ្ឌទី ១៨ នៃសេចក្តីពន្យល់ទូទៅលេខ ៣១ របស់គណៈកម្មាធិការសិទ្ធិមនុស្ស ។

[44]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មសម្រាប់សហរដ្ឋអាមេរិក (CAT/C/USA/CO/2) ត្រង់កថាខណ្ឌទី ៣២ និង ៣៧ ។

[45]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មសម្រាប់ប្រទេសកូស្តារីកា (CAT/C/CRI/CO/2) ត្រង់កថាខណ្ឌទី ១១ និង ១៨ ។




បញ្ហាមួយដែលត្រូវបានលើកឡើងដោយអ្នកជំនាញការគឺការអនុវត្តក្នុងការធ្វើឲ្យបុរសដែលត្រូវបានសង្ស័យពីការស្រលាញ់មនុស្សភេទដូចគ្នាមកពិនិត្យទ្វារលាមកដោយមិនមានការយល់ព្រម។នៅក្នុងប្រទេសខ្លះបុរសដែលត្រូវបានចាប់ខ្លួនដោយសារការចោទប្រកាន់ពីបទស្រលាញ់មនុស្សភេទដូចគ្នាត្រូវបានបង្ខិតបង្ខំឲ្យទទួលការពិនិត្យសុខភាព ដើម្បីស្វែងរកភស្តុតាងរូបវន្តនៃការរួមភេទតាមទ្វារលាមក។ ក្រៅពីមិនមានតម្លៃផ្នែកវិទ្យាសាស្ត្រ តេស្តបែបនេះគឺជាការរំលោភបំពានលើបូរណភាពរូបកាយ។ ក្នុងករណីដែលបុរសត្រូវយកមកពិនិត្យទ្វារលាមក ក្រុមការងារផ្នែកការឃុំឃាំងបំពានថ្លែងថាៈ

> *តេស្តទាំងនេះ ដែលត្រូវបានធ្វើឡើងដោយបង្ខំមានចរិតរំលោភបំពានតែម្តង និង រំលោភបំពានលើសិទ្ធិផ្នែករាងកាយរបស់បុគ្គល ដូចមានចែងក្នុងច្បាប់សិទ្ធិមនុស្ស...ដោយហេតុនេះក្រុមការងារបានពិចារណាថា...ការពិនិត្យទ្វារលាមកដោយបង្ខំបំពានការហាមឃាត់ការធ្វើទារុណកម្ម និង ប្រព្រឹត្តកម្មដ៏ឃោរឃៅ អមនុស្សធម៌ និង ថោកទាបផ្សេងទៀតថាតើដូចនៅក្នុងករណីបច្ចុប្បន្ន វាត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីដាក់ទោស ដើម្បីបង្ខំឲ្យមានការសារភាព ឬ ធ្វើឲ្យមានការកើនឡើងនូវការរើសអើងថែមទៀត។ លើសពីនេះ វាមិនមានតម្លៃផ្នែកវេជ្ជសាស្ត្រ សម្រាប់ការកំណត់ថាតើ*

*មនុស្សម្នាក់បានជាប់ពាក់ព័ន្ធនឹងទំនាក់ទំនងផ្លូវភេទជាមួយមនុស្សមានភេទដូចគ្នាដែរឬទេ ឬ ថាតើមនុស្សនោះបានពាក់ព័ន្ធនឹងអំពើអនាចារជាទម្លាប់ ឬពេស្យាចារបុរសដែរឬទេ ។*[46]

គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម និង អ្នករាយការណ៍ពិសេសទទួលបន្ទុកការធ្វើទារុណកម្ម ក៏បានរិះគន់លើការប្រើប្រាស់ការពិនិត្យទ្វារលាមកដោយបង្ខំដើម្បី "បញ្ជាក់" អំពីការស្រលាញ់មនុស្សមានភេទដូចគ្នា ។[47]អ្នករាយការណ៍ពិសេសទទួលបន្ទុកការធ្វើទារុណកម្មបានពិពណ៌នាអំពី "កោសល្យវិច័យដែលមានលក្ខណៈបំពាន "ជាការរំលោភបំពាន និង បន្ទាបបន្ថោក" ដោយមានសក្តានុពល "ដែលបង្កើតទៅជាការធ្វើទារុណកម្ម ឬ ការធ្វើទុក្ខទោស" និង បានជំទាស់នឹងការអនុវត្តក្នុងការទំនាក់ទំនងជាមួយនឹងរដ្ឋទាំងឡាយ។[48]

កង្វល់ទីពីរ គឺ អំពើហិង្សាផ្លូវភេទ។ យន្តការសិទ្ធិមនុស្ស បានលើកឡើងម្តងហើយម្តងទៀតអំពីបញ្ហានៃការរំលោភបំពានផ្លូវភេទលើមនុស្សស្រីស្រលាញ់ភេទដូចគ្នាមនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) ជារឿយៗ ដោយនគរបាលជាពិសេសនៅកន្លែងឃាត់ខ្លួន។[49] អំពើហិង្សាផ្នែកផ្លូវភេទអាចជាការធ្វើទារុណកម្មនៅពេលដែលវាត្រូវបានអនុវត្តតាមរយៈ ឬ ដោយមានការផ្តើមគំនិតពី ឬ ដោយមានការយល់ព្រម ឬ ការស្រុះស្រួលពីសំណាក់មន្ត្រីសាធារណៈ។[50] គោលបំណងមួយក្នុងចំណោមគោលបំណងដែលត្រូវបានហាមឃាត់ក្រោមការកំណត់អំពីការធ្វើទារុណកម្ម គឺ"ការរើសអើងទោះជាប្រភេទណាមួយក៏ដោយ"។ ការរំលោភបំពានផ្លូវភេទលើ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ(LGBT) ជារឿយៗត្រូវបានបង្កឲ្យមានឡើងដោយសារការរើសអើង។ អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សា លើស្ត្រីបានកត់សំគាល់ថា "ទោះបីអំពើហិង្សាផ្នែកផ្លូវភេទ ជារឿយៗ ត្រូវបានពិនិត្យមើលដាច់ដោយឡែកក៏ដោយក៏វាជារឿយៗ ចូលគ្នាជាមួយនឹងទម្រង់ផ្សេងទៀតនៃការរើសអើងក្នុងនោះរួមមាន ដោយមូលហេតុជាតិសាសន៍ ជាតិពន្ធុ សាសនា អត្តសញ្ញាណភេទ ឋានៈក្នុងសង្គម ឬ ពិការភាព"។[51] គាត់បានបញ្ជាក់អំពី "ការរើសអើង និង អំពើហិង្សាដែលរីករាលដាលដូចដែលក្រុមស្ត្រីមួយចំនួនទទួលរងដោយសារទំនោរ ផ្លូវ

---

[46]កថាខណ្ឌទី ២៣ និង ២៨-២៩ នៃសេចក្តីសម្រេចលេខ ២៥/២០០៩ របស់ក្រុមការងារប្រឆាំងនឹងការឃុំឃាំងបំពាន សម្រាប់ប្រទេសអេស៊ីប (A/HRC/16/47/Add.1) ។

[47]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មសម្រាប់ប្រទេសអេស៊ីប (CAT/C/CR/29/4) ត្រង់កថាខណ្ឌទី ៥-៦ ។

[48]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការធ្វើទារុណកម្មៈ A/56/156 ត្រង់កថាខណ្ឌទី ២៤ A/HRC/4/33/Add.1 ត្រង់កថាខណ្ឌទី ៣១៧ A/HRC/10/44/Add.4 ត្រង់កថាខណ្ឌទី ៦១ និង A/HRC/16/52/Add.1 ។

[49]**ការរំលោភបំពានផ្លូវភេទលើស្រីស្រលាញ់ភេទដូចគ្នា ប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ(LGBT)៖**CAT/C/USA/CO/2ត្រង់កថាខណ្ឌទី ៣២។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការធ្វើទារុណកម្មៈ E/CN.4/2003/68/Add.2 ត្រង់កថាខណ្ឌទី ៤២ E/CN.4/2002/76 ត្រង់ឧបសម្ព័ន្ធ III A/56/156 ត្រង់កថាខណ្ឌទី១៨ និង ២៣ ។

[50]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការធ្វើទារុណកម្មៈ (A/HRC/7/3) ត្រង់កថាខណ្ឌទី ៣៤ ។

[51]**អំពើហិង្សាផ្នែកផ្លូវភេទ និងការរើសអើងច្រើនប្រភេទ៖** របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រី (A/HRC/14/22/Add.1)ត្រង់កថាខណ្ឌ ១៧ ។

ភេទ និង អត្តសញ្ញាណយេនឌ័ររបស់ពួកគេ"។ នៅក្នុងរបាយការណ៍របស់គាត់ គាត់បានបញ្ជាក់បន្ថែមទៀតថា:

> *ដូចមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាពិសេស សេចក្តីប្រកាសស្តីពីការលុបបំបាត់ចោលអំពើហិង្សាលើស្ត្រី និងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងប្រព្រឹត្តកម្ម ឬ ការដាក់ទណ្ឌកម្មដ៏ឃោរឃៅអមនុស្សធម៌ ឬ ថោកទាប រដ្ឋទាំងឡាយមានកាតព្វកិច្ចកំណត់ជាបទល្មើសចំពោះអំពើទារុណកម្ម និងអំពើហិង្សាលើស្ត្រី ចោទប្រកាន់ចារី និងផ្តល់នូវសំណងដល់ជនរងគ្រោះ។ ដោយហេតុនេះ រដ្ឋទាំងឡាយត្រូវតែខិតខំឲ្យអស់ពីលទ្ធភាពរបស់ខ្លួន ដើម្បីបង្ការទប់ស្កាត់ការប្រព្រឹត្តអំពើហិង្សាផ្អែកផ្លូវភេទ ដោះស្រាយបញ្ហាអំពើហិង្សាផ្អែកផ្លូវភេទណាមួយ និង ផ្តល់ ដំណោះស្រាយតាមផ្លូវតុលាការដល់ជនរងគ្រោះ។[52]*

## សេចក្តីសន្និដ្ឋាន

បុគ្គលគ្រប់រូបត្រូវបានការពារពីការធ្វើទារុណកម្ម និង ប្រព្រឹត្តកម្មដ៏ឃោរឃៅ អមនុស្សធម៌ ឬ ថោកទាប។ ការពិនិត្យទ្វារលាមកដោយបង្ខំ និង អំពើហិង្សាដែលបង្កឡើងដោយភ្នាក់ងាររដ្ឋអាចជាការធ្វើទារុណកម្ម ឬ ប្រព្រឹត្តកម្ម ឬ ការដាក់ទណ្ឌកម្មដ៏ឃោរឃៅ អមនុស្សធម៌ ឬ ថោកទាប។ ដូចមានចែងក្នុង ច្បាប់អន្តរជាតិ រដ្ឋទាំងឡាយត្រូវតែហាមឃាត់ និង ដាក់ទោសលើការធ្វើទារុណកម្ម និងការធ្វើទុក្ខទោស និងត្រូវតែផ្តល់នូវដំណោះស្រាយដល់ជនរងគ្រោះដោយសារអំពើបែបនេះ។[53] នេះមានន័យថារដ្ឋត្រូវតែ កំណត់ការធ្វើទារុណកម្ម និង ការធ្វើទុក្ខទោសជាបទល្មើស ក្រោមច្បាប់ព្រហ្មទណ្ឌជាតិ និង ត្រូវតែធានាថាអំពើឃោរឃៅទាំងអស់ដែលបង្កឡើងដោយមន្ត្រីអនុវត្តច្បាប់ និង ភ្នាក់ងារដទៃទៀតរបស់រដ្ឋ ត្រូវបានស៊ើបអង្កេតដោយឯករាជ្យដោយរហ័សទាន់ពេលវេលា និង ដោយហ្មត់ចត់ និង អ្នកទទួលខុសត្រូវត្រូវចាប់បញ្ជូន ទៅជំនុំជម្រះទោសនៅតុលាការ។រដ្ឋទាំងឡាយគួរតែផ្តល់នូវនីតិវិធីដែលតាមរយៈនេះជនរងគ្រោះដោយសារអំពើបែបនេះអាចស្វែងរកដំណោះស្រាយក្នុងនោះរួមមានសំណងផងដែរ។រដ្ឋទាំងឡាយក៏មានកាតព្វកិច្ចអនុវត្ត វិធានការបង្ការទប់ស្កាត់ដូចជា ការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ និង ការពិនិត្យតាមដានកន្លែងឃុំឃាំង។

---

[52]**កាតព្វកិច្ចរបស់រដ្ឋ យោងទៅតាមអំពើហិង្សាផ្លូវភេទ៖** A/HRC/14/22/Add.1 ត្រង់កថាខណ្ឌទី ១៩ ។

[53]សេចក្តីពន្យល់ទូទៅលេខ ២០ របស់គណៈកម្មាធិការសិទ្ធិមនុស្ស។ សេចក្តីពន្យល់ទូទៅលេខ ២ របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ។

## ៣. មិនត្រូវចាត់ទុកការស្រលាញ់ភេទដូចគ្នាជាបទល្មើសព្រហ្មទណ្ឌ

ច្បាប់ដែលចាត់ទុកជាបទល្មើសចំពោះការស្រលាញ់មនុស្សមានភេទដូចគ្នា បណ្តាលឲ្យមានការរំលោភបំពានដោយដាច់ឡែកពីគ្នាមួយចំនួន ប៉ុន្តែវាមានការទាក់ទងគ្នាទៅវិញទៅមក។ ច្បាប់បែបនេះ រំលោភបំពានសិទ្ធិរបស់បុគ្គលដែលរួចផុតពីការរើសអើង ដែលត្រូវបានចែងនៅក្នុងមាត្រា ២ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់នានា ក៏ដូចជាសិទ្ធិទទួលបានការពារពីការជ្រៀតជ្រែកដោយពុំសមហេតុផលលើសិទ្ធិឯកជន និង ការឃុំឃាំងដោយបំពាន ត្រូវបានការពារដោយមាត្រា ១២ និង ៩ នៃសេចក្តីប្រកាសជាសកល និងមាត្រា ១៧ និង ៩ នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ជាងនេះទៀតច្បាប់ដែលដាក់ទោសប្រហារជីវិតចំពោះអំពើរួមភេទ រំលោភបំពានលើសិទ្ធិរស់រានមានជីវិត ដូចដែលត្រូវបានធានាដោយមាត្រា ៣ នៃសេចក្តីប្រកាសជាសកល និងមាត្រា ៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ចំពោះច្បាប់បែបនេះទោះបីជាវាមិនធ្លាប់ត្រូវបានអនុវត្តក៏ដោយ ក៏វាបំពានកាតព្វកិច្ចរបស់រដ្ឋ ដូចមានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។



## សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

**មាត្រា ២៖** មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិ និង សេរីភាពទាំងអស់ដែលបានចែងនៅក្នុង សេចក្តីប្រកាសនេះដោយគ្មានការបែងចែកណាមួយមានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬ ទស្សនៈផ្សេងទៀត ដើមកំណើតជាតិ ឬ សង្គម ទ្រព្យសម្បតិ កំណើត ឬ ស្ថានភាពផ្សេងទៀតឡើយ ។

**មាត្រា ៧៖** ជនគ្រប់រូបមានស្មើភាពគ្នាចំពោះមុខច្បាប់ និង មានសិទ្ធិទទួលបានការការពារពីច្បាប់ស្មើៗគ្នាដោយគ្មានការរើសអើង។មនុស្សគ្រប់រូបមានសិទ្ធិទទួលការការពារស្មើៗគ្នាប្រឆាំងនឹងការរើសអើងណាដែលរំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំងនឹងការញុះញង់ឲ្យមានការរើសអើង។

**មាត្រា ៩៖** គ្មាននរណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬ និរទេសខ្លួនតាមអំពើចិត្តឡើយ ។

**មាត្រា១២៖** គ្មានមនុស្សណាម្នាក់ត្រូវរងការរំលោភជ្រៀតជ្រែកតាមអំពើចិត្តក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ការឆ្លើយឆ្លង ឬការធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ ។

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

**មាត្រា ២(១)៖** រដ្ឋភាគីនីមួយៗនៃកតិកាសញ្ញាបនេះសន្យាគោរព និងធានាជូនបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដីរបស់ខ្លួន និង ស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួននូវសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ដោយគ្មានការបែងចែកណាមួយមានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬ ទស្សនៈផ្សេងទៀត ដើមកំណើតជាតិ ឬ សង្គម ទ្រព្យសម្បត្តិ កំណើត ឬ ស្ថានភាពផ្សេងទៀតឡើយ។

**មាត្រា ៦(២)៖** នៅក្នុងប្រទេសទាំងឡាយដែលមិនទាន់បានលុបចោលទោសប្រហារជីវិត ការផ្តន្ទាទោសប្រហារជីវិតអាចត្រូវធ្វើឡើងទៅលើបទល្មើសធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ ដោយអនុលោមទៅតាមច្បាប់ជាធរមាន នៅក្នុងពេលប្រព្រឹត្តបទល្មើស និង មិនផ្ទុយទៅនឹងបទប្បញ្ញត្តិនៃកតិកាសញ្ញានេះ និង អនុសញ្ញាស្តីពីការបង្ការទប់ស្កាត់ និង ការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប៉ុណ្ណោះ។ ទោសប្បញ្ញត្តិនេះអាចត្រូវបានអនុវត្តដោយអនុលោមតែទៅតាមសាលក្រម ឬ សាលដីការស្ថាពរដែលសម្រេច ដោយតុលាការសមត្ថកិច្ចប៉ុណ្ណោះ។

**មាត្រា ៩៖** មនុស្សគ្រប់រូបមានសិទ្ធិមានសេរីភាព និង សន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឬ ការឃុំឃាំងដោយបំពានឡើយ។ គ្មានជនណាម្នាក់ត្រូវបានដកហូតសេរីភាពរបស់ខ្លួនបានឡើយលើកលែងតែមានហេតុផលនិងដោយអនុលោមតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ។

**មាត្រា ១៧៖** គ្មានជនណាម្នាក់ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬ ដោយខុសច្បាប់ក្នុងជីវភាពឯកជន គ្រួសារ លំនៅដ្ឋាន ឬ សំបុត្រឆ្លងឆ្លើយរបស់ខ្លួន និងត្រូវរងការប៉ះពាល់ដោយខុសច្បាប់ទៅលើកិត្តិយស និង កេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ។

**មាត្រា ២៦៖** ជនគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និង មានសិទ្ធិទទួលបានកិច្ចការពារពីច្បាប់ស្មើភាពគ្នាដោយគ្មានការរើសអើង។ ក្នុងប្រការនេះច្បាប់ត្រូវហាមឃាត់ការរើសអើង និង ត្រូវធានាឲ្យជនគ្រប់រូបនូវកិច្ចការពារដោយស្មើភាពគ្នា និង ប្រកបដោយប្រសិទ្ធភាពពីការរើសអើងដោយមូលហេតុដូចជា ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬ ទស្សនៈផ្សេងទៀត ដើម កំណើតជាតិ ឬ សង្គម ទ្រព្យសម្បត្តិ កំណើត ឬ ស្ថានភាពផ្សេងទៀត។

## គោលជំហររបស់យន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

យ៉ាងតិចប្រទេសចំនួន៧៦ មានច្បាប់ដែលកំពុងនៅជាធរមានដែលត្រូវបានប្រើប្រាស់ ដើម្បីកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះទំនាក់ទំនងផ្លូវភេទដោយមានការយល់ព្រមរវាងនីតិជនដែលមានភេទដូចគ្នា។[54] ច្បាប់បែបនេះជាទូទៅហាមឃាត់ប្រភេទខ្លះនៃសកម្មភាពផ្លូវភេទ ឬ ភាពស្និទ្ធស្នាលណាមួយ ឬ សកម្មភាពផ្លូវភេទរវាងមនុស្សមានភេទដូចគ្នា។ ក្នុងករណីខ្លះភាសាដែលត្រូវបានប្រើប្រាស់សំដៅ ទៅលើគោលគំនិតដែលមិនច្បាស់លាស់ និង មិនបានកំណត់ដូចជា "ឧក្រិដ្ឋកម្មប្រឆាំងនឹងច្បាប់ធម្មជាតិ" ឬ "សីលធម៌" ឬ "អំពើអនាចារ"។[55] អ្វីដែលច្បាប់ទាំងនេះមានលក្ខណៈរួមគឺការ ប្រើប្រាស់ច្បាប់ទាំងនេះដើម្បីយាយីរំខាន និង ចោទប្រកាន់បុគ្គលទាំងឡាយដោយសារតែទំនាក់ទំនងផ្លូវភេទ ឬអត្តសញ្ញាណជាក់ស្តែង ឬតាមការយល់ដឹងរបស់ពួកគេ ។[56]

*យ៉ាងតិច ប្រទេសចំនួន ៧៦ មានច្បាប់ដែលកំពុងនៅជាធរមាន ដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះការរួមភេទ ដោយមានការព្រមព្រៀងរវាងនីតិជនដែលមានភេទដូចគ្នា។*

ការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះការរួមភេទជាលក្ខណៈឯកជនដោយមានការព្រមព្រៀង រវាងនីតិជនដែលមានភេទ ដូចគ្នាល្មើសនឹងកាតព្វកិច្ចរបស់រដ្ឋដូចមានចែងក្នុងច្បាប់អន្តរជាតិក្នុងនោះ រួមមានកាតព្វកិច្ចក្នុងកិច្ចការពារសិទ្ធិឯកជន និង ធានាមិនឲ្យមានការរើសអើង។ នេះជាគោលជំហរឥតងាករេរបស់អ្នកជំនាញផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ចាប់តាំងតែពីឆ្នាំ១៩៩៤ នៅពេលដែលគណៈកម្មា ធិការសិទ្ធិមនុស្សបានសម្រេចលើ *រឿងក្តីរបស់ធូណិនទល់ជាមួយប្រទេសអូស្ត្រាលី*។

ករណីរបស់ធូណិន ពាក់ព័ន្ធនឹងការជំទាស់នឹងច្បាប់នៅក្នុងរដ្ឋតាស្មានីនៃប្រទេសអូស្ត្រាលី ដែលចាត់ទុកជាបទល្មើសចំពោះទំនាក់ទំនងផ្លូវភេទ ជាមួយនឹងមនុស្សមានភេទដូចគ្នាដែលមានការព្រមព្រៀង។ គណៈកម្មាធិការបានរកឃើញថាវា "មិនមានការគួរឲ្យសង្ស័យទេថាសកម្មភាពផ្លូវភេទដោយមាន ការព្រមព្រៀងគ្នារបស់នីតិជនដែលមានលក្ខណៈឯកជនត្រូវស្ថិតក្នុងវិសាលភាពនៃគោលគំនិតស្តីពីសិទ្ធិឯកជន" ដែលមានចែងនៅក្នុង មាត្រា១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ វាមិនមានបញ្ហាអ្វីទេថាលោកធូណិនជាដើមបណ្តឹងមិនធ្លាប់ត្រូវបានចោទប្រកាន់ទេ។ អត្ថិភាពនៃច្បាប់ព្រហ្មទណ្ឌ

[54] "ការស្អប់មនុស្សស្រលាញ់ភេទដូចគ្នាដែលត្រូវបានគាំទ្រដោយរដ្ឋៈ ការអង្កេតកម្រិតពិភពលោកលើច្បាប់ដែលចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះសកម្មភាពផ្លូវភេទដូចគ្នារវាងមនុស្សពេញវ័យដែលបានព្រមព្រៀងគ្នា" ដែលត្រូវបានធ្វើឡើងដោយសមាគមអន្តរជាតិបម្រើការងារផ្នែកស្រីស្រលាញ់ភេទដូចគ្នា ប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ អ្នកប្តូរភេទ និងអ្នកមានភេទពីរ (ILGA) នៅរដ្ឋធានីប្រ៊ុយសែល ខែ ឧសភា ឆ្នាំ ២០១១ ត្រង់ទំព័រទី ៩ ។

[55] សូមមើល A/HRC/10/21/Add.3 ត្រង់កថាខណ្ឌទី ៥៦-៥៨ ។

[56] ច្បាប់ទាំងនេះ ក៏អាចត្រូវបានប្រើប្រាស់នៅក្នុងកិច្ចខិតខំប្រឹងប្រែង "បោសសម្អាតសង្គម"។ សូមមើលឧទាហរណ៍ E/CN.4/1995/11 ត្រង់កថាខណ្ឌទី ៤៩ និង E/CN.4/2005/7 ត្រង់កថាខណ្ឌទី ៧១ ។

"ជ្រៀតជ្រែកជាបន្តបន្ទាប់ និង ដោយផ្ទាល់លើសិទ្ធិឯកជនរបស់ដើមបណ្តឹង"។[57] ដូចមានចែងក្នុងមាត្រា១៧ បុគ្គលទាំងឡាយត្រូវបានការពារពី "ការជ្រៀតជ្រែកដោយបំពាន ឬ ដោយខុសច្បាប់" លើសិទ្ធិឯកជនរបស់ពួកគេ។ "ការជ្រៀតជ្រែកដោយបំពាន"អាចជាការជ្រៀតជ្រែកដែលត្រូវបានចែងដោយច្បាប់ដែលមិនបំពេញលក្ខខណ្ឌ "ស្របទៅតាមបទប្បញ្ញត្តិគោលបំណង និង គោលដៅនៃកតិកាសញ្ញា" និង "សមហេតុផលនៅក្នុងស្ថានភាពពិសេស"។[58] គណៈកម្មាធិការបានបកស្រាយអំពី "លក្ខខណ្ឌសមហេតុផលក្នុងការបញ្ជាក់ថាការជ្រៀតជ្រែកលើសិទ្ធិឯកជនត្រូវតែសមាមាត្រនឹងគោលដៅដែលត្រូវបានស្វែងរក និង មានលក្ខណៈចាំបាច់នៅក្នុងស្ថានភាពនៃករណីជាក់លាក់ណាមួយ។[59] ករណីនេះបានសន្និដ្ឋានថាច្បាប់នៅតាស្មានីមិនមានសមាមាត្រ ឬ ចាំបាច់ទេ។ វាមិនសម្រេចគោលបំណងនៃកិច្ចការពារសុខភាពសាធារណៈ ហើយវាមិនចាំបាច់ក្នុងកិច្ចការពារសីលធម៌សាធារណៈ ដូចដែលបានបង្ហាញដោយការពិតដែលថា ច្បាប់ដែលចាត់ទុកជាបទល្មើសចំពោះការស្រលាញ់មនុស្សមានភេទដូចគ្នា ត្រូវបានលុបចោលនៅតំបន់ផ្សេងទៀតនៃ ប្រទេសអូស្រ្តាលី និងមិនត្រូវបានអនុវត្តនៅក្នុងរដ្ឋតាស្មានីឡើយ ។[60]

ចាប់តាំងពីពេលដែលករណីរបស់*ធូណិន* ត្រូវបានសម្រេច អង្គការសន្ធិសញ្ញាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានជំរុញម្តងហើយម្តងទៀតឲ្យរដ្ឋទាំងឡាយធ្វើកំណែទម្រង់ច្បាប់ដែលចាត់ជាបទល្មើសចំពោះការស្រលាញ់ភេទដូចគ្នាឬ ទំនាក់ទំនងផ្លូវភេទរវាងដៃគូដែលមានភេទដូចគ្នានិងក៏បានទទួលស្វាគមន៍ការលុបចោលច្បាប់បែបនេះតាមអំណាចនីតិប្បញ្ញត្តិ ឬ តាមអំណាចតុលាការ។[61] ឧទាហរណ៍ នៅក្នុងករណីរបស់ប្រទេសឈីលី គណៈកម្មាធិការបានថ្លែងថា:

[57]កថាខណ្ឌទី ៨.២ នៃសេចក្តីសម្រេចលេខ 488/1992, CCPR/C/50/D/488/1992 ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ១៩៩៤ របស់គណៈកម្មាធិការសិទ្ធិ-មនុស្ស ចំពោះរឿងក្តីរបស់ *ធូណិន ទល់ជាមួយអូស្រ្តាលី*។

[58]សេចក្តីពន្យល់ទូទៅលេខ ១៦ នៃគណៈកម្មាធិការសិទ្ធិមនុស្ស (សិទ្ធិទទួលបានការគោរពលើសិទ្ធិឯកជន គ្រួសារ លំនៅឋាន និងសំណេរទាក់ទងគ្នា និងកិច្ចការពារលើកិត្តិយស និងកិត្តិស័ព្ទ) ។

[59]រឿងក្តីរបស់*ធូណិនទល់ជាមួយអូស្រ្តាលី* ត្រង់កថាខណ្ឌទី ៨.៣ ។

[60] ដូចយោងខាងលើ ត្រង់កថាខណ្ឌទី ៨.៥ និង ៨.៦ ។

[61] សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់តូហ្គូ (CCPR/C/TGO/CO/4) ត្រង់កថាខណ្ឌទី ១៤ សម្រាប់អ៊ូបេគីស្ថាន (CCPR/C/UZB/CO/3) ត្រង់កថាខណ្ឌទី ២២ សម្រាប់ហ្រ្គេណាដា (CCPR/C/GRC/CO/1) ត្រង់កថាខណ្ឌទី ២១ សហភាពសាធារណរដ្ឋតង់ហ្សានី (CCPR/C/TZA/CO/4) ត្រង់កថាខណ្ឌទី ២២ សម្រាប់ប្រទេសបូស្វ៉ាន់ណា (CCPR/C/BWA/CO/1) ត្រង់កថាខណ្ឌទី ២២៖ សេន វ៉ាំងសង់ និង ហ្រ្គេណាឌីន (CCPR/C/VCT/CO/2) សម្រាប់ប្រទេសអាល់ស៊េរី (CCPR/C/DZA/CO/3) ត្រង់កថាខណ្ឌទី ២៦ សម្រាប់ប្រទេសឈីលី (CCPR /C/CHL/CO/5) ត្រង់កថាខណ្ឌទី ១៦ សម្រាប់បាបាដូស (CCPR/C/BRB/CO/3) ត្រង់កថាខណ្ឌទី ១៣ សម្រាប់សហរដ្ឋអាមេរិក (CCPR /C/USA/CO/3) ត្រង់កថាខណ្ឌទី ៩ សម្រាប់ប្រទេសកេនយ៉ា (CCPR/C/ CO/83/KEN) ត្រង់កថាខណ្ឌទី ២៧ សម្រាប់ប្រទេសអេស៊ីប (CCPR /CO/76/EGY) ត្រង់កថាខណ្ឌទី ១៩ សម្រាប់ប្រទេសរ៉ូម៉ានី (CCPR/C/79/Add.111) ត្រង់កថាខណ្ឌទី ១៦ សម្រាប់ឡេសូតូ (CCPR/C/79/Add.106) ត្រង់កថាខណ្ឌទី ១៣ សម្រាប់ប្រទេសអេក្វាឌ័រ (CCPR/C/79/Add.92) ត្រង់កថាខណ្ឌទី ៨ សម្រាប់ស៊ីព្រូស (CCPR/C/79 Add.88) ត្រង់កថាខណ្ឌទី ១១ សហរដ្ឋអាមេរិក (A/50/40) ត្រង់កថាខណ្ឌទី ២៨៧ ។ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ សម្រាប់ប្រទេសគើជីស្ថាន (E/C.12/Add.49) ត្រង់កថាខណ្ឌទី ១៧ និង ៣០ សម្រាប់ស៊ីព្រូស (E/C.12/1/Add.28) ត្រង់កថាខណ្ឌទី ៧។ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការលុបបំបាត់ចោលការរើសអើងចំពោះស្ត្រីសម្រាប់ប្រទេសអ៊ូហ្គាន់ដា (CEDAW/C/UGA/CO/7) ត្រង់

*ការបន្តសុពលភាពនៃច្បាប់ដែលចាត់ទុកជាបទល្មើសចំពោះទំនាក់ទំនងការស្រលាញ់មនុស្សមានភេទដូចគ្នារវាងនីតិជនតាមការព្រមព្រៀងចូលរួមពាក់ព័ន្ធនឹងការរំលោភបំពានលើសិទ្ធិឯកជន ដែលត្រូវបានការពារដូចមានចែងនៅក្នុងមាត្រា១៧ នៃកតិកាសញ្ញានិងអាចពង្រឹងឥរិយាបថ នៃការរើសអើងរវាងមនុស្សនិងមនុស្សដោយសារទំនោរផ្លូវភេទ។ ហេតុដូច្នេះ ច្បាប់គួរតែត្រូវបានធ្វើវិសោធនកម្ម ដើម្បីលុបបំបាត់ចោលបទល្មើស រួមភេទតាមទ្វារលាមករវាងនីតិជន ។*[62]

រយៈពេលពីរបីឆ្នាំក្រោយមកគណៈកម្មាធិការបានកត់សំគាល់ដោយក្តីពេញចិត្តថាច្បាប់នៅ ប្រទេសឈីលី ចាត់ទុកជាបទល្មើសចំពោះទំនាក់ទំនងការស្រលាញ់មនុស្សមានភេទដូចគ្នារវាងនីតិជនតាមការព្រមព្រៀងគ្នាត្រូវបានលុបចោល ។[63]

ស្រដៀងគ្នានេះដែរ នៅក្នុងករណីរបស់ប្រទេសកាមេរូន គណៈកម្មាធិការបានថ្លែងថាៈ

*គណៈកម្មាធិការនៅតែខ្វល់ខ្វាយយ៉ាងជ្រាលជ្រៅអំពីការចាត់ទុកជាបទល្មើសចំពោះសកម្មភាពផ្លូវភេទដោយមានការព្រមព្រៀងរវាងនីតិជនដែលមានភេទដូចគ្នា...។ដូចដែលគណៈកម្មាធិការ និង យន្តការសិទ្ធិមនុស្សអន្តរជាតិផ្សេងទៀត បានដៅបញ្ជាក់ហើយថា ការចាត់ទុកជាអំពើបទល្មើសបែបនេះ រំលោភបំពានលើសិទ្ធិឯកជន និង សេរីភាពដោយគ្មានការរើសអើងដែលត្រូវបានចែង នៅក្នុងកតិកាសញ្ញា...។រដ្ឋភាគីគួរតែចាត់វិធានការបន្ទាន់ឆ្ពោះទៅរកការមិនចាត់ទុកជាបទល្មើសចំពោះសកម្មភាពផ្លូវភេទដោយមានការព្រមព្រៀងគ្នារវាងមនុស្សពេញវ័យដែលមានភេទដូចគ្នា ដើម្បីរៀបចំច្បាប់របស់ខ្លួន ឲ្យស្របទៅនឹងកតិកាសញ្ញានេះ ។*[64]

*ការចាត់ទុកជាបទល្មើសចំពោះទំនាក់ទំនងផ្លូវភេទរវាងមនុស្សមានភេទដូចគ្នាដោយមានការព្រមព្រៀងគ្នារបស់នីតិជន រំលោភបំពាននឹងកាតព្វកិច្ចរបស់រដ្ឋ ដូចមានចែងក្នុងច្បាប់អន្តរជាតិក្នុងនោះរួមមានកាតព្វកិច្ចក្នុងកិច្ចការពារសិទ្ធិឯកជន និងការធានាមិនឲ្យមានការរើសអើង ។*

ចំពោះសហរដ្ឋអាមេរិកជាដំបូងគណៈកម្មាធិការបានសម្តែងនូវកង្វល់អំពី "ការរំលោភបំពានដ៏ខ្លាំងក្លាលើជីវិតឯកជន" នៅក្នុងរដ្ឋទាំងនោះដែលមានទោសព្រហ្មទណ្ឌចំពោះសកម្មភាពផ្លូវភេទរវាងមនុស្សភេទដូចគ្នាដោយមានការព្រមព្រៀងគ្នានិងផលវិបាកនៃច្បាប់បែបនេះ ចំពោះ"ការទទួលបានសិទ្ធិមនុស្សផ្សេងទៀត ដោយគ្មានការរើសអើង។[65] ក្រោយមក នៅពេលដែលតុលាការកំពូល នៃសហរដ្ឋអាមេរិកបានសម្រេច

កថាខណ្ឌទី ៤៣-៤៤ សម្រាប់ប្រទេសគើជីស្ថាន (A/54/38) ត្រង់កថាខណ្ឌទី ១២៧ និង ១២៨ ។ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារសម្រាប់ ប្រទេសឈីលី (CRC/C/CHL/CO/3) ត្រង់កថាខណ្ឌទី២៩ ។

[62]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសឈីលី (CCPR/”C/79/Add.104) ត្រង់កថាខណ្ឌទី ២០ ។

[63]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសឈីលី (CCPR/”C/CHL/CO/5) ត្រង់កថាខណ្ឌទី ១៦ ។

[64] សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសកាមេរូន (CCPR/C/CMR/CO/4) ត្រង់កថាខណ្ឌទី ១២ ។

[65]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់សហរដ្ឋអាមេរិក (A/50/40) ត្រង់កថាខណ្ឌទី ២៨៧ ។

ថាច្បាប់បែបនេះមិនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញនៅក្នុងរឿងក្តីរបស់ *ឡូវរិនស៍ ទល់ជាមួយតិចសាស់* គណៈកម្មាធិការបានទទួលស្វាគមន៍ការសម្រេចនេះ។[66] នៅពេលដែលគណៈកម្មាធិការសង្កេតលើករណីរបស់*ធូណិន* សិទ្ធិឯកជននិងសិទ្ធិមិនត្រូវ បានរើស អើងរបស់បុគ្គលត្រូវបានរំលោភបំពានទោះបីជាច្បាប់ដែលត្រូវបានពិភាក្សាមិនធ្លាប់ត្រូវបានអនុវត្តក៏ដោយ។ នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួនសម្រាប់ប្រទេសអេត្យូពី គណៈកម្មាធិការបានថ្លែងថាៈ "កង្វល់របស់គណៈកម្មាធិការ មិនត្រូវបានជម្រះបំបាត់តាមរយៈព័ត៌មានដែលត្រូវបានផ្តល់ដោយរដ្ឋភាគី ដែលបទប្បញ្ញត្តិ ដែលកំពុងពិភាក្សា មិនត្រូវបានអនុវត្តជាក់ស្តែងឡើយ" ។[67]

នៅក្នុងប្រទេសខ្លះដែលមិនបានចាត់ទុកជាបទល្មើសចំពោះទំនាក់ទំនងផ្លូវភេទដោយមានការព្រមព្រៀងគ្នារបស់នីតិជននៅតែមាននីតិភាពនៃការរួមភេទខុសៗគ្នាចំពោះទំនាក់ទំនងផ្លូវភេទរវាងមនុស្សភេទដូចគ្នា និង ភេទផ្ទុយគ្នា។ យុវជនដែលមានទំនាក់ទំនងផ្លូវភេទដូចគ្នា អាចទទួលរងនូវទោសព្រហ្មទណ្ឌ ចំណែកឯយុវជនដែលមានទំនាក់ទំនងផ្លូវភេទផ្ទុយគ្នាមិនទទួលរងនូវទោសព្រហ្មទណ្ឌទេ។ ដូចដែល គណៈកម្មការសន្ធិសញ្ញាបានបង្ហាញឲ្យឃើញនីតិភាពនៃការរួមភេទខុសៗគ្នា គឺជាការរើសអើងដោយឈរលើមូលដ្ឋាន ទំនោរផ្លូវភេទ ។[68]

[66]CCPR/C/USA/CO/3 ត្រង់កថាខណ្ឌទី ៩ ។

[67]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសអេត្យូពី (CCPR/C/ETH/CO/1) ត្រង់កថាខណ្ឌទី ១២ ។

[68]ការព្រមព្រៀងរបស់មនុស្សវ័យខុសគ្នាៈ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារសម្រាប់ប្រទេសឈីលី (CRC/C/CHL/CO/3) ត្រង់កថាខណ្ឌទី ២៩ សម្រាប់កោះមែន ចក្រភពអង់គ្លេស (CRC/C/15/Add.134) ត្រង់កថាខណ្ឌទី ២២ សម្រាប់ប្រទេសអូទ្រីស (CRC/C/79/Add.103) ត្រង់កថាខណ្ឌទី ១៣ ។



អ្នករាយការណ៍ពិសេស និងក្រុមការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ដែលត្រូវបានដឹងជាទូទៅថាជាយន្តការនីតិវិធីពិសេសជាញឹកញាប់បានសម្តែងនូវកង្វល់អំពីការចាត់ទុកជាបទល្មើសចំពោះទំនាក់ទំនងផ្លូវភេទរវាងមនុស្សមានភេទដូចគ្នា។ យន្តការនីតិវិធីពិសេសទាំងនោះ បានសុំឲ្យយកចិត្តទុកដាក់លើរបៀបដែលតាមរយៈនេះ ការចាត់ទុកជាបទល្មើសចំពោះ ការស្រលាញ់មនុស្សភេទដូចគ្នាធ្វើឲ្យត្រឹមត្រូវតាមច្បាប់នូវបុរេនិច្ឆ័យ និង ជំរុញឲ្យមនុស្សប្រឈមនឹង ឧក្រិដ្ឋកម្មរើសអើង ការរំលោភបំពានរបស់នគរបាល ការធ្វើទារុណកម្ម និងអំពើហិង្សាក្នុងគ្រួសារ។[69] ឧទាហរណ៍ៈ អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅប្រព័ន្ធតុលាការដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ ឬ ដោយបំពានបានកត់សំគាល់ថា "ការចាត់ទុកជាអំពើឧក្រិដ្ឋចំពោះបញ្ហានៃទំនោរផ្លូវភេទ" បានបង្កើនការធ្វើឲ្យមាន ស្លាក

[69]សូមមើលឧទាហរណ៍ៈរបាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស (E/CN.4/2002/16/Add.1) ត្រង់កថាខណ្ឌទី ១៥៤។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រី (E/CN.4/1999/68) ត្រង់កថាខណ្ឌទី ១៥។ សូមមើលផងដែរ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការធ្វើទារុណកម្មៈ C/CN.4/2002/76 និងA/56/156 ត្រង់កថាខណ្ឌទី ១៨-២៥ ។

ស្អាមទុយ៍សនៅក្នុងសង្គម និង ធ្វើឲ្យមនុស្ស "កាន់តែងាយរងគ្រោះដោយសារអំពើហិង្សា និង ការរំលោភបំពានសិទ្ធិមនុស្ស ក្នុងនោះរួមមានការគំរាមកំហែងដល់អាយុជីវិត និងការរំលោភបំពានសិទ្ធិរស់រានមានជីវិតដែលជារឿយៗ ត្រូវបានប្រព្រឹត្តនៅក្នុងបរិយាកាសនិទ្ទណ្ឌភាព" ។[70]

នៅពេលដែលប្រទេសប៊ូរុនឌី កំពុងស្ថិតនៅក្នុងដំណើរការពិចារណារ អំពីសេចក្តីព្រាងច្បាប់ដែលចាត់ទុក ជាអំពើបទល្មើសព្រហ្មទណ្ឌចំពោះ ទំនាក់ទំនងផ្លូវភេទរវាងមនុស្សមានភេទដូចគ្នា អ្នកទទួលអាណត្តិនៃយន្តការនីតិវិធីពិសេសចំនួនបួនរូបបានផ្ញើលិខិតរួមមួយដែលជំរុញឲ្យព្រឹទ្ធសភាទទួលស្គាល់ថា សេចក្តីព្រាងច្បាប់ ដែលមានលក្ខណៈផ្ទុយទៅនឹងច្បាប់ សិទ្ធិមនុស្សអន្តរជាតិ នឹង មានឥទ្ធិពលអវិជ្ជមានលើកិច្ចខិតខំប្រឹងប្រែងរបស់ជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ និង ធ្វើឲ្យអ្នកការពារសិទ្ធិមនុស្សផ្នែកមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរ ភេទ (LGBT) ធ្លាក់ទៅក្នុងស្ថានភាពងាយរងគ្រោះជាគោលដៅដ៏មានសក្តានុពលនៃការវាយប្រហារនិង អំពើបំភិតបំភ័យដោយទាំងអាជ្ញាធរ និង សាធារណជន ។[71]

នៅក្នុង ៥ ប្រទេសក្នុងចំណោមប្រទេសចំនួន ៧៦ ក៏ដូចជាតំបន់ខ្លះនៃប្រទេសយ៉ាងតិចចំនួនពីរ (២)ផ្សេងទៀត ទោសប្រហារជីវិតអាចត្រូវបានអនុវត្តចំពោះបទល្មើសពាក់ព័ន្ធនឹងការស្រលាញ់មនុស្សភេទដូចគ្នា។[72] បន្ថែមទៅលើការពិតដែលថាការចាត់ទុកជាអំពើបទល្មើសព្រហ្មទណ្ឌ ចំពោះទំនាក់ទំនងផ្លូវភេទដោយមានការព្រមព្រៀងគ្នារបស់មនុស្សមានភេទដូចគ្នា រំលោភបំពានលើសិទ្ធិឯកជន និង ការមិនរើសអើង ការដាក់ទោសប្រហារជីវិតបណ្តាលឲ្យមានការរំលោភបំពានដាច់ដោយឡែក ដូចមានចែងនៅក្នុងមាត្រា ៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ និង មាត្រា៣ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ មាត្រា៦ចែងថានៅក្នុងប្រទេសដែលមិនបានលុបចោលទោសប្រហារជីវិត"ការផ្តន្ទាទោសប្រហារជីវិតអាចត្រូវបានដាក់តែទៅលើអំពើឧក្រិដ្ឋធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ"។ បទល្មើសផ្លូវភេទ ក្នុងនោះរួមមានទំនាក់ទំនងផ្លូវភេទរបស់មនុស្សមានភេទដូចគ្នា មិនមានលក្ខណៈគ្រប់គ្រាន់ជា"អំពើឧក្រិដ្ឋធ្ងន់ធ្ងរបំផុតនោះទេ"។ សេចក្តីសម្រេចជាបន្តបន្ទាប់របស់អតីតគណៈកម្មការសិទ្ធិមនុស្សបានអំពាវនាវឲ្យរដ្ឋទាំងឡាយ ធានា

[70]របាយការណ៍របស់អ្នករាយការណ៍ពិសេសនៃគណៈកម្មាធិការសិទ្ធិមនុស្សទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ ឬ ដោយបំពាន (A/57/138) ត្រង់កថាខណ្ឌទី ៣៧ ។

[71]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស (A/HRC/10/12/Add.1) ត្រង់កថាខណ្ឌទី ៣៥៣ ។

[72]ប្រទេសទាំងប្រាំ (៥) មានដូចជា សាធារណរដ្ឋអ៊ីស្លាមអៀរ៉ង់ ប្រទេសម៉ូរីតានី ប្រទេសអារ៉ាប់ប៊ីសាអូឌីត ប្រទេសស៊ូដង់ និងប្រទេសយេម៉ែន ។ សូមមើល"ការស្អប់មនុស្សស្រលាញ់ភេទដូចគ្នាដែលត្រូវបានគាំទ្រដោយរដ្ឋៈ ការអង្កេតកម្រិតពិភពលោកលើច្បាប់ដែលចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះសកម្មភាពផ្លូវភេទដោយមនុស្សមានភេទដូចគ្នារវាងមនុស្សពេញវ័យដែលបានព្រមព្រៀងគ្នា"ដែលត្រូវបានធ្វើឡើងដោយសមាគមអន្តរជាតិបម្រើការងារផ្នែកស្រីស្រលាញ់ភេទដូចគ្នា ប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ អ្នកប្តូរភេទ និងអ្នកមានភេទពីរ (ILGA) នៅរដ្ឋធានីប្រ៊ុយសែល ខែ ឧសភា ឆ្នាំ ២០១១ ត្រង់ទំព័រទី ១០ ។

ថា "ទោសប្រហារជីវិតមិនត្រូវបានដាក់ទៅលើសកម្មភាពដែលមិនមែនជាអំពើហិង្សាដូចជា.......ទំនាក់ទំនងផ្លូវភេទរវាងមនុស្សពេញវ័យដែលមានការព្រមព្រៀងគ្នានោះទេ ។[73]

ការងាររបស់អង្គការសន្ធិសញ្ញា និងយន្តការនីតិវិធីពិសេសបញ្ជាក់អំពីគោលការណ៍នេះ។[74] ពាក់ព័ន្ធនឹងប្រទេសស៊ូដង់ គណៈកម្មាធិការបានថ្លែងថា:

*ការដាក់ទោសប្រហារជីវិតនៅក្នុងរដ្ឋជាភាគីទៅលើអំពើល្មើសដែលមិនអាចត្រូវបានកំណត់លក្ខណៈជាបទល្មើសធ្ងន់ធ្ងរបំផុតក្នុងនោះរួមមានការគៃបន្លំប្រាក់របស់មន្ត្រីអំពើប្លន់ដោយមានប្រើហិង្សា និងការជួញដូរគ្រឿងញៀនក៏ដូចជាការអនុវត្តដែលមិនគួរត្រូវបានចាត់ទុកជាអំពើឧក្រិដ្ឋដូចជាសកម្មភាពផ្លូវភេទដូចគ្នារបស់មនុស្សប្រភេទទីបីនិងការរួមភេទខុសច្បាប់មានលក្ខណៈមិនស្របជាមួយនឹងមាត្រា ៦ នៃកតិកាសញ្ញា។[75]*

អ្នករាយការណ៍ពិសេសបានទាញការយកចិត្តទុកដាក់អំពីការដាក់ទោសប្រហារជីវិតដែលជាការរំលោភបំពានលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ នៅក្នុងរបាយការណ៍ឆ្នាំ២០០០របស់ខ្លួន អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ ឬ ដោយបំពានបានពិពណ៌នាអំពីបញ្ហាដូចខាងក្រោម:

*វាជាបុព្វហេតុនៃកង្វល់ដ៏ខ្លាំងក្លាដែលនៅក្នុងរដ្ឋខ្លះទំនាក់ទំនងផ្លូវភេទដូចគ្នានៅតែត្រូវបានដាក់ទោសរហូតដល់ស្លាប់។ វាត្រូវតែបានរំឭកឡើងវិញថា ដូចមានចែងក្នុងមាត្រា៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ការផ្តន្ទាទោសប្រហារជីវិតអាចត្រូវបានដាក់តែលើអំពើឧក្រិដ្ឋធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ ជាបញ្ញត្តិដែលដកចេញយ៉ាងច្បាស់អំពីបញ្ហាទំនោរផ្លូវភេទ ។[76]*

ដោយផ្តល់យោបល់អំពីការអនុវត្តច្បាប់សាសនាមូស្លីមនៅក្នុងផ្នែកជាច្រើននៃប្រទេសនីសេរីយ៉ា អ្នករាយការណ៍ពិសសទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ ឬ ដោយបំពានបានថ្លែងថា: "ទាក់ទងទៅនឹងការរួមភេទតាមទ្វារលាមក ការដាក់ទោសប្រហារជីវិតលើទំនាក់

---

[73]សេចក្តីសម្រេចរបស់គណៈកម្មការសិទ្ធិមនុស្ស (ស្តីពីបញ្ហាទោសប្រហារជីវិត)៖ E/CN.4/RES/2005/59 ត្រង់កថាខណ្ឌទី ៥ E/CN.4/RES/2004/67 ត្រង់កថាខណ្ឌទី ៤ E/CN.4/RES/2003/67 ត្រង់កថាខណ្ឌទី ៤ E/CN.4/RES/2002/77 ត្រង់កថាខណ្ឌទី ៤ ។

[74]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសស៊ូដង់ (CCPR/C/79/Add.85) ត្រង់កថាខណ្ឌទី ៨ ។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ ឬ ដោយបំពានៈ A/HRC/14/24/Add.1 ត្រង់កថាខណ្ឌទី ៤៥០-៤៥១ E/CN.4/2006/53/Add.2 ត្រង់កថាខណ្ឌទី ២ E/CN.4/2006/53/Add.4 ត្រង់កថាខណ្ឌទី ២៦ ៣៥ ៣៧ និង ១០៤ E/CN.4/2002/74 ត្រង់កថាខណ្ឌទី ៦៥ ។

[75]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសស៊ូដង់ (CCPR/C/SDN/CO/3) ត្រង់កថាខណ្ឌទី ១៩ ។

[76]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ ឬ ដោយបំពានៈ (E/CN.4/2000/3) ត្រង់កថាខណ្ឌទី ៥៧ ។

ទំនងផ្លូវភេទឯកជនមានលក្ខណៈមិនស្របយ៉ាងច្បាស់លាស់ជាមួយនឹងកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសនីសេរីយ៉ា"។[77] នៅពេលដែលប្រទេសនីសេរីយ៉ាបានឆ្លើយតបថា មានការផ្អាកជាបណ្តោះអាសន្នតាមអង្គហេតុចំពោះការប្រហារជីវិតអ្នករាយការណ៍ពិសេសបានគូសបញ្ជាក់ថា"មានតែលទ្ធភាពទេដែលអាចត្រូវបានប្រើប្រាស់គំរាមកំហែងដល់ជនជាប់ចោទអស់រយៈពេលជាច្រើនឆ្នាំ និង ជាទម្រង់នៃប្រព្រឹត្តកម្មដ៏ឃោរឃៅអមនុស្សធម៌ ឬ ថោកទាប ឬ ការដាក់ទណ្ឌកម្ម។ ស្ថានភាពរបស់វាដែលជាច្បាប់ធ្វើយុត្តិកម្មចំពោះការធ្វើទុក្ខបុកម្នេញដែលបង្កឡើងដោយក្រុមអ្នកការពារ និង បណ្តាលឲ្យមានការរំលោភបំពាន" ។[78]

អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបានសុខភាពផ្លូវកាយ និងផ្លូវចិត្តតាមបទដ្ឋានខ្ពស់បំផុត នៅក្នុងរបាយការណ៍ឆ្នាំ ២០១០ របស់គាត់ដែលត្រូវបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សថ្លែងថា:

> *អ្នករាយការណ៍ពិសេសមានការជឿជាក់ថា ការដាក់ទោសប្រហារជីវិតលើទំនាក់ទំនងផ្លូវភេទដោយមានការព្រមព្រៀងគ្នារបស់មនុស្សមានភេទដូចគ្នា មិនត្រឹមតែគ្មានមនសិការប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងជាការដកហូតសិទ្ធិរស់រានមានជីវិតដោយបំពានទៀតផងដែលជាការរំលោភបំពានលើសិទ្ធិរស់រានមានជីវិត ដែលត្រូវបានទទួលស្គាល់នៅក្នុងមាត្រា ៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ។[79]*

កង្វល់មួយទៀតដែលត្រូវបានសម្តែងចេញនៅក្នុងបរិបទនៃការចាត់ទុកជាអំពើបទល្មើសចំពោះទំនាក់ទំនងផ្លូវភេទដូចគ្នា គឺការចាប់ខ្លួន និងការឃុំខ្លួនដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ។ ទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ និង សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សធានាដល់សិទ្ធិរួចផុតពីការចាប់ខ្លួន ឬ ការឃុំខ្លួនដោយបំពាន។ ក្រុមការងារប្រឆាំងនឹងការឃុំខ្លួនដោយបំពានបានអះអាងដោយឥតងាករេថា ការឃុំខ្លួនបុគ្គលដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទរបស់ខ្លួនត្រូវបានហាមឃាត់ដោយច្បាប់អន្តរជាតិ ។

នៅក្នុងឆ្នាំ ២០១២ ក្រុមការងារបានពិចារណាលើរឿងក្តីមួយពាក់ព័ន្ធនឹងបុរស ៥៥នាក់ ដែលត្រូវបានចាប់ខ្លួននៅកន្លែងរាំច្រៀងនៅលើទូកលើទន្លេនីល។ ជនជាប់ឃុំត្រូវបានចោទប្រកាន់ពី "ការប្រព្រឹត្តអំពើអនាចារ" និង "ការបែកបាក់គ្នានៅក្នុងសង្គម"។ ក្រុមការងារបានសន្និដ្ឋានថាការចាប់ខ្លួនដោយឈរលើមូល

---

[77]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ ឬ ដោយបំពានៈ (E/CN.4/2006/53/Add.4) ត្រង់កថាខណ្ឌទី ៣៧ ។

[78]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ ឬ ដោយបំពានៈ (A/HRC/8/3/Add.3) ត្រង់កថាខណ្ឌទី ៧៦ ។

[79]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិរបស់មនុស្សរាល់រូបក្នុងការទទួលបានសុខភាពផ្លូវកាយ និងផ្លូវចិត្តតាមស្តង់ដាដែលអាចសម្រេចបានខ្ពស់បំផុត (A/HRC/14/20) ត្រង់កថាខណ្ឌទី ២០ ។

ដ្ឋាននេះ មានលក្ខណៈរើសអើងដែលជាការរំលោភបំពានលើមាត្រា ២ និង ២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ និងថាហេតុដូច្នេះការឃុំខ្លួនមានលក្ខណៈបំពាន។[80] នៅក្នុងឆ្នាំ ២០០៦ ក្រុមការងារបានចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងការចាប់ខ្លួនបុរសចំនួន ១១នាក់ នៅក្នុងប្រទេសកាមេរូន ដូចមានចែងនៅក្នុងមាត្រា ៣៤៧ ស្ទួននៃក្រមព្រហ្មទណ្ឌ ដែលចាត់ទុកជាអំពើបទល្មើសចំពោះទំនាក់ទំនងផ្លូវភេទរវាងមនុស្សមានភេទដូចគ្នា។ ជានិច្ចកាល ក្រុមការងារបានរកឃើញថាការឃុំខ្លួនមានលក្ខណៈ បំពាន ដែលជាការរំលោភបំពានលើច្បាប់អន្តរជាតិ។ ក្រុមការងារ បានថ្លែងថាៈ

> *អត្ថិភាពនៃច្បាប់ដែលចាត់ទុកជាបទល្មើសចំពោះការប្រព្រឹត្តផ្លូវភេទដូចគ្នារវាងមនុស្សពេញវ័យមានការព្រមព្រៀងគ្នាជាលក្ខណៈឯកជន និង ការអនុវត្តទោសព្រហ្មទណ្ឌចំពោះមនុស្សដែលត្រូវបាន ចោទប្រកាន់ពីបទប្រព្រឹត្តបែបនេះ រំលោភបំពានលើសិទ្ធិឯកជន និង សេរីភាពរួចផុតពីការរើសអើង ដូចមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ។ ហេតុដូច្នេះហើយ ក្រុមការងារនេះពិចារណាថា ...ការចាត់ទុកជា<u>បទល្មើស</u>ចំពោះការស្រលាញ់មនុស្សភេទដូចគ្នានៅក្នុងច្បាប់របស់កាមេរូន មានលក្ខណៈមិនស្របជាមួយនឹងមាត្រា ១៧ និងមាត្រា ២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ពោលគឺជា លិខិតុបករណ៍ ដែលប្រទេសកាមេរូនបានផ្តល់សច្ចាប័ន ។*[81]

ក្រុមការងារបានលើកឡើងដដែលៗអំពីសេចក្តីសន្និដ្ឋានទាំងនេះក្នុងករណីដែលទើបតែមានថ្មីៗនេះ។[82] ឧទាហរណ៍ ពាក់ព័ន្ធនឹងការចាប់ខ្លួន និងការកាត់ទោសបុរសចំនួនបួននាក់ពីបទប្រព្រឹត្តអំពើអនាចារនៅក្នុងស្រុកអាគូហ្សា ប្រទេសអេស៊ីប ក្រុមការងារបានថ្លែងថាៈ "ការបង្ខូចកេរ្តិ៍ឈ្មោះ និងការធ្វើទុក្ខបុកម្នេញលើមនុស្សដោយសារតែ ទំនាក់ទំនងផ្លូវភេទរបស់ពួកគេ ជាការរំលោភបំពានលើគោលការណ៍ច្បាប់សិទ្ធិមនុស្សអន្តរជាតិ"។[83] ស្រដៀងគ្នានេះដែរ នៅក្នុងករណីរបស់សាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ គណៈកម្មាធិការសិទ្ធិ មនុស្សបានអំពាវនាវដល់រដ្ឋជាភាគីឲ្យ "ធានាថា នរណាម្នាក់ក៏ដោយដែលត្រូវបានឃុំខ្លួនដោយសារតែសកម្មភាពផ្លូវភេទដែលមានការព្រមព្រៀងដោយសេរី និងទៅវិញទៅមក ឬ ទំនោរផ្លូវភេទ គួរតែត្រូវបានដោះលែងជាបន្ទាន់ និងដោយឥតលក្ខខ័ណ្ឌ ។[84]

---

[80]សេចក្តីសម្រេចលេខ ៧/២០០២ របស់ក្រុមការងារប្រឆាំងនឹងការឃុំឃាំងបំពាន សម្រាប់ប្រទេសអេស៊ីប (E/CN.4/2003/8/Add.1) ។

[81]សេចក្តីសម្រេចលេខ ២២/២០០៦ របស់ក្រុមការងារប្រឆាំងនឹងការឃុំឃាំងបំពាន សម្រាប់ប្រទេសកាមេរូន (A/HRC/4/40/Add.1) ត្រង់កថាខណ្ឌទី ១៩ ។

[82]ក្រុមការងារប្រឆាំងនឹងការឃុំឃាំងបំពាន បានចេញសេចក្តីសម្រេចលេខ ៤២/២០០៨ សម្រាប់ប្រទេសអេស៊ីប (A/HRC/13/30/Add.1) និងលេខ ២៥/២០០៩ សម្រាប់ប្រទេសអេស៊ីប (A/HRC/16/47/Add.1)។ សូមមើលផងដែរនូវរបាយការណ៍របស់ក្រុមការងារប្រឆាំងនឹងការឃុំឃាំងបំពាន (A/HRC/16/47) ត្រង់កថាខណ្ឌទី ៨ (ង) នៃឧបសម្ព័ន្ធ (ការបែងចែកប្រភេទនៃការដកហូតសេរីភាពជាមូលដ្ឋាន ដោយមានមូលដ្ឋាននៅលើការរើសដោយសារតែទំនោរផ្លូវភេទ ដែលជាការរំលោភបំពានលើច្បាប់អន្តរជាតិ ជាលក្ខណៈបំពាន) ។

[83]កថាខណ្ឌទី ២៥ នៃសេចក្តីសម្រេចលេខ ៤២/២០០៨ របស់ក្រុមការងារប្រឆាំងនឹងការឃុំឃាំងបំពាន ។

[84]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់សាធារណរដ្ឋអៀរ៉ង់ (CCPR/C/IRN/CO/3) ត្រង់កថាខណ្ឌទី ១០ ។

# សេចក្ដីសន្និដ្ឋាន

ការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះទំនាក់ទំនងផ្លូវភេទរវាងមនុស្សពេញវ័យមានភេទដូចគ្នាដោយមានការព្រមព្រៀងគ្នាជាការរំលោភបំពានការធានាតាមផ្លូវច្បាប់ជាលក្ខណៈអន្តរជាតិនូវសិទ្ធិឯកជន និងការមិនរើសអើង។ ការអនុវត្តទោសប្រហារជីវិតចំពោះទំនាក់ទំនងផ្លូវភេទដោយមានការព្រមព្រៀងគ្នា គឺ



ជាការរំលោភបំពានលើសិទ្ធិរស់រានមានជីវិត។ ការចាប់ខ្លួន ឬការឃុំខ្លួនបុគ្គលទាំងឡាយដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ ឬ ទំនាក់ទំនងផ្លូវភេទដូចគ្នា ត្រូវបានហាមឃាត់ដូចគ្នាដែរតាមរយៈការធានា មិនឲ្យមានការឃុំខ្លួនដោយបំពាន។ ទោះបីជាមិនធ្លាប់ត្រូវបានអនុវត្តក៏ដោយ ច្បាប់ព្រហ្មទណ្ឌបែបនេះ គឺជាការរំលោភបំពាននឹងកាតព្វកិច្ចរបស់រដ្ឋតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ រដ្ឋទាំងឡាយគួរតែលុបចោលជាបន្ទាន់នូវច្បាប់ទាំងអស់ដែលចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះទំនាក់ទំនងផ្លូវភេទ ដូចគ្នាដោយមានការព្រមព្រៀង របស់មនុស្សពេញវ័យជាលក្ខណៈឯកជន ។

## ៤. ហាមឃាត់ការរើសអើង ដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ

*មនុស្សគ្រប់រូបមានសិទ្ធិរួចផុតពីការរើសអើងក្នុងនោះរួមមានដោយសារទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ។ សិទ្ធិនេះត្រូវបានការពារដោយមាត្រា ២ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ក៏ដូចជាបទប្បញ្ញត្តិដែលមិនរើសអើងនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដ៏សំខាន់។ លើសពីនេះទៀត មាត្រា ២៦ នៃសេចក្តីប្រកាសចែងថា មនុស្សគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ និង មានសិទ្ធិទទួលបានកិច្ចការពារស្មើភាពគ្នាពីច្បាប់ដោយគ្មានការរើសអើង ។*



## សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

**មាត្រា ២៖** មនុស្សម្នាក់ៗ អាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ ដែលបានប្រកាស់ក្នុងសេចក្តី ប្រកាសនេះ ដោយគ្មានការបែងចែកណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈ នយោបាយ ឬ ទស្សនៈផ្សេងទៀត ដើមកំណើតជាតិ ឬ សង្គម ទ្រព្យសម្បត្តិ កំណើត ឬ ស្ថានភាពផ្សេងទៀត ។

**មាត្រា ៧៖** មនុស្សគ្រប់រូបមានស្មើភាពគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបានការការពារ ពីច្បាប់ស្មើៗ គ្នាដោយគ្មានការរើសអើង។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការការពារស្មើៗគ្នា ប្រឆាំងនឹងការរើសអើងណា ដែលជាការរំលោភបំពានលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំងការញុះញង់ឲ្យមានការរើសអើង។

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

**មាត្រា ២(១)៖** រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរព និងធានាជូនបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដីនិងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួននូវសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញានេះដោយគ្មានការបែងចែកណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬ ទស្សនៈផ្សេងទៀត ដើមកំណើតជាតិ ឬ សង្គម ទ្រព្យសម្បត្តិ កំណើត ឬ ស្ថានភាពផ្សេងទៀត។

**មាត្រា ២៦៖** ជនគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និង មានសិទ្ធិទទួលបានកិច្ចការពារពីច្បាប់ស្មើគ្នាដោយគ្មានការរើសអើង។ ក្នុងប្រការនេះច្បាប់ត្រូវហាមការរើសអើង និង ត្រូវធានាឲ្យជនគ្រប់រូបនូវការការពារដោយស្មើភាពគ្នា និង ប្រកបដោយប្រសិទ្ធភាពប្រឆាំងការរើសអើង ទាំងឡាយមានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈ នយោបាយ ឬ ទស្សនៈ ផ្សេងទៀត ដើមកំណើតជាតិ ឬ សង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពផ្សេងទៀត ។

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

**មាត្រា ២៖** រដ្ឋភាគីទាំងឡាយនៃកតិកាសញ្ញាបច្ចុប្បន្ននេះសន្យាធានាថា សិទ្ធិទាំងឡាយដែលចែងក្នុងកតិកាសញ្ញានេះ នឹងត្រូវប្រើប្រាស់ ដោយគ្មានការរើសអើងណាមួយ ផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬ ទស្សនៈផ្សេងទៀត ដើមកំណើតជាតិ ឬ សង្គម ទ្រព្យសម្បត្តិ កំណើត ឬ ស្ថានភាពផ្សេងទៀត។

## អនុសញ្ញាស្តីពីសិទ្ធិកុមារ

**មាត្រា ២៖** រដ្ឋភាគី ត្រូវគោរព និងធានា សិទ្ធិដូចចែងនៅក្នុងអនុសញ្ញានេះដល់កុមារម្នាក់ៗ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយគ្មានការរើសអើងណាមួយ ដោយឥតគិតពីពូជសាសន៍ ពណ៌ សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬ ទស្សនៈផ្សេងទៀត ដើមកំណើតជាតិ ជាតិពន្ធុ ឬ សង្គម ទ្រព្យសម្បត្តិ ពិការភាព កំណើត ឬ ស្ថានភាពផ្សេងទៀតរបស់កុមារ ឬ របស់ឪពុកម្តាយ របស់កុមារ ឬ របស់អាណាព្យាបាលស្របច្បាប់របស់កុមារ ។

## គោលជំហររបស់យន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

បុគ្គលដែលជាមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូច មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) ធ្លាប់ជួបប្រទះការរើសអើងក្នុងទិដ្ឋភាពជាច្រើនខុសៗគ្នានៃការរស់នៅប្រចាំថ្ងៃ។ពួកគេទទួលរងទាំងការរើសអើងផ្លូវការក្នុងទម្រង់ជាច្បាប់ និងគោលនយោបាយរបស់រដ្ឋ ដែលចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះការរួមភេទដូចគ្នា រារាំងពួកគេពីទម្រង់ខ្លះនៃការងារ ឬ បដិសេធពួកគេមិនឲ្យទទួលបានប្រយោជន៍នានា និងការររើសអើងមិនផ្លូវការក្នុងទម្រង់ជាស្លាកស្នាមទុយ៌សសង្គម ការផាត់ចេញ និងភាពលំអៀង ក្នុងនោះរួមមាននៅកន្លែងធ្វើការ នៅតាមលំនៅឋាន នៅតាមសាលារៀន និងនៅតាមគ្រឹះស្ថានថែទាំសុខភាព។ ប៉ុន្តែ ច្បាប់សិទ្ធិមនុស្សអន្តរជាតិហាមឃាត់ការរើសអើង ដោយឈរលើមូលដ្ឋានទំនោរផ្លូវភេទ និងអត្តសញ្ញាណភេទ។ ទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ ដូចជា ជាតិសាសន៍ ភេទ ពណ៌សម្បុរ ឬ សាសនា គឺជាមូលដ្ឋានមិនអាចអនុញ្ញាតសម្រាប់ការបែងចែកធ្វើឲ្យខុសគ្នា។

ច្បាប់អន្តរជាតិ កំណត់និយមន័យនៃពាក្យការរើសអើងជាការបែងចែកធ្វើឲ្យខុសគ្នាណាមួយការផាត់ចេញការរិតត្បិត ឬ សេចក្តីចូលចិត្ត ឬ ប្រព្រឹត្តកម្មខុសគ្នាផ្សេងទៀត ដែលមានមូលដ្ឋានផ្ទាល់ ឬ មិនផ្ទាល់នៅលើមូលហេតុ ដែលត្រូវបានហាមឃាត់ចំពោះការរើសអើង និងដែលមានគោលបំណង ឬ ឥទ្ធិពលនៃការធ្វើឲ្យទៅជាមោឃៈ ឬ ការធ្វើឲ្យខូចខាតដល់ការទទួលស្គាល់ ការទទួលបាន ឬ ការប្រើប្រាស់ ដោយមានភាពស្មើគ្នានូវសិទ្ធិដែលត្រូវបានធានាក្រោមច្បាប់អន្តរជាតិ។[85] ភាពខុសគ្នានៃប្រព្រឹត្តកម្មដោយផ្អែកលើមូលហេតុដែលត្រូវបានហាមឃាត់ត្រូវបានចាត់ទុកជាការរើសអើងលុះត្រាតែរដ្ឋអាចបង្ហាញថា មានយុត្តិកម្មលើភាពខុសគ្នានៃប្រព្រឹត្តកម្ម ដែលមានលក្ខណៈសមហេតុផល និងមិនលំអៀង ។

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ទាំងអស់រួមបញ្ចូលជាបញ្ជីមូលហេតុនៃការរើសអើងដែលត្រូវបានហាមឃាត់ ក្នុងការធានាដែលមិនមានការរើសអើងនៃសេចក្តីប្រកាស និង កតិកាសញ្ញាទាំងនេះ។ បញ្ជីទាំងនេះមិនរួមបញ្ចូល "ទំនោរផ្លូវភេទ" ឬ "អត្តសញ្ញាណយេនឌ័រ" ច្បាស់លាស់ទេ ប៉ុន្តែបញ្ជីទាំងអស់នេះបានប្រើឃ្លាជារួមថា "ស្ថានភាពផ្សេងទៀត"។ ការប្រើប្រាស់ឃ្លា "ស្ថានភាពផ្សេងទៀត" បង្ហាញថា បញ្ជីទាំងនោះត្រូវបានរៀបចំឡើងក្នុងគោលបំណងដោយមានលក្ខណៈបើកចំហ និងពន្យល់ៈ ម្យ៉ាងទៀត មូលដ្ឋាននៃការរើសអើង មិនបិទទេ។ យោងតាមគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គម-កិច្ច និង វប្បធម៌ៈ

[85]កថាខណ្ឌទី ៧ នៃសេចក្តីពន្យល់ទូទៅលេខ ១៨ របស់គណៈកម្មាធិការសិទ្ធិមនុស្ស កថាខណ្ឌទី ៧ នៃសេចក្តីពន្យល់ទូទៅលេខ ២០ របស់គណៈកម្មា-ធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។ សូមមើលមាត្រា ១ នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងជាតិសាសន៍ មាត្រា ១ នៃអនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងចំពោះស្ត្រីភេទ និងមាត្រា ២ នៃអនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ ។

*លក្ខណៈនៃការរើសអើងប្រែប្រួលទៅតាមបរិបទ និងវិវត្តជាប្រចាំ។ ដូចនេះ វិធីសាស្ត្រដែលមានលក្ខណៈបត់បែនសម្រាប់មូលហេតុនៃ "ស្ថានភាពផ្សេងទៀត" គឺត្រូវការចាំបាច់ ដើម្បីចាប់យកទម្រង់ផ្សេងទៀតនៃប្រព្រឹត្តកម្មខុសគ្នាដែលមិនអាចត្រូវបានធ្វើយុត្តិកម្ម ដោយសមហេតុផល និង ដោយមិនលំអៀង និងមានលក្ខណៈដែលអាចប្រៀបធៀបបានទៅនឹងមូលហេតុដែលត្រូវបានទទួលស្គាល់យ៉ាងជាក់លាក់ នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ២។ មូលហេតុបន្ថែមទាំងនេះត្រូវបានទទួលស្គាល់ជារួមនៅពេលដែលវាបង្ហាញបទពិសោធន៍របស់ក្រុមសង្គមដែលងាយរងគ្រោះ និងបានទទួលរង និងបន្តទទួលរងភាពទន់ខ្សោយ ។*[86]

នៅក្នុងយុត្តិសាស្ត្រ សេចក្តីពន្យល់ទូទៅ និង សេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួន អង្គការសន្ធិសញ្ញានៃអង្គការសហប្រជាជាតិ បានអះអាងដោយឥតងាករេថា ទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ ជាមូលហេតុនៃការរើសអើងដែលត្រូវបានហាមឃាត់ដូចមានចែងនៅក្នុងច្បាប់អន្តរជាតិ។ លើសពីនេះទៀតយន្តការនីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស បានទទួលស្គាល់ជាយូរមកហើយចំពោះការរើសអើង ទាំងលើទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ។

នៅក្នុងរឿងក្តីរបស់*ធូណិន* គណៈកម្មាធិការសិទ្ធិមនុស្សបានថ្លែងថា "សេចក្តីយោងចំពោះ'ភេទ' នៅក្នុងកថាខណ្ឌទី ១ មាត្រា ២ និងមាត្រាទី ២៦ ត្រូវបានធ្វើឡើងរួមបញ្ចូលទាំងទំនោរផ្លូវភេទ" ។[87]

នៅក្នុងរឿងក្តីរបស់ *យ៉ាំងទល់នឹងប្រទេសអូស្ត្រាលី* ដែលត្រូវបានសម្រេចនៅក្នុងឆ្នាំ ២០០៣ និងរឿងក្តីរបស់*អ៊ិក្សទល់នឹងប្រទេសប្រទេសកូឡុំប៊ី* ដែលត្រូវបានសម្រេចនៅក្នុងឆ្នាំ ២០០៧ គណៈកម្មាធិការបានសន្និដ្ឋានថា ភាពខុសគ្នានៃប្រព្រឹត្តកម្មនៅក្នុងការផ្តល់ប្រយោជន៍សោធននិវត្តន៍ ដល់ដៃគូដែលមានភេទដូចគ្នា ជាការរំលោភបំពានលើសិទ្ធិរួចផុតពីការរើសអើង"ដោយឈរលើមូលដ្ឋាននៃភេទ ឬ ទំនោរផ្លូវភេទ" ។[88]

ចាប់តាំងពីពេលមានក្តីររបស់*ធូណិន*មក នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានជាច្រើន គណៈកម្មាធិការសិទ្ធិមនុស្សបានជំរុញរដ្ឋជាភាគីទាំងឡាយឲ្យ "ធានាឲ្យមានសិទ្ធិស្មើគ្នាចំពោះមនុស្សទាំងអស់ ដូចដែលត្រូវបានកំណត់នៅក្នុងកតិកាសញ្ញាដោយមិនគិតអំពីទំនោរផ្លូវភេទ"។[89]រដ្ឋទាំងឡាយមាន"កាតព្វកិច្ចតាមផ្លូវ

---

[86]កថាខណ្ឌទី ២៧ នៃសេចក្តីពន្យល់ទូទៅលេខ ២០ របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ។

[87]CCPR/C/50/d/499/1992 ត្រង់កថាខណ្ឌទី៨.៧ ។

[88]នៅក្នុងរឿងក្តី*របស់យ៉ាំងទល់ជាមួយអូស្ត្រាលី* កថាខណ្ឌទី ១០.៤ នៃសេចក្តីសម្រេចលេខ ៩៤១/២០០០ (CCPR/C/78/D/941/2000) របស់គណៈកម្មាធិការសិទ្ធិមនុស្ស នៅក្នុង *រឿងក្តីរបស់អ៊ិក្សទល់ជាមួយកូឡុំប៊ី* កថាខណ្ឌទី ៩ នៃ សេចក្តីសម្រេចលេខ ១៣៦១/២០០៥ (CCPR/C/89/D/1361/2005) របស់គណៈកម្មាធិការសិទ្ធិមនុស្ស ។

[89]**ធានាឲ្យមានសិទ្ធិស្មើគ្នាចំពោះមនុស្សទាំងអស់ ដោយមិនគិតអំពីទំនោរផ្លូវភេទ៖** សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសឈីលី (CCPR/C/CHL/CO/5) ត្រង់កថាខណ្ឌទី ១៦ ។ សូមមើលផងដែរនូវសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់សានម៉ារីណូ (CCPR/C/SMR/CO/2) ត្រង់កថាខណ្ឌទី ៧ និងសម្រាប់ប្រទេសអូទ្រីស (CCPR/C/AUT/CO/4) ត្រង់កថាខណ្ឌទី ៨ ។

ច្បាប់...ដើម្បីធានាចំពោះមនុស្សរាល់រូបនូវសិទ្ធិដែលត្រូវបានទទួលស្គាល់នៅក្នុងកតិកាសញ្ញា...ដោយគ្មានការរើសអើង ដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ”។[90] ជាញឹកញាប់គណៈកម្មាធិការបានទទួលស្វាគមន៍ចំពោះការអនុម័តច្បាប់ដែលមានចែងរួមទាំងពីទំនោរផ្លូវភេទក្នុងចំណោមមូលហេតុនៃការរើសអើងដែលត្រូវបានហាមឃាត់។[91] គណៈកម្មាធិការក៏បានសម្តែងនូវកង្វល់នៅពេលដែលរដ្ឋទាំងឡាយមិនទទួលស្គាល់ការផ្លាស់ប្តូរភេទដោយចេញនូវឯកសារអត្តសញ្ញាណថ្មីនិងបានកត់សំគាល់លើច្បាប់អនុម័តដែលផ្តល់ការទទួលស្គាល់តាមផ្លូវច្បាប់ចំពោះការផ្លាស់ប្តូរអត្តសញ្ញាណយេនឌ័រ ។[92]

*ទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ ដូចជា ជាតិសាសន៍ ភេទ ពណ៌សម្បុរ ឬ សាសនា គឺជាមូលដ្ឋានមិនអាចអនុញ្ញាតសម្រាប់ការបែងចែក ។*

គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ បានអះអាងថា ការធានាដែលមិនមានការ រើសអើងនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ រួមបញ្ចូលទាំងទំនោរផ្លូវភេទ។ គណៈកម្មាធិការនេះបានបង្ហាញបញ្ហានេះតាមរយៈសេចក្តីសង្កេតទូទៅពាក់ព័ន្ធនឹងសិទ្ធិធ្វើការងារសិទ្ធិទទួលបានទឹក ប្រើប្រាស់សិទ្ធិទទួលបានសន្តិសុខសង្គម សិទ្ធិមានសុខភាពតាមស្តង់ដារ ដែល អាចសម្រេចបានខ្ពស់បំផុតក៏ដូចជាពាក់ព័ន្ធនឹងអត្ថន័យទូទៅនៃការធានាដែល មិនមានការរើសអើង។[93] នៅក្នុងឆ្នាំ២០០៩ គណៈកម្មាធិការបានពន្យល់ថា ការធានាដែលមិនមានការរើសអើង រួមបញ្ចូលទាំងអត្តសញ្ញាណយេនឌ័រដោយថ្លែងថា “អ្នកប្តូរភេទ អ្នកប្តូរភេទ បន្ទាប់ពីវះកាត់ ឬ មនុស្សភេទពីរជារឿយៗ ប្រឈមមុខនឹងការរំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ដូចជា ការយាយីរំខាន នៅតាមសាលារៀន ឬ នៅតាមកន្លែងធ្វើការ”។[94]

នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួនគណៈកម្មាធិការបានសម្តែងចេញនូវកង្វល់អំពីការរើសអើងចំពោះបុគ្គលដែលជាមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រ-

---

[90]CCPR/C/USA/CO/3 ត្រង់កថាខណ្ឌទី ២៥ ។

[91]**ការទទួលស្វាគមន៍ច្បាប់ដែលមិនមានការរើសអើង៖** សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសក្រិច (CCPR/CO/83/GRC) ត្រង់កថាខណ្ឌទី ៥ សម្រាប់ប្រទេសហ្វាំងឡង់ (CCPR/CO/82/FIN) ត្រង់កថាខណ្ឌទី ៣ សម្រាប់ប្រទេសស្លូវ៉ាគី (CCPR/CO/78/SVK) ត្រង់កថាខណ្ឌទី ៤ សម្រាប់ប្រទេសស៊ុយអែត (CCPR/C/SWE/CO/6) ត្រង់កថាខណ្ឌទី ៣ សម្រាប់ប្រទេសដាណឺម៉ាក (CCPR/C/DNK/CO/5) ត្រង់កថាខណ្ឌទី ៤ សម្រាប់ប្រទេសបារាំង (CCPR/C/FRA/CO/4) ។សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទសម្រាប់ប្រទេសម៉ុងតេណេហ្គ្រោ (CEDAW/C/MNE/CO/1) ត្រង់កថាខណ្ឌទី ៤(ខ) ។

[92]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសអៀរឡង់ (CCPR/C/IRL/CO/3) ត្រង់កថាខណ្ឌទី ៨ សម្រាប់ចក្រភពអង់គ្លេស និងប្រទេសអៀរឡង់ខាងជើង (CCPR/C/GBR/CO/6) ត្រង់កថាខណ្ឌទី ៥ ។

[93]**ទំនោរផ្លូវភេទ៖** សេចក្តីសង្កេតទូទៅលេខ ២០ (ការមិនរើសអើងចំពោះសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌) ត្រង់កថាខណ្ឌទី ៣២ លេខ ១៩ (សិទ្ធិផ្នែកសន្តិសុខសង្គម) ត្រង់កថាខណ្ឌទី ២៩ លេខ ១៨ (សិទ្ធិធ្វើការងារ) ត្រង់កថាខណ្ឌទី ១២(ខ) លេខ ១៥ (សិទ្ធិទទួលបានទឹកប្រើប្រាស់គ្រប់គ្រាន់) ត្រង់កថាខណ្ឌទី ១៣ លេខ ១៤ (សិទ្ធិមានសុខភាពតាមស្តង់ដារដែលអាចសម្រេចបានខ្ពស់បំផុត) ត្រង់កថាខណ្ឌទី ១៨ របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ។

[94]**អត្តសញ្ញាណយេនឌ័រ៖** កថាខណ្ឌទី ៣២ នៃសេចក្តីពន្យល់ទូទៅលេខ ២០ (ការមិនរើសអើងចំពោះសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌) របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ។

លាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ក្នុងការទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ និងបានជំរុញឲ្យមានការអនុម័តច្បាប់ដើម្បីការពារពួកគេពីការរើសអើង។[95] ស្រដៀងគ្នានេះដែរគណៈកម្មាធិការបានសរសើររដ្ឋទាំងឡាយណាដែលបានអនុម័តច្បាប់នេះ។[96]

ដូចគ្នាដែរ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ បកស្រាយអំពីសិទ្ធិទទួលបានភាពមិនរើសអើងនៅក្នុងមាត្រា ២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារដើម្បីដាក់បញ្ចូលទំនោរផ្លូវភេទ[97] និងអត្តសញ្ញាណយេនឌ័រ។[98] នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួន គណៈកម្មាធិការនេះបានលើកឡើងនូវកង្វល់អំពីច្បាប់ដែលមិនការពារបុគ្គលពីការរើសអើងដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ និង អំពីការខិតខំប្រឹងប្រែងមិនបានពេញលេញក្នុងការប្រយុទ្ធប្រឆាំងនឹងការរើសអើងបែបនេះ។[99] ឧទាហរណ៍ ចំពោះចក្រភពអង់គ្លេស គណៈកម្មាធិការនេះបានសម្តែងចេញនូវកង្វល់ថា "ដាក់ស្តែងក្រុមកុមារខ្លះ ដូចជា ...កុមារដែលជាមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT)...បន្តជួបប្រទះនឹងការរើសអើង និង ស្លាកស្នាមទុយ៌សនៅក្នុងសង្គម" ។[100] គណៈកម្មាធិការនេះបានផ្តល់ជាអនុសាសន៍ថា រដ្ឋគួរតែពង្រឹងការលើកកម្ពស់ការយល់ដឹង និង វិធានការបង្ការផ្សេងទៀតចំពោះការរើសអើង និង ប្រសិនបើចាំបាច់ចាត់វិធានការដើម្បីជាប្រយោជន៍ដល់ ក្រុមកុមារនេះ ។

អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មិនរួមបញ្ចូលបញ្ជីមូលដ្ឋាននៃការរើសអើងទេ។ ជំនួសមកវិញមាត្រា ១ ចែងថា ការបង្កការឈឺចាប់ ឬ ការរងទុក្ខដ៏ធ្ងន់ធ្ងរដោយចេតនាដើម្បីគោលបំណងមួយចំនួនក្នុងនោះរួមមានមូលហេតុ "ដោយផ្អែកលើការរើសអើងណាមួយក៏ដោយ" ជាអំពើធ្វើទារុណកម្ម។ នៅក្នុងសេចក្តីសង្កេតទូទៅលេខ ២ របស់ខ្លួន គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម បានពន្យល់ថា

[95]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ សម្រាប់ប្រទេសប៉ូឡូញ (E/C.12/POL/CO/5) ត្រង់កថាខណ្ឌទី ១២ សម្រាប់ប្រទេសចិន (E/C.12/1/Add.107) ត្រង់កថាខណ្ឌទី ៧៨ សម្រាប់ទ្រីនីដាដ និងតូបាហ្គោ (E/C.12/1/Add.80) ត្រង់កថាខណ្ឌទី ១៤ ។

[96]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ សម្រាប់ប្រទេសអៀរឡង់ (E/C.12/1/Add.35) ត្រង់កថាខណ្ឌទី ៥ សម្រាប់ប្រទេសស៊ុយអែត (E/C.12/1/Add.70) ត្រង់កថាខណ្ឌទី ៨ សម្រាប់លីកធិនស្តេន (E/C.12/LIE/CO/1)ត្រង់កថាខណ្ឌទី ៦ សម្រាប់ម៉ូណាកូ (E/C.12/MCO/CO/1) ត្រង់កថាខណ្ឌទី ៣ សម្រាប់ប្រទេសប្រេស៊ីល (E/C.12/CO/BRA/2) ត្រង់កថាខណ្ឌទី ៣ ។

[97]សេចក្តីពន្យល់ទូទៅលេខ ៤ (សុខភាព និងការវិវត្តរបស់មនុស្សពេញវ័យនៅក្នុងបរិបទនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ) ត្រង់កថាខណ្ឌទី ៦ និងលេខ ៣ (មេរោគអេដស៍/ជំងឺអេដស៍ និងសិទ្ធិកុមារ) ត្រង់កថាខណ្ឌទី ៨ របស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ ។

[98]កថាខណ្ឌទី ៦០ និងទី ៧២(ឆ) (ដោយសង្កត់ធ្ងន់ថា រដ្ឋភាគីទាំងឡាយត្រូវតែដោះស្រាយបញ្ហានៃការរើសអើងចំពោះក្រុមកុមារដែលងាយរងគ្រោះ និងទន់ខ្សោយខ្វះឥទ្ធិពល ក្នុងនោះរួមមានកុមារដែលជាកុមារីស្រលាញ់ភេទដូចគ្នា កុមារាស្រលាញ់ភេទដូចគ្នា កុមារប្តូរភេទ ឬ កុមារប្តូរភេទបន្ទាប់ពីវះកាត់) នៃសេចក្តីពន្យល់ទូទៅលេខ ១៣ (សិទ្ធិ សេរីភាពរបស់កុមាររួចផុតពីរាល់ទម្រង់នៃអំពើហិង្សា) របស់គណៈកម្មាធិការសិទ្ធិកុមារ ។

[99]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារសម្រាប់ប្រទេសនូវ៉ែលសេឡង់ (CRC/C/NZL/CO/3-4) ត្រង់កថាខណ្ឌទី ២៥ សម្រាប់ប្រទសស្លូវ៉ាគី (CRC/C/SVK/CO/2) ត្រង់កថាខណ្ឌទី ២៧ សម្រាប់ប្រទេសម៉ាឡេស៊ី (CRC/C/MYS/CO/1) ត្រង់កថាខណ្ឌទី ៣១ សម្រាប់ប្រទេសចិន (CRC/C/CHN/CO/2) ត្រង់កថាខណ្ឌទី ៣១សម្រាប់កោះមែន ចក្រភពអង់គ្លេស (CRC/C/15/Add.134) ត្រង់កថាខណ្ឌទី ២២ ។

[100]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារសម្រាប់ចក្រភពអង់គ្លេស និងប្រទេសអៀរឡង់ខាងជើង (CRC/C/GBR/CP/4) ត្រង់កថាខណ្ឌទី ២៤-២៥ ។



កាតព្វ កិច្ចរបស់រដ្ឋភាគីទាំងឡាយក្នុងការបង្ការការធ្វើទារុណកម្ម រួមបញ្ចូលទាំងកាតព្វកិច្ចក្នុងការធានាថា "ច្បាប់ របស់ខ្លួនត្រូវបានអនុវត្តជាក់ស្តែងទៅលើគ្រប់បុគ្គលទាំងអស់ដោយមិនគិតអំពី " ចរិតលក្ខណៈផ្ទាល់ខ្លួនមួយ ចំនួនក្នុងនោះរួមមាន "ទំនោរផ្លូវភេទ" និង "អត្តសញ្ញាណភេទ" ផងដែរ។[101] នៅក្នុងសេចក្តីសង្កេតសន្និដ្ឋាន របស់ខ្លួន គណៈកម្មាធិការនេះបានសម្តែងចេញនូវកង្វល់អំពីការរំលោភបំពានផ្នែកផ្លូវភេទ និង រូបរាងកាយ ដោយមន្ត្រីនគរបាល និងមន្ត្រីពន្ធនាគារចំពោះបុគ្គល "ដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ និង/ឬ អត្ត-សញ្ញាណប្តូរភេទរបស់ពួកគ"។[102] គណៈកម្មាធិការនេះថ្លែងថា:

*គណៈកម្មាធិការពិចារណាថា ជាពិសេសវិធានស្តីពីសីលធម៌សាធារណៈ អាចផ្តល់ដល់នគរបាល និង ចៅក្រមនូវអំណាចធ្វើការសម្រេចដែល នៅពេលគួបផ្សំជាមួយនឹងបុរេនិច្ឆ័យ និង ឥរិយាបថដែលមាន លក្ខណៈរើសអើង អាចនាំទៅដល់ការរំលោភបំពានចំពោះក្រុមនេះ ។[103]*

[101]កថាខណ្ឌទី ២១ នៃសេចក្តីពន្យល់ទូទៅលេខ ២ (អនុវត្តមាត្រា ២ របស់ភាគីរដ្ឋទាំងឡាយ) របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ។

[102]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មសម្រាប់ប្រទេសកូស្តារីកា (CAT/C/CRI/CO/2)ត្រង់កថាខណ្ឌទី ១១ និង ១៨ សូមមើលផងដែរ សម្រាប់ប្រទេសឡាត់វី (CAT/C/LVA/CO/2) ត្រង់កថាខណ្ឌទី ១៩ (ការលើកឡើងនូវកង្វល់អំពីអំពើហិង្សា និងការរើសអើងដែលមានចំពោះសហគមន៍ស្រីស្រលាញ់ភេទដូចគ្នា ប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ (LGBT)សម្រាប់ប្រទេសប៉ូឡូញ (CAT/C/POL/CO/4) ត្រង់កថាខណ្ឌទី ២០ (ការនិយាយវាយប្រហារ និងភាពមិនចេះអត់ឱនចំពោះប្រុសស្រលាញ់ភេទដូចគ្នា និងស្រីស្រលាញ់ភេទដូចគ្នា) សម្រាប់សហរដ្ឋអាមេរិក (CAT/C/USA/CO/2)សម្រាប់ប្រទេសអេក្វាឌ័រ (CAT/C/ECU/CO/2) ត្រង់កថាខណ្ឌទី ១៧។

[103]CAT/C/CRI/CO/2 ត្រង់កថាខណ្ឌទី ១១ ។

អនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ មិនរួមបញ្ចូលបញ្ជីមូលដ្ឋាននៃការរើសអើងទេ។ទោះជាដូច្នេះក្តីគណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទបានបញ្ជាក់អំពីភាពទាក់ទងទៅវិញទៅមកនៃគ្រប់ទម្រង់ទាំងអស់នៃការរើសអើងជាគន្លឹះសំខាន់សម្រាប់ការយល់ដឹងអំពី វិសាលភាពនៃកាតព្វកិច្ចរបស់រដ្ឋ ដូចមានចែងនៅ ក្នុងអនុសញ្ញា។ "ការរើសអើងប្រឆាំងនឹងស្ត្រី ភេទ ដោយមានមូលដ្ឋាននៅលើភេទ និង យេនឌ័រ ត្រូវបានផ្សារភ្ជាប់ទំនាក់ទំនងដោយមិនអាចបំបែកបានជាមួយនឹងកត្តាផ្សេងទៀតដែលប៉ះពាល់ដល់ស្ត្រីភេទ ដូចជាជាតិសាសន៍ ជាតិពន្ធុ សាសនា ឬ ជំនឿ សុខភាព ឋានៈ វ័យ វណ្ណៈ ឋានៈក្នុងសង្គម និងទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ...។ រដ្ឋភាគីទាំងឡាយត្រូវតែទទួលស្គាល់តាមផ្លូវច្បាប់ នូវទម្រង់ដែលទាក់ទងទៅវិញទៅមកបែបនេះនៃការរើសអើង និង ឥទ្ធិពលអវិជ្ជមាន ដែលត្រូវបានធ្វើឲ្យកាន់តែធ្ងន់ធ្ងរឡើងនៃទម្រង់ទាំងនោះទៅលើស្ត្រីពាក់ព័ន្ធនិងហាមឃាត់ចំពោះទម្រង់ទាំងនោះ។[104] នៅក្នុងអនុសាសន៍ទូទៅលេខ២៧ គណៈកម្មាធិការនេះបានពិពណ៌នាអំពីការរើសអើងដែលស្ត្រីវ័យចំណាស់ប្រឈមមុខថា"ជារឿយៗ មានទិដ្ឋភាពជាច្រើន ដោយមានកត្តាវ័យដែលធ្វើឲ្យកាន់តែធ្ងន់ធ្ងរឡើងនូវទម្រង់ផ្សេងទៀតនៃការរើសអើង ដោយមានមូលដ្ឋាននៅលើយេនឌ័រ ប្រភពដើម ជាតិពន្ធុ ពិការភាព កម្រិតនៃភាពក្រីក្រ ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ ឋានៈនៃពលករទេសន្ត ប្រវេសន៍ ស្ថានភាព អាពាហ៍ពិពាហ៍ និងគ្រួសារ អក្ខរកម្ម និងមូលដ្ឋានផ្សេងទៀត" ។[105]

*មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT)ជួបប្រទះការរើសអើងលើទិដ្ឋភាពជាច្រើនខុសៗគ្នានៃការរស់នៅប្រចាំថ្ងៃ ។*

គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ បានសុំឲ្យមានការយកចិត្តទុកដាក់លើការរើសអើងចំពោះស្ត្រីភេទ ដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ។[106] នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានឆ្នាំ២០១០ របស់ខ្លួនសម្រាប់ប្រទេសអ៊ូហ្គាន់ដា គណៈកម្មាធិការនេះបានបង្ហាញពី "កង្វល់ដ៏ខ្លាំងក្លាអំពីការយាយីរំខាន អំពើហិង្សា ឧក្រិដ្ឋកម្មរើសអើង និង ការញុះញង់ឲ្យមានការស្អប់ស្ត្រីភេទដែលត្រូវបានរាយការណ៍ ដោយសារតែទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័ររបស់ពួកគេ។ គណៈកម្មាធិការនេះខ្វល់ខ្វាយផងដែរថា ពួកគេប្រឈមមុខនឹងការរើសអើងក្នុងការងារ ការថែទាំសុខភាព ការអប់រំ និង វិស័យផ្សេងទៀត"។ គណៈកម្មាធិការនេះបានអំពាវនាវដល់ប្រទេសអ៊ូហ្គាន់ដាឲ្យ "ផ្តល់កិច្ចការពារប្រកប

[104]កថាខណ្ឌទី ១៨ នៃអនុសាសន៍ទូទៅលេខ ២៨ (ស្តីពីកាតព្វកិច្ចសំខាន់នៃភាគីរដ្ឋទាំងឡាយ ដូចមានចែងនៅក្នុងមាត្រា ២) របស់គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ ។

[105]កថាខណ្ឌទី ១៣ នៃអនុសាសន៍ទូទៅលេខ ២៧ (ស្តីពីស្ត្រីវ័យចំណាស់ និងកិច្ចការពារសិទ្ធិរបស់ពួកគេ) របស់គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទ ។

[106]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទសម្រាប់ប្រទេសប៉ាណាម៉ា (CEDAW/C/PAN/CO/7)ត្រង់កថាខណ្ឌទី ២២ សូមមើលផងដែរ សម្រាប់ប្រទេសអាល្លឺម៉ង់ (CEDAW/C/DEU/CO/6)ត្រង់កថាខណ្ឌទី ៦១-៦២សម្រាប់ប្រទេសអាសង់ទីន (CEDAW/C/ARG/CO/6)ត្រង់កថាខណ្ឌទី ៤៣-៤៤ សម្រាប់ប្រទេសអាហ្វ្រិកខាងត្បូង (CEDAW/C/ZAF/CO/4)ត្រង់កថាខណ្ឌទី ៣៩-៤០សម្រាប់ប្រទេសតើជីស្ថាន (A/54/38, 20)ត្រង់កថាខណ្ឌទី ១២៨ ។



ដោយប្រសិទ្ធភាពពីអំពើហិង្សា និង ការរើសអើងចំពោះស្ត្រីភេទដោយមានមូលដ្ឋាននៅលើទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ជាពិសេស តាមរយៈការអនុម័តច្បាប់ប្រឆាំងនឹងការរើសអើងគ្រប់ជ្រុងជ្រោយ ដោយមានវិសាលភាពក្នុងចំណោមកត្តាផ្សេងទៀតលើការហាមឃាត់ទម្រង់ជាច្រើននៃការរើសអើងចំពោះស្ត្រី ដោយឈរលើគ្រប់មូលដ្ឋានគ្រឹះទាំងអស់ ក្នុងនោះរួមមានដោយឈរលើមូលដ្ឋានទំនោរ ផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រផងដែរ″ ។[107]

អង្គការសន្ធិសញ្ញាសិទ្ធិមនុស្សមួយចំនួនកត់សំគាល់ជាពិសេសលើច្បាប់ដែលរើសអើងដោយឈរ លើមូលដ្ឋាននៃអត្តសញ្ញាណយេនឌ័រ។ក្នុងករណីរបស់ប្រទេសគូវ៉ែតគណៈកម្មាធិការសិទ្ធិមនុស្សបានសម្តែងចេញនូវកង្វល់អំពី ‟បទឧក្រិដ្ឋថ្មីនៃ ‘ការធ្វើត្រាប់តាមសមាជិកដែលមានភេទផ្ទុយគ្នា’ និងបានអំពាវនាវដល់រដ្ឋភាគីឲ្យលុបចោលច្បាប់នេះ″ដើម្បីធ្វើឲ្យច្បាប់របស់ខ្លួនស្របទៅនឹងកតិកាសញ្ញានេះ″។[108]គណៈកម្មា-ធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ បានសង្កេតដោយសេចក្ដីស្រងាកចិត្តថា អ្នកប្តូរភេទ និង មនុស្ស

[107]សេចក្ដីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទសម្រាប់ប្រទេសអ៊ូហ្គាន់ដា (CEDAW/C/UGA/CO/7)ត្រង់កថាខណ្ឌទី ៤៣-៤៤ ។

[108]សេចក្ដីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសគូវ៉ែត (CCPR/C/KWT/CO/2) ត្រង់កថាខណ្ឌទី ៣០ ។

ភេទពីរត្រូវបានកំណត់ចរិតលក្ខណៈថាមាន ជំងឺផ្លូវចិត្ត និង បានសម្តែងចេញផងដែរនូវកង្វល់ចំពោះការរំលោភបំពានលើសិទ្ធិទំនាក់ទំនងផ្លូវភេទ និងសិទ្ធិបន្តពូជរបស់ពួកគេដែលជាការរំលោភបំពានលើ មាត្រា ១២នៃកតិកាសញ្ញានេះ។ គណៈកម្មាធិការនេះបានអំពាវនាវដល់ប្រទេសអាល្លឺម៉ង់ឲ្យអនុម័តលើវិធានការការពារ "បូរណភាពបុគ្គល និង សិទ្ធិទំនាក់ទំនងផ្លូវភេទ និង សិទ្ធិបន្តពូជ" របស់អ្នកប្តូរភេទនិងមនុស្សភេទពីរ។[109] ក្នុងករណីរបស់ប្រទេសកូស្តារីកា គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទបានទទួលស្វាគមន៍បទដ្ឋានគតិយុត្តអត្តសញ្ញាណប័ណ្ណថ្មីដែលបានគោរពអត្តសញ្ញាណយេនឌ័ររបស់បុគ្គល ។[110]

## វិស័យពិសេសដែលគួរឲ្យបារម្ភ

សិទ្ធិទទួលបានការពារពីការរើសអើងដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ អនុវត្តចំពោះការទទួលបានសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ទាំងអស់។ វិស័យពិសេសនៃការងារ សុខភាព និងការអប់រំ ត្រូវបានពិភាក្សានៅត្រង់ចំណុចនេះ ប៉ុន្តែអង្គការសន្ធិសញ្ញា និង យន្តការនីតិវិធីពិសេស ក៏បានកត់សំគាល់អំពីការរើសអើងនៅក្នុងវិស័យនៃលទ្ធភាពទទួលបានសេវាជាមូលដ្ឋានផ្សេងទៀត ដូចជា ការផ្តល់ជម្រកស្នាក់នៅ និងប្រយោជន៍ផ្នែកសង្គមកិច្ច ។[111]

### ការងារ

*ចំពោះប្រយោជន៍ការងាររដ្ឋមិនអាចបែងចែកពីភាពខុសគ្នារវាងគូស្វាមីដែលស្រលាញ់ភេទផ្ទុយគ្នានិងស្រលាញ់ភេទដូចគ្នាដោយមិនទាន់បានរៀបការទេ ។*

មាត្រា ៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ចែងថា: "រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិធ្វើការងាររួមមានសិទ្ធិរបស់មនុស្សរាល់រូបមានលទ្ធភាពចិញ្ចឹមជីវិតដោយការងារដែលជ្រើសរើស ឬ ព្រមទទួលយកដោយសេរី និង ចាត់វិធានការសមស្របដើម្បីការពារសិទ្ធិនេះ"។ គណៈកម្មាធិការសិទ្ធិ សេដ្ឋកិច្ច

---

[109]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌សម្រាប់ប្រទេសអាល្លឺម៉ង់ (E/C.12/DEU/CO/5) ត្រង់កថាខណ្ឌទី ២៦ ។

[110]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទសម្រាប់ប្រទេសកូស្តារីកា (E)

[111]**ការរើសអើងលើលទ្ធភាពទទួលបានសេវាជាមូលដ្ឋាន៖** សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់សហព័ន្ធសរុស្ស៊ី (CCPR /C/RUS/CO/6) ត្រង់កថាខណ្ឌទី ២៧ សម្រាប់ប្រទេសជប៉ុន (CCPR/C/JPN/CO/5) ត្រង់កថាខណ្ឌទី ២៩។ កថាខណ្ឌទី ៣២ នៃសេចក្តីពន្យល់ទូទៅលេខ ២០ របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការផ្តល់ជម្រកស្នាក់នៅគ្រប់គ្រាន់ជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅគ្រប់គ្រាន់ A/HRC/10/7Add.3 ត្រង់កថាខណ្ឌទី ៥០ A/HRC/4/18/Add.2 ត្រង់កថាខណ្ឌទី ១២៥ E/CN.4/2006/118 ត្រង់កថាខ័ណ្ឌទី ៣០ E/CN.4/2005/43 ត្រង់កថាខណ្ឌទី ៦៣ ។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិរបស់មនុស្សរាល់រូបក្នុងការទទួលបានសុខភាពផ្លូវកាយ និងផ្លូវចិត្តតាមស្តង់ដាដែលអាចសម្រេចបានខ្ពស់បំផុតE/CN.4/2004 /49 ត្រង់កថាខណ្ឌទី ៣៨ E/CN.4/2003/58 ត្រង់កថាខណ្ឌទី ៦៨។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិទទួលបានការអប់រំ E/CN.4/2006/45 ត្រង់កថាខណ្ឌទី ១១៣ E/CN.4/2001/52ត្រង់កថាខ័ណ្ឌទី ៧៥។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកជម្រកស្នាក់នៅគ្រប់គ្រាន់ A/HRC/10/7/Add.3 ត្រង់កថាខណ្ឌទី ៥០ A/HRC/7/16 និង A/HRC/4/18/Add.2 ត្រង់កថាខណ្ឌទី ១២៥ E/CN.4/2006/118 ត្រង់កថាខណ្ឌទី ៣០ E/CN.4/2005/43ត្រង់កថាខណ្ឌទី ៦៣។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាចំពោះស្ត្រី E/CN.4/ 2005/72/Add. 1 ត្រង់កថាខណ្ឌទី ២៣២-២៣៤ ។

សង្គមកិច្ច និង វប្បធម៌ បានថ្លែងថាកតិកាសញ្ញា "ហាមឃាត់ការរើសអើងលើលទ្ធភាពទទួលបាន និង រក្សាបានការងារដោយឈរ លើមូលដ្ឋាន...ទំនោរផ្លូវភេទ"។[112] គោលការណ៍មិនរើសអើង នេះអនុវត្តចំពោះគ្រប់ទិដ្ឋភាពទាំងអស់នៃសិទ្ធិធ្វើការងារ។ ដូច្នេះរដ្ឋទាំងឡាយមានកាតព្វកិច្ចបន្ទាន់ក្នុងការធានាថាសិទ្ធិធ្វើការងារ នឹងត្រូវបានប្រើប្រាស់ដោយគ្មានការរើសអើងទោះជាប្រភេទណាមួយក៏ដោយ។ រដ្ឋទាំងឡាយត្រូវតែគោរព ចំពោះសិទ្ធិធ្វើ ការងារ ដោយបញ្ឈប់ការបដិសេធ ឬ ការកម្រិតលើលទ្ធភាពទទួល បានការងារសមរម្យចំពោះមនុស្សគ្រប់ រូប និង ជាពិសេសចំពោះ"ក្រុម និង បុគ្គលបាត់បង់ឱកាសទ្រទ្រង់ ការរស់នៅសមរម្យ និង ទន់ខ្សោយខ្វះ ឥទ្ធិពល"។[113] ការរើសអើងណាមួយលើលទ្ធភាព ប្រើប្រាស់ទីផ្សារ កម្លាំងពលកម្ម ឬ ទទួលបានមធ្យោបាយ និង សិទ្ធិមាន ការងារធ្វើ "គឺជាការរំលោភបំពានលើកតិកាសញ្ញា នេះ" ។[114]

ចំពោះប្រយោជន៍ការងារ រដ្ឋមិនអាចបែងចែកពីភាពខុសគ្នារវាងគូស្វាមីដែលស្រលាញ់ភេទផ្ទុយគ្នា និង ស្រលាញ់ភេទដូចគ្នាដោយមិនទាន់បានរៀបការទេ។ ក្នុងករណីនៃ*រឿងក្តីរបស់អ៊ុំក្សជាមួយប្រទេសកូឡុំប៊ី* គណៈកម្មាធិការសិទ្ធិមនុស្សបានរកឃើញថា ការខកខានរបស់រដ្ឋក្នុងការពង្រីកប្រយោជន៍សោធននិវត្តឲ្យដល់ ដៃគូស្រលាញ់ភេទដូចគ្នាដែលមិនទាន់បានរៀបការ នៅពេលដែលប្រយោជន៍បែបនេះត្រូវបានផ្តល់ទៅគូស្វាមីស្រលាញ់ភេទផ្ទុយគ្នាដែលមិនទាន់បានរៀបការ គឺ ជាការរំលោភបំពានលើសិទ្ធិដែលត្រូវបានការពារដោយកតិកាសញ្ញានេះ។[115] ក្នុងករណីនៃ*រឿងក្តីរបស់យ៉ាំងជាមួយអូស្ត្រាលី* ដែលបានពាក់ព័ន្ធនឹងអង្គហេតុស្រដៀងគ្នាយ៉ាងខ្លាំងនោះ គណៈកម្មាធិការនេះបានថ្លែងថា:

> *រដ្ឋភាគីមិនផ្តល់ការអះអាងណាមួយអំពីការបែងចែករវាងដៃគូស្រលាញ់ភេទដូចគ្នាដែលត្រូវបានបដិសេធន៏មិនឲ្យទទួលបានប្រយោជន៍សោធននិវត្តដូចមានចែងនៅក្នុងច្បាប់ និងដៃគូស្រលាញ់ភេទផ្ទុយគ្នាដោយមិនបានរៀបការ ដែលត្រូវបានផ្តល់ប្រយោជន៍នេះ មានលក្ខណៈសមហេតុផល និង មិនលំអៀង ហើយគ្មានភស្តុតាងណាមួយដែលធ្វើឲ្យឃើញនូវអត្ថិភាពនៃកត្តាដែលធ្វើយុត្តិកម្មលើការបែងចែកនេះ ត្រូវបានប្រមូលមកបង្ហាញឡើយ។*

ក្នុងបរិបទនេះ គណៈកម្មាធិការនេះរកឃើញថា រដ្ឋភាគីបានរំលោភបំពានលើមាត្រា ២៦ នៃកតិកាសញ្ញា នេះដោយបដិសេធមិនផ្តល់សោធននិវត្តឲ្យទៅសាមីខ្លួន ដោយឈរលើមូលដ្ឋាននៃភេទ ឬ ទំនោរផ្លូវភេទរបស់គាត់។[116]

[112] កថាខណ្ឌទី ១២ (ខ)(១) នៃសេចក្តីសង្កេតទៅលេខ ១៨ (សិទ្ធិធ្វើការងារ) របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ។
[113] ដូចយោងខាងលើ ត្រង់កថាខណ្ឌទី ២៣ ។
[114] ដូចយោងខាងលើ ត្រង់កថាខណ្ឌទី ៣៣ ។
[115] CCPR/C/89/D/1361/2005 ត្រង់កថាខណ្ឌទី ៧.២ ។
[116] CCPR/C/78/D/941/2000 ត្រង់កថាខណ្ឌទី ១០.៤ ។

## ***សុខភាព***

មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) និងមនុស្សភេទពីរក៏ប្រឈមមុខផងដែរចំពោះឧបសគ្គមួយចំនួនក្នុងការប្រើប្រាស់សិទ្ធិផ្នែកសុខភាព។ មាត្រា ១២(១)នៃកតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចែងថាៈ"រដ្ឋភាគីនៃកតិកាសញ្ញានេះទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូបមានកម្រិតសុខភាពទាំងខាងរាងកាយ និង ខាងផ្លូវស្មារតីខ្ពស់បំផុតដែលអាចធ្វើទៅបាន"។ នៅក្នុងសេចក្តីសង្កេតទូទៅរបស់ខ្លួនលើមាត្រា ១២ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ បានថ្លែងថាៈ

*នៅក្នុងប្រទេសជាច្រើន អ្នកប្តូរភេទ ប្រឈមមុខនឹងការលំបាកពិសេសក្នុងទទួលបានការថែទាំសុខភាព ។*

> *សិទ្ធិផ្នែកសុខភាព គឺ មិនត្រូវយល់ថាជាសិទ្ធិមានសុខភាពល្អប៉ុណ្ណោះទេ។ សិទ្ធិផ្នែកសុខភាពមានទាំងសេរីភាព និង សិទ្ធិទទួលបាន។ សេរីភាពរួមបញ្ចូលសិទ្ធិគ្រប់គ្រងលើសុខភាព និង រាងកាយរបស់ខ្លួន ក្នុងនោះរួមមានសេរីភាពផ្នែកទំនាក់ទំនងផ្លូវភេទ និង សុខភាពបន្តពូជ និង សិទ្ធិរួចចាកផុតពីការជ្រៀតជ្រែក ដូចជាសិទ្ធិរួចចាកផុតពីការធ្វើទារុណកម្ម ការព្យាបាលសុខភាព និង ការពិសោធន៍ ដោយគ្មានការយល់ព្រម។ ផ្ទុយមកវិញសិទ្ធិទទួលបានរួមបញ្ចូលសិទ្ធិប្រើប្រាស់ប្រព័ន្ធគាំពារសុខភាពដែលផ្តល់ឱកាសស្មើគ្នាដល់មនុស្សក្នុងការទទួលបានសុខភាពតាមកម្រិតខ្ពស់បំផុត ដែលសម្រេចបាន។*[117]

នៅក្នុងសេចក្តីពន្យល់ទូទៅលេខ ១៤ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានថ្លែងថាកតិកាសញ្ញានេះ "ហាមឃាត់ការរើសអើងលើលទ្ធភាពទទួលបានការថែទាំសុខភាព និង កត្តាកំណត់ជាមូលដ្ឋាននៃសុខភាព ក៏ដូចជាទទួលបានមធ្យោបាយ និង សិទ្ធិទទួលបានការងាររបស់គេដោយឈរលើមូលដ្ឋាន ... ទំនោរផ្លូវភេទ" ។[118] នៅក្នុងសេចក្តីពន្យល់ទូទៅលេខ ២០ គណៈកម្មាធិការនេះ បានពន្យល់ថាមូលដ្ឋាននៃ "ស្ថានភាពផ្សេងទៀត" នៅក្នុងមាត្រា ២ នៃកតិកាសញ្ញានេះ រួមបញ្ចូលទាំងទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ។[119] ការធានាឲ្យមាន"សិទ្ធិមានលទ្ធភាពប្រើប្រាស់សម្ភារៈសុខាភិបាល និង ទទួលបានទំនិញ និង សេវា ដោយឈរលើមូលដ្ឋានមិនរើសអើងជាពិសេស សម្រាប់ក្រុមងាយរងគ្រោះ ឬ ទន់ខ្សោយ " គឺជាកាតព្វកិច្ចបន្ទាន់របស់រដ្ឋ។[120]

---

[117]កថាខណ្ឌទី ៨ នៃសេចក្តីពន្យល់ទូទៅលេខ ១៤ របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ។
[118]ដូចយោងខាងលើ ត្រង់កថាខណ្ឌទី ១៨ ។
[119]កថាខណ្ឌទី ៣២ នៃសេចក្តីពន្យល់ទូទៅលេខ ២០ របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ។
[120]កថាខណ្ឌទី ៤៣ (ក) នៃសេចក្តីពន្យល់ទូទៅលេខ ១៤ របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ។

ទោះបីជា អង្គការសុខភាពពិភពលោកបានដកការស្រលាញ់ភេទដូចគ្នា ពីតារាងចំណាត់ថ្នាក់ជំងឺរបស់ខ្លួននៅក្នុងឆ្នាំ១៩៩២ក៏ដោយប្រទេសមួយចំនួននៅតែចាត់ថ្នាក់ការស្រលាញ់ភេទដូចគ្នាជាជំងឺដដែល។ អ្នករាយការណ៍ពិសេសទទួលបន្ទុកការធ្វើទារុណកម្មបានកត់សំគាល់ថា "ក្រុមជនភាគតិចផ្នែកផ្លូវភេទ ត្រូវបានគេនិយាយថា ត្រូវបានកំណត់ដោយគ្មានការស្ម័គ្រចិត្តនៅក្នុងគ្រឹះស្ថានសុខាភិបាលរបស់រដ្ឋដែលនៅទីនោះ មានការចោទប្រកាន់ថាពួកគេ ត្រូវបានតម្រូវឲ្យទទួលការព្យាបាលដោយបង្ខំដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ ក្នុងនោះរួមមានការព្យាបាលដោយដាក់ឲ្យឆក់ខ្សែ ភ្លើង និង 'ការព្យាបាលមិនពេញចិត្ត' ផ្សេងទៀតដែលតាមរបាយការណ៍វាបណ្តាលឲ្យមានការប៉ះពាល់ដល់ផ្លូវចិត្ត និងផ្លូវកាយ" ។[121]

ការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ចំពោះទំនាក់ទំនងផ្លូវភេទរបស់មនុស្សមានភេទដូចគ្នា ប៉ះពាល់ដល់សិទ្ធិផ្នែកសុខភាព ដោយសារវារារាំងបុគ្គលទាំងឡាយមិនឲ្យការទទួលបានការថែទាំសុខភាព ដោយគ្មានការភ័យខ្លាចថាពួកគេអាចបញ្ចេញឲ្យដឹងជាសក្តានុពលនូវអំពើឧក្រិដ្ឋ និង ដោយសារវាលើកទឹកចិត្តដល់មន្ត្រីសុខាភិបាលបដិសេធការផ្តល់សេវា។ លើសពីនេះទៀត ការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះទំនាក់ទំនងផ្លូវភេទមានន័យថា ផែនការ និង គោលនយោបាយសុខភាពជាតិ មិនពិចារណាទៅលើសេចក្តីត្រូវការផ្នែកសុខភាពជាក់លាក់របស់សហគមន៍ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT)។ នៅក្នុងរបាយការណ៍ឆ្នាំ ២០១០ របស់ខ្លួនជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិផ្នែកសុខភាពបានពន្យល់ថា:

> *ច្បាប់ព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងទំនាក់ទំនងផ្លូវភេទដូចគ្នាដោយមានការព្រមព្រៀង ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រជារឿយៗរំលោភបំពានលើសិទ្ធិមនុស្សក្នុងនោះរួមមានសិទ្ធិផ្នែកសុខភាពផងដែរ។ ជាទូទៅច្បាប់ទាំងនេះមានជាប់ជាមួយនូវការរើសអើងហើយដូច្នេះវាបំពាន នឹងលក្ខខណ្ឌនៃវិធីសាស្ត្រសិទ្ធិផ្នែកសុខភាពដែលតម្រូវឲ្យមានសមភាពលើលទ្ធភាពទទួលបានសម្រាប់មនុស្សទាំងអស់។ផលប៉ះពាល់ពាក់ព័ន្ធនឹងសុខភាពនៃការរើសអើងដោយមានមូលដ្ឋាននៅលើទំនាក់ទំនងផ្លូវភេទ និងទំនោរផ្លូវភេទមានទំហំធំធេង និង រារាំងបុគ្គលទទួលរងគ្រោះមិនឲ្យមានលទ្ធភាពទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ផ្សេងទៀត។ បន្ទាប់មក ការរំលោភបំពានលើសិទ្ធិមនុស្សផ្សេងទៀតប៉ះពាល់លើការសម្រេចបានសិទ្ធិផ្នែកសុខភាព ដូចជា ដោយរារាំងលទ្ធភាពទទួលបានការងារ ឬ លំនៅឋាន ។[122]*

[121]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការធ្វើទារុណកម្ម (A/56/156) ត្រង់កថាខណ្ឌទី ២៤ ។

[122]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិរបស់មនុស្សរាល់រូបក្នុងការទទួលបានសុខភាពផ្លូវកាយ និងផ្លូវចិត្តតាមស្តង់ដាដែលអាចសម្រេចបានខ្ពស់បំផុត (A/HRC/14/20) ត្រង់កថាខណ្ឌទី ៦ ។



អ្នករាយការណ៍ពិសេសបានបែងចែកប្រភេទប៉ះពាល់នៃការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌលើសិទ្ធិផ្នែកសុខភាពជាបីយ៉ាង: ការរារាំងលើលទ្ធភាពទទួលបានសេវាសុខភាព អំពើហិង្សា និង ការរំលោភបំពាន និង ស្លាកស្នាមទុយ៌សសង្គម។ ក្នុងករណីដែលទំនាក់ទំនងផ្លូវភេទរបស់មនុស្សមានភេទដូចគ្នា ត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌបុគ្គលទាំងឡាយមិនអាចមានលទ្ធភាពទទួលបានសេវាសុខភាពប្រកបដោយប្រសិទ្ធភាពនិង វិធានការបង្ការផ្នែកសុខភាពមិនត្រូវបានតម្រូវទៅតាមសេចក្តីត្រូវការរបស់សហគមន៍មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ(LGBT)ឡើយ។ មន្ត្រីសុខាភិបាលអាចជំទាស់មិនព្រមព្យាបាលអ្នកជំងឺដែលស្រលាញ់ភេទដូចគ្នា ឬអាចឆ្លើយតបដោយមានអរិភាព។[123]ការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌបង្ហាញនូវស្លាកស្នាមទុយ៌ស"តាមរយៈការពង្រឹងបុរេនិច្ឆ័យ និង លក្ខណៈជាតួយ៉ាងដែលមានស្រាប់"។[124] បន្ទាប់មកការធ្វើឲ្យមានស្លាកស្នាមទុយ៌ស"រារាំងដល់ស្ថាប័ននីតិប្បញ្ញត្តិ និង ស្ថាប័នរៀបចំគោលនយោបាយមិនឲ្យដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសុខភាពបានពេញលេញនៅក្នុងសហគមន៍ ដែលងាយទទួលរងការរំលោភបំពានលើការទទួលបានសិទ្ធិផ្នែកសុខភាពយ៉ាងខ្លាំង"។[125] យោងតាមអ្នករាយការណ៍ពិសេសរដ្ឋទាំងឡាយមិនត្រូវចាត់ទុកទំនាក់ទំនងផ្លូវភេទដោយមានការព្រមព្រៀងរបស់មនុស្សមានភេទដូចគ្នាជាបទល្មើសព្រហ្មទណ្ឌឡើយ"ដើម្បីបំពេញកាតព្វ

[123]**ការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ និងសុខភាព៖** ដូចយោងខាងលើ ត្រង់កថាខណ្ឌទី ១៧-២១ ។
[124]ដូចយោងខាងលើ ត្រង់កថាខណ្ឌទី ២២ ។
[125]ដូចយោងខាងលើ ត្រង់កថាខណ្ឌទី ២៣ ។

កិច្ចសួលនៃសិទ្ធិផ្នែកសុខភាព និង បង្កើតឲ្យមានបរិយាកាសដែលជំរុញឲ្យមានការទទួលបានដោយពេញលេញ នូវសិទ្ធិនេះ ។[126]

ការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនូវទំនាក់ទំនងផ្លូវភេទដោយមានការព្រមព្រៀងគ្នាក៏មានឥទ្ធិពលអវិជ្ជមានលើយុទ្ធនាការផ្នែកសុខភាពសាធារណៈក្នុងការប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍។[127]ក្នុងរឿងក្តីរបស់*ទូណិន*គណៈកម្មាធិការសិទ្ធិមនុស្សបានបដិសេធការអះអាងរបស់អាជ្ញាធររដ្ឋតាស្មានីថាច្បាប់ដែលចាត់ទុកជាអំពើបទល្មើសព្រហ្មទណ្ឌ នូវទំនាក់ទំនងផ្លូវភេទដោយមានការព្រមព្រៀងគ្នារបស់ មនុស្សមានភេទដូចគ្នាជាវិធានការផ្នែកសុខភាពសាធារណៈដ៏ចាំបាច់មួយ។ផ្ទុយមកវិញដូចដែលរដ្ឋាភិបាលអូស្ត្រាលី បានសង្កេត "ច្បាប់ដែលចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនូវសកម្មភាពផ្លូវភេទរបស់មនុស្សភេទដូចគ្នាមានទំនោររារាំងកម្មវិធីផ្នែកសុខភាពសាធារណៈតាមរយៈការជំរុញដោយសម្ងាត់នូវមនុស្សជាច្រើនឲ្យប្រឈមនឹងការឆ្លងជំងឺ។ ដូចនេះ ការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនូវសកម្មភាពផ្លូវភេទរបស់មនុស្សភេទដូចគ្នានឹងហាក់ដូចជាមានភាពផ្ទុយទៅនឹងការអនុវត្តកម្មវិធីអប់រំប្រកបដោយប្រសិទ្ធភាពចំពោះការបង្ការមេរោគអេដស៍/ជំងឺអេដស៍"។[128]

ផលវិបាកជាអវិជ្ជមានផ្នែកសុខភាពសាធារណៈនៃច្បាប់ព្រហ្មទណ្ឌជាញឹកញាប់ត្រូវបានលើកឡើងដោយអ្នករាយការណ៍ពិសេស។នៅក្នុងលិខិតរួមស្តីពីការចោទប្រកាន់ពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ប្រឆាំងនឹង ការស្រលាញ់មនុស្សភេទដូចគ្នានៅប្រទេសអ៊ូហ្គាន់ដា យន្តការនីតិវិធីពិសេសបួន បានសរសេរថាៈ

> *ប្រសិនបើច្បាប់បានចូលជាធរមាន វានឹងរារាំងដល់លទ្ធភាពទទួលបានព័ត៌មាន និង សេវាពាក់ព័ន្ធនឹងមេរោគអេដស៍ និងសុខភាព សម្រាប់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) ហេតុនេះ អាចធ្វើឲ្យអន្តរាយដល់ការឆ្លើយតបរបស់ជាតិទៅនឹងមេរោគអេដស៍ ដោយមិនត្រឹមតែតាមរយៈការធ្វើឲ្យមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) រួញរាក្នុងការស្វែងរក និង ទទួលបានសេវាប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងរារាំងអ្នកផ្តល់សេវាមិនឲ្យផ្តល់ព័ត៌មាន និងសេវាដល់សមាជិកសហគមន៍នេះទៀតផង ។*[129]

ពាក់ព័ន្ធនឹងច្បាប់ដែលត្រូវបានស្នើឡើងនៅប្រទេសប៊ូរុនឌី អ្នករាយការណ៍ពិសេសទទួលបន្ទុកសុខ-ភាពបានសរសេរថាការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះការស្រលាញ់មនុស្សភេទដូចគ្នា នឹងមានបុរេ

[126]ដូចយោងខាងលើ ត្រង់កថាខណ្ឌទី ២៦ ។

[127]ការចាត់ទុកជាបទល្មើស និងមេរោគអេដស៍/ជំងឺអេដស៍ៈ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសកាមេរូន (CCPR/C/CMR/CO/4) ត្រង់កថាខណ្ឌទី ១២សម្រាប់ចាម៉ៃកា (CCPR/C/JAM/CO/3) ត្រង់កថាខណ្ឌទី ៩ ។

[128]CCPR/C/50/D/488/1992 ត្រង់កថាខណ្ឌទី ៨.៥ ។

[129]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការប្រហារជីវិតក្រៅតុលាការ ដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់ ឬ ដោយបំពាន (A/HRC/14/24/Add.1) ត្រង់កថាខណ្ឌទី ១១៤១ ។

និច្ឆ័យដែលប៉ះពាល់លើកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសប៊ូរុនឌី ក្នុងការប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ គាត់បានថ្លែងថា:

*គោលនយោបាយផ្នែកសុខភាពសាធារណៈស្ដីពីការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ បង្ហាញយ៉ាងច្បាស់លាស់ថាការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះការស្រលាញ់មនុស្សភេទដូចគ្នា ដែលត្រូវបានភ្ជាប់ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងការរើសអើងចំពោះមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្ដូរភេទ (LGBT) ជាឧបករណ៍ដ៏ធំមួយ ដើម្បីរាំងស្កាត់ការរាលដាលនៃមេរោគនេះ។ ក្រៅពីនេះ ប្រសិនបើសេចក្ដីព្រាងក្រមដែលកំពុងពិភាក្សាចូលជាធរមានវានឹងរារាំងដល់លទ្ធភាពទទួលបានព័ត៌មានការថែទាំ និង ការព្យាបាលចំពោះមនុស្សប្រតិព័ទ្ធមនុស្សភេទដូចគ្នាដែលមានផ្ទុកមេរោគអេដស៍នៅក្នុងប្រទេសប៊ូរុនឌីហេតុដូច្នេះហើយអាចធ្វើឲ្យគ្រោះថ្នាក់ដល់ការឆ្លើយតបរបស់ជាតិទៅនឹងការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍។*[130]

សេចក្ដីពន្យល់ស្រដៀងគ្នានេះត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងច្បាប់ដែលត្រូវបានស្នើឡើងនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ។[131]

នៅក្នុងប្រទេសជាច្រើន អ្នកប្ដូរភេទប្រឈមមុខនឹងការលំបាកពិសេសលើលទ្ធភាពទទួលបានការថែទាំសុខភាព។ ការព្យាបាលប្ដូរភេទ ក្នុងករណីដែលមានជារឿយៗមានតម្លៃថ្លៃណាស់ហើយមូលនិធិរបស់រដ្ឋ ឬ វិសាលភាពនៃការធានារ៉ាប់រងកម្រមានណាស់។ មន្ត្រីសុខាភិបាលជារឿយៗមិនខ្វល់នឹងសេចក្ដីត្រូវការ របស់អ្នកប្ដូរភេទ និងខ្វះការបណ្ដុះបណ្ដាលអាជីពចាំបាច់។[132]លើសពីនេះទៀតកុមារមានភេទពីរដែលកើតមកមានចរិតលក្ខណៈភេទមិនមែនប្រក្រតីជារឿយៗត្រូវទទួលរងការរើសអើង និង ការវះកាត់ផ្នែកវេជ្ជសាស្ត្រ ដែលមិនចាំបាច់ ដែលត្រូវបានធ្វើឡើងដោយគ្មានការយល់ព្រមជាមុនពីពួកគេ ឬ ការយល់ព្រមពីមាតាបិតារបស់ពួកគេក្នុង ការប៉ុងប៉ងកែភេទរបស់ពួកគេ ។[133]

*ជារឿយៗវាគឺនៅក្នុងទីធ្លាសាលាបឋមសិក្សាដែលក្មេងប្រុស ត្រូវបានក្មេងដទៃទៀតចាត់ទុកថាដូចស្រីពេក ឬ ក្មេងស្រី ដែលត្រូវបានចាត់ទុកថាស្រីមានឫកពារដូចប្រុស ត្រូវប្រឈមមុខ នឹងការជន្លជន្លេញ និងជួនកាលការវាយប្រហារបឋម ។*

---

[130]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិរបស់មនុស្សរាល់រូបក្នុងការទទួលបានសុខភាពផ្លូវកាយ និងផ្លូវចិត្តតាមស្តង់ដាដែលអាចសម្រេចបានខ្ពស់បំផុត (A/HRC/14/20/Add.1) ត្រង់កថាខណ្ឌទី ១៤ (ការបកប្រែភាសាមិនផ្លូវការ) ។

[131]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមានសេរីភាពនៃគំនិតនិងការសម្តែងមតិ (A/HRC/17/27,27) ត្រង់កថាខណ្ឌទី ៦៧៥ ។

[132]"សិទ្ធិមនុស្ស និងអត្តសញ្ញាណយេនឌ័រ" របស់ក្រុមប្រឹក្សាស្នងការអឺរ៉ុបទទួលបន្ទុកសិទ្ធិមនុស្ស ឆ្នាំ ២០០៩ ត្រង់កថាខណ្ឌទី ៣.៣ ។ "ការបង្ការ និងការព្យាបាលមេរោគអេដស៍ និងជំងឺកាមរោគផ្សេងទៀត" របស់អង្គការសុខភាពពិភពលោក ត្រង់ទំព័រទី ៣០-៣១ ។

[133]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងចំពោះស្ត្រីភេទសម្រាប់ប្រទេសកូស្តារីកា (CEDAW/C/CRI/CO/5-6) ត្រង់កថាខណ្ឌទី ៤០ ។

## ការអប់រំ

ការរើសអើងនៅតាមសាលារៀន និង មជ្ឈដ្ឋានអប់រំផ្សេងទៀតធ្វើឲ្យអន់ថយយ៉ាងធ្ងន់ធ្ងរដល់ លទ្ធភាពរបស់យុវជនដែលត្រូវបានយល់ឃើញថាជាមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ឬ មនុស្សភេទពីរ ដែលត្រូវបានផ្តល់នូវសិទ្ធិទទួលបានការអប់រំរបស់ពួកគេ។ ក្នុងករណីខ្លះអាជ្ញាធរផ្នែកអប់រំ និង សាលារៀន រើសអើងយ៉ាងសកម្មចំពោះយុវជនដោយសារតែទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេជួនកាលនាំទៅដល់ការបដិសេធការចូលរៀន របស់ពួកគេ ឬ ត្រូវបានបណ្តេញចេញ។[134]

លើសពីនេះទៀត យុវនារីស្រលាញ់ភេទដូចគ្នា យុវជនស្រលាញ់ភេទដូចគ្នា យុវជនយុវនារីស្រលាញ់ភេទទាំងពីរ និងយុវជនយុវនារីប្តូរភេទ (LGBT) និង យុវជនវនារីភេទពីរ ជាញឹកញាប់ជួបប្រទះនឹងអំពើហិង្សា និងការយាយីរំខាន ក្នុងនោះរួមមានការសម្លុតកំហែងនៅក្នុងសាលារៀនពី សំណាក់មិត្តរួមថ្នាក់និង គ្រូបង្រៀន។[135]ការប្រឈមមុខនឹងបុរេនិច្ឆ័យប្រភេទនេះ និង ការបំភិតបំភ័យតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងរួមពីសំណាក់អាជ្ញាធរនៅតាមសាលារៀន និង ផ្នែកអប់រំ និង ការធ្វើសមាហរណកម្មគោលការណ៍មិនរើសអើង និង ភាពចម្រុះទៅក្នុងកម្មវិធីសិក្សារបស់សាលា រៀន និង កម្មវិធីទំនាក់ទំនង។ ប្រព័ន្ធផ្សព្វផ្សាយ ក៏មានតួនាទីដែលត្រូវបានអនុវត្តផងដែរដោយលុបបំបាត់ទម្លាប់អវិជ្ជមានរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) ក្នុងនោះរួមមាននៅក្នុងកម្មវិធីទូរទស្សន៍ ដែលមានប្រជាប្រិយភាពនៅក្នុងចំណោមយុវជន។

គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ និងគណៈកម្មាធិការសិទ្ធិកុមារបានសម្តែងចេញនូវកង្វល់អំពីការរើសអើងដោយសារការស្អប់មនុស្សស្រលាញ់ភេទដូចគ្នានៅតាមសាលារៀននិងបានអំពាវនាវសុំឲ្យមានវិធានការតបទៅនឹងឥរិយាបថស្អប់មនុស្សភេទដូចគ្នានិងការស្អប់មនុស្សប្តូរភេទ។[136] យោងតាមអង្គការអប់រំវិទ្យាសាស្ត្រ និង វប្បធម៌នៃអង្គការសហប្រជាជាតិ "ជារឿយៗវានៅក្នុងទីធ្លាសាលាបឋមសិក្សាដែលក្មេងប្រុសត្រូវបានក្មេងដទៃទៀតចាត់ទុកថាដូចស្រីពេក ឬ ក្មេងស្រីដែលត្រូវបានចាត់ទុកថាជាស្រីមានឫកពារដូចប្រុសត្រូវប្រឈមមុខនឹងការជន្លជន្លេញ និង ជួនកាលការវាយ

[134]E/CN.4/2006/45 ត្រង់កថាខណ្ឌទី ១១៣ ។

[135]សូមមើល ឧទាហរណ៍ៈ E/CN.4/2001/52 ត្រង់កថាខណ្ឌទី ៧៥ និង E/CN.4/2006/45 ត្រង់កថាខណ្ឌទី ១១៣ ។

[136]សូមមើលឧទាហរណ៍ៈ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសម៉ិកស៊ិក (CCPR/C/MEX/CO/5) ត្រង់កថាខណ្ឌទី ២១សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សិទ្ធិផ្នែកសង្គម និងសិទ្ធិផ្នែកវប្បធម៌សម្រាប់ប្រទេសប៉ូឡូញ (E/C.12/POL/CO/5) ត្រង់កថាខណ្ឌទី ១២-១៣ និងសេចក្តីពន្យល់ទូទៅលេខ ៣ (CRC/GC/2003/3) ត្រង់កថាខណ្ឌទី ៨ និងលេខ ១៣ (CRC/C/GC/13) ត្រង់កថាខណ្ឌទី ៦០ និងទី ៧២(ឆ) របស់គណៈកម្មាធិការសិទ្ធិកុមារ និងសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសម្រាប់ប្រទេសនូវ៉ែលសេឡង់ (CRC/C/NZL/CO/3-4) ត្រង់កថាខណ្ឌទី ២៥ សម្រាប់ប្រទេសស្លូវ៉ាគី (CRC/C/SVK/CO/2) ត្រង់កថាខណ្ឌទី ២៧-២៨ និងសម្រាប់ប្រទេសម៉ាឡេស៊ី (CRC/C/MYS/CO/1) ត្រង់កថាខណ្ឌទី ៣១ ។

ប្រហារបឋម ដែលត្រូវបានផ្សារភ្ជាប់ទំនាក់ទំនងទៅនឹងអាការៈខាងក្រៅ និង អាកប្បកិរិយារបស់ពួកគេដែលត្រូវបានចាត់ទុកថាមិនត្រូវគ្នានឹងអត្តសញ្ញាណភេទផ្ទុយគ្នាដែលមានជាធម្មនិយាម"។[137]

ការដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា និង ស្លាកស្នាមទុយ៌សធ្វើឲ្យមានការធ្លាក់ទឹកចិត្ត និង បញ្ហាផ្នែកសុខភាពផ្សេងទៀត និងរួមចំណែកធ្វើឲ្យមានការគេចមិនទៅរៀន អវត្តមានពីសាលារៀន កុមារដែលត្រូវបង្ខំឲ្យបោះបង់ការសិក្សា[138] និងក្នុងករណីធ្ងន់ធ្ងរបំផុតការធ្វើអត្តឃាតដោយគ្រោងទុកមុន ឬ ជាក់ស្តែង ។[139] ការអង្កេតមួយដែលត្រូវបានធ្វើឡើងនៅក្នុងចក្រភពអង់គ្លេស បានរកឃើញថាជិត៦៥ភាគរយ នៃយុវនារីស្រលាញ់ភេទដូចគ្នា យុវជនស្រលាញ់ភេទដូចគ្នា និងយុវជនយុវនារីស្រលាញ់ភេទទាំងពីរ ត្រូវបានសម្លុតកំហែងនៅតាមសាលារៀន ដោយសារតែទំនោរផ្លូវភេទ និងជាងមួយភាគបួនត្រូវបានរំលោភបំពានផ្នែកផ្លូវកាយ។[140] លទ្ធផលរកឃើញទាំងនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈលទ្ធផលនៃការសិក្សាដែលត្រូវបានធ្វើឡើងនៅក្នុងប្រទេសផ្សេងទៀត ។[141]

កង្វះពាក់ព័ន្ធ គឺការអប់រំផ្លូវភេទ។ សិទ្ធិទទួលបានការអប់រំ រួមបញ្ចូលសិទ្ធិទទួលបានព័ត៌មានដ៏ទូលំទូលាយត្រឹមត្រូវ និងសមស្របតាមអាយុស្តីពីទំនាក់ទំនងផ្លូវភេទរបស់មនុស្សដើម្បីធានាថាយុវជនអាចទទួលបានព័ត៌មានដែលចាំបាច់ ដើម្បីឲ្យមានជីវិតរស់នៅដ៏ចម្រើនរុងរឿងធ្វើការសម្រេចចិត្តដែលផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយ និងការពារខ្លួនឯង និងអ្នកដទៃពីជំងឺកាមរោគ។[142] អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិទទួលបានការអប់រំបានកត់សំគាល់ថា "ដើម្បីឲ្យមានលក្ខណៈទូលំទូលាយ ការអប់រំផ្លូវភេទ ត្រូវតែយក

[137] "ការពិគ្រោះយោបល់អន្តរជាតិលើការសម្លុតកំហែង និងការយាយីរំខានដោយសារការស្អប់មនុស្សស្រលាញ់ ភេទដូចគ្នានៅក្នុងគ្រឹះស្ថានអប់រំ" នៅក្នុងសេចក្តីកត់សំគាល់នាខែ កក្កដា ឆ្នាំ ២០១១ របស់អង្គការអប់រំ វិទ្យាសាស្រ្ត និងវប្បធម៌នៃអង្គការសហប្រជាជាតិ ។ សូមមើលផងដែរ "ការឆ្លើយតបនៃវិស័យអប់រំទៅនឹងការសម្លុតកំហែងដោយសារការស្អប់មនុស្សស្រលាញ់ភេទដូចគ្នា" ឆ្នាំ ២០១២ របស់អង្គការអប់រំ វិទ្យាសាស្រ្ត និងវប្បធម៌នៃអង្គការសហប្រជាជាតិ ។

[138] សូមមើល ឧទាហរណ៍: E/CN.4/2006/45 ត្រង់កថាខណ្ឌទី ១១៣ ។

[139] E/CN.4/2003/75/Add.1 ត្រង់កថាខណ្ឌទី ១៥០៨ ។

[140] Ruth Hunt និង Johan Jensen៖ "បទពិសោធន៍របស់យុវជនស្រលាញ់ភេទដូចគ្នា

[141] "ការផាត់ចេញពីសង្គមនៃយុវនារីស្រលាញ់ភេទដូចគ្នា យុវជនស្រលាញ់ភេទដូចគ្នា យុវជនយុវនារីស្រលាញ់ភេទទាំងពីរ និងយុវជនយុវនារីប្តូរភេទនៅអឺរ៉ុប" សមាគមស្រីស្រលាញ់ភេទដូចគ្នា ប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សមានភេទពីរនៅតំបន់អឺរ៉ុប និងអង្គការអន្តរជាតិនៃយុវជនស្រលាញ់ភេទដូចគ្នា និងយុវនារីស្រលាញ់ភេទដូចគ្នា ឆ្នាំ ២០០៦ ។

[142] សូមមើលកថាខ័ណ្ឌទី ២៦ និងទី ២៨ នៃសេចក្តីពន្យល់ទូទៅលេខ ៤ (CRH/GC/2003/4) របស់គណៈកម្មាធិការសិទ្ធិកុមារ ។ សូមមើលផងដែរ កថាខណ្ឌទី ៧.៤៧ នៃកម្មវិធីសកម្មភាពនៅក្នុងសន្និសីទអន្តរជាតិស្តីពីប្រជាជន និងការអភិវឌ្ឍ កថាខណ្ឌទី ៧ នៃសេចក្តីសម្រេចលេខ 2009/1 របស់គណៈកម្មការទទួលបន្ទុកប្រជាជន និងការអភិវឌ្ឍ និងផ្នែក ២.៣ និង ៣.៤ នៃសេចក្តីណែនាំបច្ចេកទេសអន្តរជាតិស្តីពីការអប់រំលើទំនាក់ទំនងផ្លូវភេទនៃអង្គការអប់រំ វិទ្យាសាស្រ្ត និងវប្បធម៌នៃអង្គការសហប្រជាជាតិ ។

ចិត្តទុកដាក់ជាពិសេសទៅលើភាពចម្រុះដោយហេតុថា មនុស្សរាល់រូបមានសិទ្ធិដោះស្រាយបញ្ហាទំនាក់ទំនងផ្លូវភេទរបស់ខ្លួនផ្ទាល់" ។[143]

## ការទទួលស្គាល់ទំនាក់ទំនង

នៅក្នុងប្រទេសខ្លះ រដ្ឋផ្ដល់ប្រយោជន៍ដល់គូស្វាមីស្រលាញ់ភេទផ្ទុយគ្នាដែលបានរៀបការរួចហើយ និង ដែលមិនទាន់បានរៀបការ ប៉ុន្តែបដិសេធប្រយោជន៍ទាំងនេះចំពោះគូស្វាមីស្រលាញ់ភេទដូចគ្នាដែលមិនទាន់បានរៀបការ។ ឧទាហរណ៍ រួមបញ្ចូលសិទ្ធិទទួលបានសោធននិវត្ត លទ្ធភាពបន្សល់ទុកទ្រព្យសម្បត្តិទៅដៃគូដែលនៅរស់រានមានជីវិតឱកាសរស់នៅក្នុងជម្រកសាធារណៈបន្ទាប់ពីមរណភាពរបស់ដៃគូ ឬឱកាសជានានិវាសនដ្ឋានសម្រាប់ដៃគូបរទេស។កង្វះការទទួលស្គាល់ជាផ្លូវការលើទំនាក់ទំនងមនុស្សមានភេទដូចគ្នា និង អវត្តមាននៃការហាមឃាត់តាមផ្លូវច្បាប់លើការរើសអើង ក៏អាចបណ្ដាលឲ្យដៃគូមានភេទដូចគ្នាទទួលការរើសអើងពីសំណាក់តួអង្គឯកជន ក្នុងនោះរួមមាន អ្នកថែទាំសុខភាព និង ក្រុមហ៊ុនធានារ៉ាប់រង ។

ដូចមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ រដ្ឋទាំងឡាយមិនបានតម្រូវឲ្យអនុញ្ញាតឲ្យគូស្វាមីមានភេទដូចគ្នារៀបការទេ។[144] សូម្បីដូច្នោះក៏ដោយ កាតព្វកិច្ចការពារបុគ្គលទាំងឡាយពីការរើសអើងដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ រួមបញ្ចូលការធានាថា គូស្វាមីមានភេទដូចគ្នាដែលមិនទាន់បានរៀបការត្រូវបានទទួលស្គាល់ដូចគ្នា និងត្រូវបានផ្ដល់នូវសិទ្ធិទទួលបានប្រយោជន៍ដូចគ្នានឹងគូស្វាមីមានភេទផ្ទុយគ្នាដែលមិនទាន់រៀបការដែរ។[145] គណៈកម្មាធិការសិទ្ធិមនុស្ស បានទទួលស្វាគមន៍វិធានការដើម្បីដោះស្រាយបញ្ហានៃការរើសអើងនៅក្នុងបរិបទនេះ។ នៅក្នុងសេចក្ដីសង្កេតសន្និដ្ឋានរបស់ខ្លួនសម្រាប់ប្រទេសអៀរឡង់ គណៈកម្មាធិការបានជំរុញឲ្យរដ្ឋភាគីធានាថាសេចក្ដីស្នើច្បាប់ដែលកំណត់អំពីភាពជាដៃគូជាពលរដ្ឋ "មិនមានលក្ខណៈរើសអើងលើទម្រង់ជាដៃគូដែលមិនមែនជាប្រពៃណី ក្នុងនោះរួមមានប្រយោជន៍ផ្នែកពន្ធដារ និងសុខុមាលភាព" ។[146]

---

[143] A/65/162 ត្រង់កថាខណ្ឌទី ២៣ ។ សូមមើលផងដែរ "ការអប់រំផ្លូវភេទដ៏ទូលំទូលាយៈ ការផ្ដល់ដល់យុវជននូវព័ត៌មាន ជំនាញ និងចំណេះដឹងដែលពួកគេត្រូវការចាំបាច់" នៃមូលនិធិសហប្រជាជាតិដើម្បីប្រជាជន និង "ស្តង់ដាអប់រំផ្លូវភេទនៅអឺរ៉ុប" នៃការិយាល័យប្រចាំតំបន់អឺរ៉ុបរបស់អង្គការសុខភាពពិភពលោក និងមជ្ឈមណ្ឌលសហព័ន្ធដើម្បីការអប់រំសុខភាព ត្រង់ទំព័រទី ២៧ ។

[144] CCPR/C/75/D/902/1999 និង 10 IHRR 40 (2003) ។

[145] CCPR/C/78/D/941/2000 ត្រង់កថាខណ្ឌទី ១០.៤ ។

[146] សេចក្ដីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់ប្រទេសអៀរឡង់ (CCPR/C/IRL/CO/3) ត្រង់កថាខណ្ឌទី ៨ ។

## សេចក្ដីសន្និដ្ឋាន

រដ្ឋទាំងឡាយ តម្រូវឲ្យធានាមិនឲ្យមានភាពរើសអើងក្នុងការប្រើប្រាស់សិទ្ធិមនុស្សទាំងអស់ចំពោះមនុស្សគ្រប់រូបដោយមិនគិតអំពីទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ។ នេះគឺជាកាតព្វកិច្ចបន្ទាន់ និងពហុវិស័យដូចមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ រដ្ឋទាំងឡាយគួរតែអនុម័តច្បាប់គ្រប់ជ្រុងជ្រោយដែលហាមឃាត់ការរើសអើងដោយឈរលើមូលដ្ឋាននៃទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ ទាំងនៅក្នុងវិស័យសាធារណៈនិងឯកជន។ ច្បាប់បែបនេះ គួរតែរួមបញ្ចូលនូវដំណោះស្រាយសម្រាប់ជនរងគ្រោះដោយសារការរើសអើង។ រដ្ឋទាំងឡាយ ក៏គួរតែប្រើប្រាស់យុទ្ធនាការលើកកម្ពស់ការយល់ដឹង និង កម្មវិធីបណ្ដុះបណ្ដាល ដើម្បីបង្ការទប់ស្កាត់ការរើសអើង តាមរយៈការដោះស្រាយបញ្ហានៃឥរិយាបថសង្គមដែលមានលក្ខណៈរើសអើង ។

## ៥. គោរពសេរីភាពក្នុងការសម្តែងមតិ ធ្វើសមាគម និង ជួបជុំដោយសន្តិវិធី

*ការកម្រិតលក្ខខណ្ឌលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ធ្វើសមាគម និងជួបជុំដោយសន្តិវិធី ដែលមានមូលដ្ឋាននៅលើទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័ររបស់បុគ្គល ជាការរំលោភបំពានលើសិទ្ធិដែលត្រូវបានធានាដោយមាត្រា ១៩ និង មាត្រា ២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ១៩ មាត្រា ២១ និង មាត្រា ២២ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ការកម្រិតលក្ខខណ្ឌលើសិទ្ធិទាំងនេះ ត្រូវតែស្របទៅនឹងបទប្បញ្ញត្តិច្បាប់អន្តរជាតិស្តីពីភាពមិនរើសអើង។*



## សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

**មាត្រា ១៩៖** មនុស្សគ្រប់រូប មានសិទ្ធិមានសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ ។ សិទ្ធិនេះ រួមបញ្ចូលសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងផ្សព្វផ្សាយព័ត៌មាន និងមតិយោបល់។

**មាត្រា ២០(១)៖** មនុស្សគ្រប់រូប មានសិទ្ធិមានសេរីភាពក្នុងការជួបជុំដោយសន្តិវិធី និងធ្វើសមាគម។

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

**មាត្រា ១៩(២)៖** ជនគ្រប់រូប ត្រូវមានសិទ្ធិសេរីភាពក្នុងការការបញ្ចេញមតិ ។ សិទ្ធិនេះត្រូវរួមបញ្ចូលសេរីភាពក្នុងការស្រាវជ្រាវ ទទួល និងចែកផ្សាយព័ត៌មាន និងមតិយោបល់គ្រប់បែបយ៉ាង ដោយមិនគិតពីកម្រិតព្រំដែន ទោះជាដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬ ដោយបោះពុម្ពជាទម្រង់សិល្បៈ ឬ តាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយផ្សេងទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន ។

**មាត្រា ២១៖** សិទ្ធិក្នុងការជួបជុំដោយសន្តិវិធី ត្រូវតែទទួលស្គាល់ ។ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតដែលកំណត់ដោយច្បាប់ប៉ុណ្ណោះ និង ដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬ សុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬ សីលធម៌ ឬ ការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

**មាត្រា ២២(១)៖** ជនគ្រប់រូប មានសិទ្ធិចូលរួមសមាគមដោយសេរីជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើត សហជីព និងសិទ្ធិចូលជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

# គោលជំហររបស់យន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សធានាចំពោះមនុស្សរាល់រូបនូវសិទ្ធិសេរីភាពក្នុងការមានមតិ និង សម្តែងមតិ ការជួបជុំដោយសន្តិវិធី និងការធ្វើសមាគម។ សិទ្ធិដូចគ្នាទាំងនេះ ត្រូវបានធានាដោយមាត្រា១៩ មាត្រា២១ និងមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ។ សេរីភាពក្នុងការសម្តែងមតិ រួមបញ្ចូលសិទ្ធិ "ក្នុងការស្វែងរក ទទួល និងចែកផ្សាយព័ត៌មាន និងមតិយោបល់គ្រប់ប្រភេទទាំងអស់ ដោយមិនគិតអំពីកម្រិតព្រំដែន ទោះជាដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬ ដោយបោះពុម្ពជាទម្រង់សិល្បៈ ឬ តាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយផ្សេងទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន"។[147] វាមានលក្ខណៈសំខាន់ចំពោះការទទួលបានសិទ្ធិក្នុងការធ្វើសមាគម និងជួបជុំ ។ សេរីភាពក្នុងការធ្វើសមាគមជំរុញឲ្យបុគ្គលទាំងឡាយចូលរួមប្រមូលផ្តុំគ្នា ដើម្បីរួមគ្នាបង្ហាញលើកកម្ពស់ ស្វែងរក និងការពារផលប្រយោជន៍រួម។

[147] មាត្រា ១៩(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ។




សេរីភាពក្នុងការជួបជុំសំដៅទៅលើប្រភេទណាមួយនៃការជួបប្រជុំទោះ ជាសាធារណៈ ឬ ជាលក្ខណៈឯកជនក្នុងនោះរួមមានបាតុកម្មការដើរក្បួន និង ព្យុះហយាត្រាផងដែរ។ ទាំងនេះ គឺជាសិទ្ធិដែលជាផ្នែកសំខាន់បំផុតនៃសង្គមស៊ីវិលដ៏សកម្មនិងប្រជាធិបតេយ្យដែលកំពុងតែដំណើរការ។ វាក៏ជាសិទ្ធិដែលមានលក្ខណៈចាំបាច់ចំពោះការងាររបស់អ្នកការពារសិទ្ធិនុស្សផងដែរ។

ការដាក់កំហិតលក្ខខណ្ឌលើការទទួលបានសិទ្ធិមានសេរីភាពក្នុងការធ្វើសមាគម ការសម្តែងមតិ និងការជួបជុំរបស់បុគ្គល និង អង្គការផ្នែកមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ(LGBT) ត្រូវបានចងក្រងជាឯកសារយ៉ាងទូលំទូលាយដោយយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ច្បាប់ដែលហាមឃាត់"ការផ្សព្វផ្សាយជាសាធារណៈចំពោះការស្រលាញ់មនុស្សភេទដូចគ្នា" ឬ "ការឃោសនាអំពីការស្រលាញ់មនុស្សភេទដូចគ្នា" អាចបញ្ឈប់ការពិភាក្សាណាមួយលើទំនាក់ទំនងផ្លូវភេទនៅក្នុងវិស័យសាធារណៈ។នៅក្នុងប្រទេសខ្លះការដើរក្បួនព្យុះហយាត្រា និង ការប្រជុំផ្សេងទៀតរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទ ដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ត្រូវបានបដិសេធមិនចេញលិខិតអនុញ្ញាតឲ្យ ឬត្រូវបានប្រឈមមុខនឹងការគំរាមកំហែង និងអំពើហិង្សាពីអ្នកឃ្លាំមើល។[148] ក្រុមជាច្រើនប្រឈមមុខនឹងការបដិសេធមិនអនុញ្ញាតឲ្យចុះបញ្ជីជាផ្លូវការជាអង្គការមិនមែនរដ្ឋាភិបាល ឬ សមាគម។ ឧទាហរណ៍ នៅក្នុងករណីដែល

[148] សូមមើលឧទាហរណ៍: របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកទម្រង់សហសម័យនៃការប្រកាន់ជាតិសាសន៍ (E/CN.4/2006/16/Add.1) ត្រង់កថាខណ្ឌទី ៧២ ។

ពាក់ព័ន្ធនឹងការគំរាមកំហែងដល់អាយុជីវិតចំពោះវេទិកាស្តីពីមនុស្សស្រីស្រលាញ់ភេទដូចគ្នាមនុស្សស្រលាញ់គ្រប់ភេទ និង មនុស្សប្រុសស្រលាញ់ភេទដូចគ្នា (JFLAG) នៅចាម៉ៃកា អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមានសេរីភាពក្នុងការមានមតិ និងការសម្តែងមតិបានផ្ញើលិខិតស្តីពីការចោទប្រកាន់ ដោយសម្តែងចេញនូវកង្វល់ថាៈ

*បុគ្គលនិងសមាគមទាំងឡាយដែលការពារសិទ្ធិរបស់បុរស និង ស្ត្រីដែលស្រលាញ់ភេទដូចគ្នា ជាពិសេសសមាជិកវេទិកាស្តីពីមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់គ្រប់ភេទ និង មនុស្សប្រុសស្រលាញ់ភេទដូចគ្នា (JFLAG) នៅចាម៉ៃកា អាចប្រឈមមុខនឹងការប៉ុងប៉ងរបស់អាជ្ញាធរសាធារណៈក្នុងការបង្ក្រាបការប្រើប្រាស់សេរីភាពក្នុងការនិយាយស្តីរបស់ពួកគេម្យ៉ាងទៀត ប្រឈមមុខនឹងការវាយប្រហារដោយហិង្សារបស់បុគ្គលស្អប់ មនុស្សស្រលាញ់ភេទដូចគ្នា ដែលអាចមានការចាប់អារម្មណ៍ថា រដ្ឋាភិបាលនឹងមិនប្រព្រឹត្តអំពើហិង្សាខ្លាំងក្លាបែបនេះទេ។[149]*

បន្ទាប់ពីពិធីព្យុះហយាត្រាជាប្រពៃណីរបស់សហគមន៍មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ(LGBT) ត្រូវបានហាមឃាត់នៅទីក្រុងមូស្គូម គណៈកម្មាធិការសិទ្ធិមនុស្សបានជំរុញឲ្យសហព័ន្ធរុស្ស៊ី "អនុវត្តវិធានការចាំបាច់ទាំងអស់ដើម្បីធានាឲ្យមានការប្រើប្រាស់ជាក់ស្តែងនូវសិទ្ធិធ្វើសមាគម និង ជួបជុំដោយសន្តិវិធីចំពោះសហគមន៍មនុស្សស្រីស្រ-លាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ (LGBT)"។[150]នៅពេលដែលសភាលីទុយអានីបាននិងកំពុងតែពិចារណាទៅលើសេចក្តីព្រាងច្បាប់ដែលនឹងហាមឃាត់ការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានស្តីពីមនុស្សស្រីស្រលាញ់ភេទដូចគ្នានិងមនុស្សស្រលាញ់ភេទទាំងពីរ អ្នករាយការណ៍ពិសេសទទួលបន្ទុកសេរីភាពក្នុងការបញ្ចេញមតិ និងការសម្តែងមតិ និងអ្នកការពារសិទ្ធិមនុស្សបានចេញ សេចក្តីអំពាវនាវរួមគ្នាជាបន្ទាន់មួយ ដោយសម្តែងនូវកង្វល់ថាច្បាប់ នឹង កម្រិតលក្ខខណ្ឌលើសិទ្ធិមានសេរីភាពក្នុងការសម្តែងមតិ និង ដាក់កំហិតលក្ខខណ្ឌលើ "ការងារត្រឹមត្រូវតាមច្បាប់របស់អ្នកការពារសិទ្ធិមនុស្ស ជាពិសេសអ្នកដែលខិតខំពុះពារដើម្បីការពារសិទ្ធិរបស់មនុស្ស ស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT)"។[151]ស្រដៀងគ្នានេះដែរនៅក្នុងលិខិតរួមមួយទៀតដែលពាក់ព័ន្ធនឹងច្បាប់ដែលត្រូវ

---

[149]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមានសេរីភាពក្នុងការបញ្ចេញមតិ និងការសម្តែងមតិ (E/CN.4/2005/64/Add.1) ត្រង់កថាខណ្ឌទី ៤៩៤និងរបាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស (E/CN.4/2005/101/Add.1)ត្រង់កថាខណ្ឌទី ៣៤២ ។

[150]សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សសម្រាប់សហព័ន្ធរុស្ស៊ី (CCPR/C/RUS/CO/6) ត្រង់កថាខណ្ឌទី ២៧ ។

[151]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមានសេរីភាពនៃគំនិត និងការសម្តែងមតិ (A/HRC/14/23/Add.1) ត្រង់កថាខណ្ឌទី ១៤០៥ ។

បានស្នើរឡើងនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោអ្នករាយការណ៍ពិសេសបានថ្លែងថាៈ

> *សេចក្តីព្រាងច្បាប់នេះ ក៏នឹងមានឥទ្ធិពលអវិជ្ជមានលើស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្សដែលធ្វើការងារលើកកម្ពស់ និង គាំពារសមភាពរបស់មនុស្សស្រី ស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ(LGBT) នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ។ សេចក្តីព្រាងច្បាប់នឹងជំរុញឲ្យអ្នកការពារសិទ្ធិមនុស្ស ធ្លាក់ចូលក្នុងសភាពងាយទទួលរងគ្រោះថ្នាក់ដែលកាន់តែកើនឡើងពិតប្រាកដ ដោយសារពួកគេអាចក្លាយជាចំណុចគោលដៅនៃការវាយប្រហារ និង អំពើបំភិតបំភ័យ ទាំងពី អាជ្ញាធរ និងប្រជាជនទូទៅ ។*[152]

*នៅក្នុងប្រទេសខ្លះ ការដើរក្បួនព្យុះហយាត្រា និងការប្រជុំផ្សេងទៀតរបស់មនុស្ស ស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ត្រូវបានបដិសេធមិនចេញលិខិតអនុញ្ញាតឲ្យ ឬ ត្រូវបានប្រឈមមុខនឹងការគំរាមកំហែង និងអំពើហិង្សាពីអ្នកឃ្លាំមើល។*

រដ្ឋទាំងឡាយជារឿយៗប្រើប្រាស់ "សីលធម៌សាធារណៈ" ដើម្បីធ្វើយុត្តិកម្មការកម្រិតលក្ខខណ្ឌលើសិទ្ធិសេរីភាពក្នុងការធ្វើសមាគម ការសម្តែងមតិ និង ការជួបជុំរបស់បុគ្គល និងអង្គការទាំងឡាយ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយចែងថាសិទ្ធិទាំងនេះអាចត្រូវបានដាក់កំហិតលក្ខខណ្ឌនៅពេលដែលការដាក់កំហិតលក្ខខណ្ឌត្រូវបានចែងដោយច្បាប់មានលក្ខណៈចាំបាច់ នៅក្នុងសង្គមប្រជាធិបតេយ្យ និង គឺដើម្បីគោលដៅត្រឹមត្រូវតាមច្បាប់។ គោលដៅត្រឹមត្រូវតាមច្បាប់ ដែលមាននៅក្នុងមាត្រា ១៩ មាត្រា ២១ និងមាត្រា ២២ មានលក្ខណៈស្រដៀងគ្នា ហើយទាំងអស់នេះរួមបញ្ចូល ការគាំពារសុខភាពសាធារណៈ និង សីលធម៌។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ដែលដាក់កំហិតលក្ខខណ្ឌលើសិទ្ធិទាំងនេះ "ត្រូវតែស្របទៅនឹងបទប្បញ្ញត្តិ គោលបំណង និងគោលដៅរបស់កតិកាសញ្ញាតែម្តង" និង "មិនត្រូវរំលោភបំពានលើបទប្បញ្ញត្តិដែលមិនមានលក្ខណៈរើសអើងនៃកតិកាសញ្ញា" ។[153]

អាណត្តិរបស់យន្តការនីតិវិធីពិសេសដែលដោះស្រាយជាមួយនឹងអ្នកការពារសិទ្ធិមនុស្ស និង សិទ្ធិសេរីភាពនៃគំនិត និង ការបញ្ចេញមតិ មានលក្ខណៈសកម្មណាស់ក្នុងការកត់ត្រាការរំលោភបំពានលើសិទ្ធិរបស់អ្នកការពារសិទ្ធិរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្ស

---

[152]របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលសិទ្ធិមានសេរីភាពនៃគំនិត និងការសម្តែងមតិ (A/HRC/17/27/Add.1)ត្រង់កថាខណ្ឌទី ៦៧៦ (ការបកប្រែភាសាមិនផ្លូវការ) ។

[153]សេចក្តីពន្យល់ទូទៅលេខ ៣៤ (មាត្រា ១៩) ត្រង់កថាខណ្ឌទី ២៦ សូមមើលផងដែរនូវសេចក្តីពន្យល់ទូទៅលេខ ២២ (មាត្រា ១៨) ត្រង់កថាខណ្ឌទី ៨ ("ការកម្រិតលក្ខខណ្ឌ អាចមិនត្រូវបានធ្វើឡើង ដើម្បីគោលបំណងដែលមានលក្ខណៈរើសអើង ឬ ត្រូវបានអនុវត្តតាមរបៀបរើសអើង") របស់គណៈកម្មាធិការសិទ្ធិមនុស្ស ។

ស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ (LGBT) និង មនុស្សមានភេទពីរ និង អ្នកដែលធ្វើការបញ្ហាពាក់ព័ន្ធ។[154]តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស បានថ្លែងថាៈ

*ក្នុងករណីជាច្រើនពីគ្រប់តំបន់ទាំងអស់ មន្ត្រីនគរបាល ឬ មន្ត្រីរដ្ឋាភិបាល ជាចារីដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តអំពើហិង្សា និង ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និង មនុស្សភេទពីរ (LGBTI)។ មានករណីមួយចំនួនក្នុងចំណោមករណីទាំងនេះ អាជ្ញាធរបានហាមឃាត់ការធ្វើបាតុកម្ម សន្និសីទ និងកិច្ចប្រជុំ បានបដិសេធមិនចុះបញ្ជីអង្គការដែលធ្វើការដើម្បីសិទ្ធិរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និង មនុស្សភេទពីរ (LGBTI) និងតាមការចោទប្រកាន់មន្ត្រីនគរបាលបានវាយដំ ឬ រំលោភបំពានផ្នែកផ្លូវភេទលើអ្នកការពារសិទ្ធិរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរមនុស្សប្តូរភេទ និងមនុស្សភេទពីរ(LGBTI) ទាំងនេះ។ ជាទូទៅ អាជ្ញាធរបានប៉ុនប៉ងធ្វើយុត្តិកម្មសកម្មភាពប្រឆាំងនឹងអ្នកការពារទាំងនេះដោយអះអាងថា "សាធារណជន" មិនចង់ឲ្យបាតុកម្មទាំងនេះត្រូវបានធ្វើឡើង ឬ អង្គការទាំងនេះត្រូវបានចុះបញ្ជីទេ ឬថា "ប្រជាជន" មិនចង់ឲ្យមានមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និង មនុស្សភេទពីរ (LGBTI) នៅក្នុងសហគមន៍របស់ពួកគេទេ។ តំណាងពិសេសបានលើកឡើងនូវមាត្រា ២ និង មាត្រា១២ នៃសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្សដើម្បីរំឭកដល់រដ្ឋទាំងឡាយអំពីការទទួលខុសត្រូវរបស់ខ្លួនចំពោះកិច្ចការពារអ្នកការពារសិទ្ធិមនុស្ស ពីអំពើហិង្សានិងការគំរាមកំហែង។[155]*

[154]**ការលើកឡើងពីហានិភ័យចំពោះអ្នកការពារសិទ្ធិរបស់ស្រីស្រលាញ់ភេទដូចគ្នា ប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ (LGBT)៖** របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្សៈA/HRC/16/44 ត្រង់កថាខណ្ឌទី ២៧ ៤៣ និង ៨៥ A/HRC/13/22/Add.3 និង A/HRC/13/22 ត្រង់កថាខណ្ឌទី ៤៩ A/HRC/10/12 ត្រង់កថាខណ្ឌទី ២១ ៦៥ ៧២ ៧៤ និង ៨២ A/HRC/4/37 ត្រង់កថាខណ្ឌទី ៩៣-៩៦ របាយការណ៍ប្រចាំឆ្នាំរបស់អ្នករាយការណ៍ពិសេសប្រចាំមហាសន្និបាត (A/61/312) ត្រង់កថាខណ្ឌទី ៧ របាយការណ៍នៃអ្នករាយការណ៍ពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស (C/CN.4/2001/94)ត្រង់កថាខណ្ឌទី ៨៩ ។ របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកការលើកកម្ពស់ និងកិច្ចការពារសេរីភាពនៃការសម្តែងមតិ និងគំនិត A/HRC/17/27/Add.1 ត្រង់កថាខណ្ឌទី ៦៧១-៦៧៦១៦៥៤-១៦៥៩ ២២២៨-២២៣១ និង ២០១២-២០១៨ A/HRC/14/23/Add.1 ត្រង់កថាខណ្ឌទី ៤៨៥-៥០៥១០១៨-១០៤៨ ២៤៨៣-២៤៨៩ ២៥០៨-២៥១២ ២០៩៣-២១១៣និង ១៤០០-១៤១៤ A/HRC/14/23/Add.2 ត្រង់កថាខណ្ឌទី ៥ A/HRC/7/14/Add.1 ត្រង់កថាខណ្ឌទី ៥២៩-៥៣០ E/CN.4/2006/55/Add.1 ត្រង់កថាខណ្ឌទី ១០៤៦ E/CN.4/2005/64/Add.3 ត្រង់កថាខណ្ឌទី ៧៥-៧៧ E/CN.4/2002/75/Add.1 ត្រង់កថាខណ្ឌទី ១២២-១២៤ E/CN.4/2005/64/Add.1ត្រង់កថាខណ្ឌទី ៤៩៤ ៦៤៨ ៧៩០ ៩៧២និង ៩៨១ ។

[155]របាយការណ៍របស់អ្នករាយការណ៍ពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស (A/HRC/4/37) ត្រង់កថាខណ្ឌទី ៩៦ ។

នៅក្នុងបរិបទនៃមាត្រា១៩ យន្តការនីតិវិធីពិសេសពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ បានបញ្ជាក់ឡើងវិញថាសិទ្ធិសេរីភាពក្នុងការសម្តែងមតិគឺជាសិទ្ធិដែលមនុស្សគ្រប់រូបមានដោយមិនគិតអំពីទំនោរផ្លូវភេទ និង/ឬអត្តសញ្ញាណយេនឌ័រ។ ដោយផ្តល់យោបល់លើសេចក្តីព្រាងច្បាប់របស់នីសេរីយ៉ាដែលនឹងដាក់ទោសលើការតស៊ូមតិជាសាធារណៈដោយគាំទ្រដល់សិទ្ធិរបស់ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ(LGBT) តំណាងពិសេសទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្សបានថ្លែងថា"ជាពិសេសកង្វល់ដ៏ខ្លាំងក្លាត្រូវបានសម្តែងចេញដោយពិចារណាទៅលើការកម្រិតលក្ខខណ្ឌដែលច្បាប់នេះនឹងមានទៅលើសេរីភាពក្នុងការសម្តែងមតិ និង ការធ្វើសមាគមរបស់អ្នកការពារសិទ្ធិមនុស្ស និង សមាជិកនៃសង្គមស៊ីវិល នៅពេលតស៊ូមតិដើម្បីសិទ្ធិរបស់ប្រុសស្រលាញ់ភេទដូចគ្នា និងស្រីស្រលាញ់ភេទដូចគ្នា" ។[156]

ស្រដៀងគ្នានេះដែរ នៅពេលច្បាប់ប្រឆាំងនឹងការស្រលាញ់មនុស្សភេទដូចគ្នា ត្រូវបានបញ្ចូលនៅប្រទេសអ៊ូហ្គាន់ដានៅក្នុងឆ្នាំ ២០០៩ តំណាងពិសេសពីររូបបានចេញសេចក្តីថ្លែងការណ៍រួមដែលលើកឡើងដោយផ្អែកថាៈ

> *ច្បាប់នេះនឹងរារាំងបង្អាក់ដោយមិនសមហេតុផលតទៅទៀតលើការប្រើប្រាស់សិទ្ធិសេរីភាពនៃគំនិតនិងការសម្តែងមតិ ជួបជុំដោយសន្តិវិធី និង ធ្វើសមាគមដោយហាមឃាត់ការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយឯកសារស្តីពីការស្រលាញ់ភេទដូចគ្នា ក៏ដូចជាការផ្តល់មូលនិធិ និងឧបត្ថម្ភដល់ សកម្ម -ភាពពាក់ព័ន្ធ។*[157]

នៅក្នុងរបាយការណ៍របស់លោកក្នុងដំណើរទស្សនកិច្ចទៅកាន់ប្រទេសកូឡុំប៊ីអ្នករាយការណ៍ពិសេសទទួលបន្ទុកលើកកម្ពស់ និង កិច្ចការពារសិទ្ធិ សេរីភាពនៃគំនិត និងការសម្តែងមតិ បានគូសបញ្ជាក់ថា"ពលរដ្ឋគ្រប់រូបក្នុងចំណោមកត្តាផ្សេងទៀតដោយមិនគិតអំពីទំនោរផ្លូវភេទមានសិទ្ធិសម្តែងមតិអំពីខ្លួនឯង និងស្វែងរក ទទួល និងចែកផ្សាយព័ត៌មាន" ។[158]

---

[156] របាយការណ៍របស់អ្នករាយការណ៍ពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស (A/HRC/4/37/Add.1) ត្រង់កថាខណ្ឌទី ៥១១ ។

[157] សេចក្តីថ្លែងការណ៍រួមរបស់អ្នករាយការណ៍ពិសេសទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស និងតំណាងពិសេសទទួលបន្ទុកសិទ្ធិមានសេរីភាពនៃគំនិតនិងការបញ្ចេញមតិ ចុះថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១០ ។

[158] របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមានសេរីភាពនៃគំនិត និងការសម្តែងមតិក្នុងដំណើរបេសកកម្មទៅកាន់ប្រទេសកូឡុំប៊ី (E/CN.4/2005/64/Add.3) ត្រង់កថាខណ្ឌទី ៧៥ និង ៧៦ ។

# សេចក្តីសន្និដ្ឋាន

រដ្ឋទាំងឡាយត្រូវតែធានាឲ្យមានសិទ្ធិ សេរីភាពក្នុងការសម្តែងមតិ ធ្វើសមាគម និង ជួបជុំដោយសន្តិវិធីចំពោះមនុស្សគ្រប់រូប ដោយមិនគិតអំពីភេទ ទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ និង ត្រូវតែធានាថាការដាក់កំហិតលក្ខខណ្ឌណាមួយលើសិទ្ធិទាំងនេះមិនមានលក្ខណៈរើសអើង។ដើម្បីការពារការប្រើប្រាស់សិទ្ធិទាំងនេះរដ្ឋទាំងឡាយត្រូវតែទប់ស្កាត់ ឬ ស៊ើបអង្កេត និង ផ្តន្ទាទោសឲ្យមានប្រសិទ្ធភាពលើអំពើហិង្សា និងការបំភិតបំភ័យដែលបង្កឡើងដោយភាគីឯកជន ។





# សេចក្តីសន្និដ្ឋាន

ដូចដែលជំពូកមុនៗបានបង្ហាញកិច្ចការពារមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ(LGBT) ពីអំពើហិង្សា និងការរើសអើងមិនតម្រូវឲ្យមានការបង្កើតសិទ្ធិជាក់លាក់ថ្មីមួយចំនួនរបស់ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រ-លាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ(LGBT)ទេ វាក៏មិនតម្រូវឲ្យមានការបង្កើតស្តង់ដាសិទ្ធិមនុស្សអន្តរជាតិថ្មីដែរ។ ចំពោះភាពតានតឹងនិងភាពស្មុគស្មាញទាំងអស់នៃការពិភាក្សាវែកញែកផ្នែកនយោបាយអំពីសមភាពនៃ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ(LGBT) នៅឯអង្គការសហប្រជាជាតិផ្តើមចេញពីទស្សនវិស័យច្បាប់បញ្ហានេះមានលក្ខណៈងាយយល់។ កាតព្វកិច្ចដែលរដ្ឋទាំងឡាយត្រូវតែការពារមនុស្សស្រីស្រ-លាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ (LGBT) ពីការរំលោភបំពានលើសិទ្ធិមនុស្សរបស់ពួកគេត្រូវបានកំណត់យ៉ាងត្រឹមត្រូវរួចហើយ និងកំពុងតែភ្ជាប់កាតព្វកិច្ចទៅរដ្ឋជាសមាជិកទាំងអស់នៃអង្គការសហប្រជាជាតិ។

សៀវភៅនេះព្យាយាមពន្យល់អំពីប្រភព និង វិសាលភាពនៃកាតព្វកិច្ចតាមផ្លូវច្បាប់ទាំងនោះដោយយោងទៅតាមសេចក្តីសម្រេចអនុសាសន៍ និង សេចក្តីណែនាំដ៏ច្រើនសន្ធឹកសន្ធាប់ដែលត្រូវបានចេញដោយយន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។វាបែងចែកការទទួលខុសត្រូវរបស់រដ្ឋជាប្រាំផ្នែកសំខាន់ៗដែលតាមរយៈនេះវិធានការរបស់ជាតិ គឺ ត្រូវការបន្ទាន់បំផុតពោលគឺចាប់ពីកិច្ចគាំពារពីអំពើហិង្សារហូតដល់ការបង្ការ-ទប់ស្កាត់ការធ្វើទារុណកម្មការមិនចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះការស្រលាញ់មនុស្សភេទដូចគ្នាការហាមឃាត់ការរើសអើង និង ការគោរពចំពោះសេរីភាពក្នុងការសម្តែងមតិធ្វើសមាគមនិងជួបជុំដោយសន្តិវិធី ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ រដ្ឋជាច្រើនមានធ្វើការខិតខំប្រឹងប្រែងជាលក្ខណៈប្តេជ្ញាចិត្តដើម្បីពង្រឹងកិច្ចការពារសិទ្ធិមនុស្សនៅក្នុងផ្នែកនីមួយៗ។ ច្បាប់ថ្មីៗជាច្រើនត្រូវបានអនុម័ត ពោលគឺក្នុងនោះរួមមានច្បាប់ដែលហាមឃាត់ការរើសអើងដាក់ទោសលើអំពើឧក្រិដ្ឋដោយសារការការស្អប់មនុស្សស្រលាញ់ភេទដូចគ្នា ផ្តល់ការទទួលស្គាល់ចំពោះទំនាក់ទំនងរបស់មនុស្សភេទដូចគ្នានិងបង្កលក្ខណៈងាយស្រួលដល់អ្នកប្តូរភេទក្នុងការទទួលបានឯកសារផ្លូវការដែលឆ្លុះបញ្ចាំងអំពីភេទដែលគួរជាទីចូលចិត្តរបស់ពួកគេ។ កម្មវិធីបណ្តុះបណ្តាលត្រូវបានរៀបចំបង្កើតឡើងសម្រាប់នគរបាល បុគ្គលិកពន្ធនាគារ គ្រូបង្រៀន បុគ្គលិកសង្គមកិច្ច និង បុគ្គលិកដទៃទៀត ព្រមទាំងគំនិតផ្តួចផ្តើមប្រឆាំងនឹងការសម្លុតកំហែងត្រូវបានអនុវត្តនៅតាមសាលារៀនជាច្រើន។

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះកិច្ចការជាច្រើនទៀតចាំបាច់ត្រូវសម្រេចឲ្យបានដើម្បីប្រឈមមុខជាមួយ បុរេនិច្ឆ័យ និង ការពារមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ(LGBT)នៅក្នុងគ្រប់ប្រទេសទាំងអស់ពីអំពើហិង្សា និង ការរើសអើង។ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សសង្ឃឹមថាអត្ថបទបោះពុម្ពផ្សាយនេះអាចជួយរួមចំណែកដល់គោលដៅនេះដោយផ្តល់ធនធានជាក់ស្តែងដល់មនុស្សទាំងអស់ដែលខិតខំពុះពារដើម្បីការផ្លាស់ប្តូរទោះជាផ្តើមចេញពីទស្សនវិស័យរបស់អង្គការសហប្រជាជាតិអង្គការតំបន់រដ្ឋាភិបាល ស្ថាប័នសិទ្ធិមនុស្សជាតិ ឬ សង្គមស៊ីវិលក៏ដោយ។

**ការសាកសួរណាមួយ** គួរតែត្រូវបានបញ្ជូនទៅ៖

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ
8-14, Avenue de la Paix
1211 Geneva ប្រទេសស្វីស

**ការិយាល័យក្រុងញូវយ៉ក**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្ស
អង្គការសហប្រជាជាតិ
ទីក្រុងញូយ៉ក NY 10017
សហរដ្ឋអាមេរិក

**ការសរសេរ**

ត្រូវបានរៀបចំឡើងដោយការិយាល័យឧត្តមស្នងការ
អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំទីក្រុងញូវយ៉ក

ទីប្រឹក្សា៖ Allison Jernow គម្រោងទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ
គណៈកម្មការអ្នកច្បាប់អន្តរជាតិ (ICJ)ទីក្រុងហ្សឺណែវ

**រៀបចំរូបថត ដោយ៖**

Emma K. Lydersen//បេសកកម្មរបស់អង្គការសហប្រជាជាតិនៅប្រទេសណូរវេ (ទំព័រទី ១២)
Luca Zennaro/EPA (ទំព័រទី ១៣)
Zsolt Szigetvary/EPA (ទំព័រទី ២១)
Jordi Matas (ទំព័រទី ២៩)
Orlando Barria/EPA(ទំព័រទី ៣២)
Gil Yarri/EPA (ទំព័រទី ៣៨)
Tatyana Zenkovich/EPA (ទំព័រទី ៤៣)
Francis R. Malasig/EPA (ទំព័រទី ៤៥)
Jim Lo Scalzo/EPA (ទំព័រទី ៥១ និងទំព័រទី ៧២)
Divyakant Solanki/EPA (ទំព័រទី ៥៣)
Jagadeesh NV/EPA (ទំព័រទី ៥៨)
Zsolt Szigetvary/EPA (ទំព័រទី ៦៥)
Abir Sultan/EPA (ទំព័រទី ៦៧)
រូបថតនៃអង្គការសហប្រជាជាតិ (ទំព័រទី ៧៣)

**ប្លង់ និងការរៀបចំ៖**

Stefan Einarsson / www.stefaneinarsson.com
បោះពុម្ពផ្សាយនៅអង្គការសហប្រជាជាតិ ក្នុងទីក្រុងញូវយ៉ក

# កើតមក មានសេរីភាព និង សមភាព

" ចំពោះអ្នកដែលជាមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ ឬមនុស្សប្តូរ ភេទ ខ្ញុំសូមនិយាយថា: អ្នកមិននៅឯកោទេ  ការតស៊ូរបស់អ្នក ដើម្បីបញ្ចប់អំពើហិង្សា និងការរើសអើងគឺជាការតស៊ូរួមគ្នា។ ការ វាយប្រហារណាមួយលើរូបអ្នក គឺជាការវាយប្រហារលើតម្លៃជា សកលដែលអង្គការសហប្រជាជាតិ និងខ្ញុំបានធ្វើសច្ចាប្រណិធានថានឹងការពារ និង គោរព។ ថ្ងៃនេះ ខ្ញុំគាំទ្រអ្នក ហើយខ្ញុំសូមអំពាវនាវដល់ប្រទេសទាំងអស់ និងមនុស្សទូទៅឲ្យគាំទ្រ អ្នកដែរ" ។

— **អគ្គលេខាធិការអង្គការសហប្រជាជាតិ**
**បាន គីមូន ខែ មីនា ឆ្នាំ ២០១២**

" នៅពេលដែលខ្ញុំលើកឡើងអំពីបញ្ហាអំពើហិង្សា និងការរើសអើងចំពោះបុគ្គលទាំងឡាយ ដោយសារទំនោរផ្លូវភេទ ឬ អត្តសញ្ញាណ យេនឌ័រ អ្នកខ្លះត្អូញត្អែរថា ខ្ញុំកំពុងតែជំរុញឲ្យមាន "សិទ្ធិថ្មី" ឬ "សិទ្ធិពិសេស"។ ប៉ុន្តែមិនមានអ្វីថ្មី ឬ ពិសេសទេ អំពីសិទ្ធិរស់រាន មានជីវិត និងសន្តិសុខផ្ទាល់ខ្លួន សិទ្ធិសេរីភាពពីការរើសអើង ។ សិទ្ធិទាំងនេះ និងផ្សេងទៀត មានលក្ខណៈជាសកល ដូចដែល បានចែងនៅក្នុងច្បាប់អន្តរជាតិ ប៉ុន្តែត្រូវបានបដិសេធចំពោះមនុស្សជាច្រើននៅក្នុងក្រុមរបស់យើង គ្រាន់តែដោយសារទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័ររបស់ពួកគេ" ។

— **ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**
**ណាវី ភីឡាយ ខែ ឧសភា ឆ្នាំ ២០១២**

"ការហាមឃាត់ចំពោះការរើសអើងដូចមានចែងនៅក្នុងមាត្រា ២៦ (នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ) ក៏មានការរើសអើងដោយសារទំនោរផ្លូវភេទដែរ" ។

— **គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ**
**រឿងក្តីរបស់អ៊ិច ទល់ជាមួយប្រទេសកូឡុំប៊ី (២០០៧)**

"រដ្ឋភាគី (នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌) គួរតែធានាថា ទំនោរផ្លូវភេទរបស់ មនុស្ស មិនមែនជាឧបសគ្គក្នុងការសម្រេចបាននូវសិទ្ធិដែលបានចែងនៅក្នុងកតិកាសញ្ញាទេ" ។ ...... ក្រៅពីនេះ អត្តសញ្ញាណភេទត្រូវបានទទួលស្គាល់ជាមូលហេតុ នៃការរើសអាងដែលត្រូវបានហាមឃាត់"

— **សេចក្តីពន្យល់ទូទៅលេខ ២០ (ឆ្នាំ ២០០៩) របស់គណៈកម្មាធិការ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ នៃអង្គការសហប្រជាជាតិ**

"ការរើសអើងចំពោះស្ត្រី ដោយសារភេទ និង យេនឌ័រ ត្រូវបានផ្សារភ្ជាប់ទំនាក់ទំនងដោយមិនអាចបំបែកបានជាមួយនឹងកត្តាផ្សេងទៀតដែលប៉ះពាល់ដល់ស្ត្រី ដូចជា ......ទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ"

— **អនុសាសន៍ទូទៅលេខ ២៨ (ឆ្នាំ ២០១០) របស់គណៈកម្មាធិការ**
**ទទួលបន្ទុកលុបបំបាត់ការរើសអើងលើស្ត្រី**

"រដ្ឋភាគី (នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម) ត្រូវតែធានាថា ពាក់ព័ន្ធនឹងកម្មវត្ថុនៃកាតព្វកិច្ចដូចមានចែងនៅក្នុងអនុសញ្ញា ច្បាប់របស់ខ្លួនត្រូវបានអនុវត្តជាក់ស្តែងចំពោះមនុស្សទាំងអស់ ដោយមិនគិតអំពី .........ទំនោរផ្លូវភេទ (ឬ) អត្តសញ្ញាណប្តូរយេនឌ័រ"

— **សេចក្តីពន្យល់ទូទៅលេខ ២ (ឆ្នាំ ២០០៨) របស់គណៈកម្មាធិការ**
**ប្រឆាំងនឹងការធ្វើទារុណកម្មនៃអង្គការសហប្រជាជាតិ**